Theology on the Web.org.uk

Making Biblical Scholarship Accessible

This document was supplied for free educational purposes. Unless it is in the public domain, it may not be sold for profit or hosted on a webserver without the permission of the copyright holder.

If you find it of help to you and would like to support the ministry of Theology on the Web, please consider using the links below:

Buy me a coffee https://www.buymeacoffee.com/theology

PATREON https://patreon.com/theologyontheweb

**PayPal** https://paypal.me/robbradshaw

---

A table of contents for *Honeycomb* can be found here:

https://biblicalstudies.org.uk/articles_honeycomb.php




ព្រឹត្តិបត្រទេវសាស្ត្រទ្វេភាសា ខ្មែរ-អង់គ្លេស ផ្តល់នូវចំណេះដឹងផ្នែកព្រះគម្ពីរ
ដល់លោកអ្នក ប្រៀបដូចជាទឹកឃ្មុំផ្តល់កម្លាំងដល់អ្នកដំណើរដែលកំពុងខ្សោយល្វើយ ។

A bilingual Khmer-English Theological Journal to give biblical knowledge to its readers as a honeycomb gives strength to exhausted travelers.

---

ឆ្នាំទី ២ លេខ ១

Vol. 2, No. 1

ខែ មករា ឆ្នាំ ២០០១

January 2001

គម្រោងកម្មវិធីហ្វឹកហ្វឺន ធីម៉ូថេ បានបោះពុម្ពព្រឹត្តិបត្រ *សំណុំទឹកឃ្មុំ* នេះឡើង ។
ទាក់ទងតាមការិយាល័យប្រៃសណីយ៍ ប្រអប់សំបុត្រលេខ ៤៧៩ ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ (៨៥៥) ២៣ ២១៦ ០៥២ ទូរសារលេខ (៨៥៥) ២៣ ២១៦ ៤២០
សារអេឡិចត្រូនិច: Russell_Bowers@wvi.org
បណ្ណាធិការ Russell H. Bowers, Jr.
ផ្នែកប្រែសម្រួល: អ៊ួន សិលា
ពិនិត្យផ្ទៀងផ្ទាត់ភាសាខ្មែរ: ម៉ម បាណាបាស
ផ្នែកបច្ចេកទេស: លុយ ពៅ
សំណេរអត្ថបទ និង ការទាក់ទងផ្សព្វផ្សាយ ត្រូវដាក់ជូនមកបណ្ណាធិការ
បោះពុម្ពនៅទីក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

*Honeycomb* is published by Training of Timothys
Central Post Office, P.O. Box 479, Phnom Penh, Kingdom of Cambodia
email Russell_Bowers@wvi.org
editor, Russell H. Bowers, Jr.
translation, Uon Seila
Khmer proofreading, Barnabas Mam and
technical support, Luy Peou

Manuscripts and communications should be addressed to the editor.
Printed in Phnom Penh, Kingdom of Cambodia.

# From the Editor

We are happy to include a variety of articles in this quarter's *Honeycomb*. Two are designed to stimulate our readers' thinking on culture and indigenization. Dr. Ravi Jayakaran's work on wholistic participatory learning and action reminds Christians of the importance of grasping the worldview of those to whom we are ministering if our ministry is to prove effective and transformational. Arun Sok Nhep's reflection on indigenization builds on this idea to suggest practical ways that understanding Khmer culture could influence church structure here.

A third article may also prove "cross-cultural" for many of our readers. François Ponchaud is a senior Roman Catholic missionary statesman in Cambodia, and discusses the steps his church follows in nurturing adult conversion in this mostly non-Christian environment. Among Ponchaud's other published works are his *Cambodia: Year Zero* and *Cathedral of the Rice Paddy*.

Ian Webber has written a devotional and exhortational study on intercession, and this quarter's *Honeycomb* includes a brief introduction on one of the least-studied books of the New Testament—Philemon. We regret that Robert Choy was unable to submit his promised follow-up article on "God and Money" due to his recent move from Cambodia to New Zealand.

To round out this issue of the journal, Debbi Maher introduces us to Yos Em Sithan, whose efforts a little over a decade ago encouraged official tolerance of Christianity.

As always, our hope is that these studies will introduce new ideas to our readers, to the end that we mature in our understanding and ministries. May we approach these articles in the spirit of 1 Thessalonians 5:19–22, which rendered roughly says, "Welcome opportunities for learning. But test all you hear. Then swallow the fish and spit out the bones."

# ចេញពីបណ្ណាធិការ

យើងរីករាយក្នុងការបញ្ចូលអត្ថបទចំរុះគ្នា នៅក្នុងសំណាំទឹកឃ្មុំ ត្រីមាសនេះ ។ អត្ថបទពីរដែលបានរៀបចំឡើង ដើម្បីជាស់ស្មារតីផ្តល់គំនិតអ្នកអានរបស់យើង ឲ្យគិតអំពីវប្បធម៌ និងការធ្វើឲ្យពួកជំនុំមានលក្ខណៈឯករាជ្យម្ចាស់ការ ។ អត្ថបទរបស់បណ្ឌិត ចៃយ៉ាការ៉ាន់ ស្តីអំពីការចូលរួមយល់ដឹងពីលក្ខណៈគ្រប់ជ្រុងជ្រោយ និងស្តីពីសកម្មភាពដែលរំលឹកគ្រីស្តបរិស័ទ ឲ្យគិតដល់សារៈសំខាន់នៃការក្រសោបយកគតិលោករបស់ពួកមនុស្ស ដែលយើងកំពុងបំរើ ។ លោក សុខ ញិបអារុណ អត្ថបទរបស់គាត់រំពឹងគិតនៃការធ្វើឲ្យពួកជំនុំមានលក្ខណៈឯករាជ្យម្ចាស់ការ ដើម្បីឲ្យយល់ពីទំនៀមទម្លាប់ វប្បធម៌ខ្មែរដែលអាចមានឥទ្ធិពលរចនាសម្ព័ន្ធរបស់ ពួកជំនុំនៅទីនេះ ។

លោកឪពុក ហ្វ្រង់ស្វ័រ ប៉ុងសូដ៍ គឺជារដ្ឋបុរសនៃសាសនទូតរបស់ព្រះសហគមន៍ នៅក្នុងប្រទេសកម្ពុជា និងពិភាក្សាអំពីជំហានទាំងឡាយដែលព្រះសហគមន៍របស់គាត់បានធ្វើក្នុងការបំពាក់បំប៉នមនុស្សពេញវ័យ ឲ្យក្លាយទៅជាគ្រីស្តបរិស័ទ ដែលនៅក្នុងនេះភាគច្រើន ជាបរិយាកាសដែលមិនមែនជាគ្រីស្តបរិស័ទ ។

លោក អៀន វិប័រ បានសរសេរអត្ថបទនៃការសិក្សាស្តីពីការទូលអង្វរ និង នៅក្នុងលេខនៃព្រឹត្តិបត្រសំណាំទឹកឃ្មុំនេះ ក៏មានបញ្ចូលអត្ថបទ នៃការបង្ហាញឲ្យស្គាល់ពីលក្ខណៈក័ណ្ឌគម្ពីរភីលេម៉ូន ។ យើងមានការ សោកស្តាយណាស់ ដែលលោក រ៉ូប៊ីត ឆយ មិនអាចសរសេរអត្ថបទ ស្តីពី "ប្រាក់ និង ព្រះ" វគ្គទី ២ នៅក្នុងការចេញផ្សាយលេខនេះ ដែលគាត់បានសន្យានោះ ព្រោះគាត់ត្រូវផ្លាស់ទៅប្រទេសនូវែលហ្សេឡង់វិញ ។

ជាទីបញ្ចប់នេះ ដេប៊ី ម៉ាហើរ បាននាំឲ្យយើងស្គាល់លោកស្រី យស់ ឯមស៊ីថាន ដែលមានការប្រឹងប្រែងបានសម្រេចជោគជ័យ ក្នុងជំនឿគ្រីស្តបរិស័ទត្រូវបានទទួលស្គាល់ជាផ្លូវការ ។

យើងសង្ឃឹមថា នៅក្នុងការសិក្សាទាំងនេះនឹងនាំមកជូននូវគំនិតថ្មីដល់លោកអ្នកអានរបស់យើង ។ សូមឲ្យយើងចូលមកអានអត្ថបទទាំងនេះ ក្នុងស្មារតីនៃ ១ថែស្សាឡូនិក ៥:១៩-២២ ដែលធ្វើឲ្យយើងអាចនិយាយថា "ស្វាគមន៍ចំពោះឱកាសទាំងឡាយ ដែលយើងបានរៀន ។ តែសូមធ្វើការសាកល្បងលមើលអ្វី ដែលអ្នកបានឮ ។ សូមលេបតែសាច់ត្រី និង ខ្ជាក់ឆ្អឹងត្រីចេញ" ។

VOLUME 1 JANUARY 2001 NUMBER 1

# Honeycomb

**Our Experiences with Wholistic PLA's** 1
*Ravi I. JAYAKARAN*

**បទពិសោធន៍របស់យើងជាមួយពន្ធកិច្ចគ្រប់ជ្រុងជ្រោយ PLA** ១១
*រ៉ាវី ចាយ៉ាការ៉ាន់*

**Intercession** 26
*Ian WEBBER*

**ការទូលអង្វរ** ៣២
*អៀន ទីប៉័រ*

**Introduction to Philemon** 42
*Russell H. BOWERS, Jr.*

**ការណែនាំឲ្យស្គាល់ពីលក្ខណៈគម្ពីរ ភីលេម៉ូន** ៥៦
*រ៉ាស់សែល បូវើស៍*

**Training Adults to Become Christian in the Catholic Church** 77
*François PONCHAUD*

**ការបង្ហាត់មនុស្សពេញវ័យឲ្យទៅជាគ្រីស្ទបរិស័ទ តាមរបៀបព្រះសហគមន៍កាតូលិក** ៨៦
*លោកបូជាចារ្យ ហ្វ្រង់ស្វ័រ ប៉ុងសូដ៍*

**Indigenization of a National Church** 99
*Arun SOK NHEP*

**ការធ្វើឲ្យពួកជំនុំក្នុងស្រុកមានលក្ខណៈម្ចាស់ការ** ១១១
*សុខញិប អារុណ*

***Biography:* Yos Em Sithan** 129
*Debbi MAHER*

**ការជួបជាមួយ លោកស្រី យស់ ឯមស៊ីថាន** ១៣៣
*ដេប៊ី ម៉ាហើរ*

HONEYCOMB 2/1 (January 2001): 1–10

# Our Experiences with Wholistic PLA's: Seeing the Spiritual and Whose Reality Counts

*Ravi* I. *JAYAKARAN*

"*A nation forges deities in its imaginings, in its sacred literature, in wood and stone. The forms it gives them, the forces it has them embody, the virtues with which it endows them reflect the accumulated experience of the nation, the insights of its seers they answer to its needs.*" Thus wrote Arun Shourie in the introduction to his *Worshiping False Gods*. The gods a community worships and its spiritual beliefs demonstrate the way that community sees its world and perceives reality. What a sad reflection this is on Christians who have chosen to ignore these areas while striving to understand communities.

In recent years major paradigm shifts have been made in community development. It has been increasingly recognized that "Top Down" externally conceived solutions do not solve the problems of communities. Nor are they sustainable, since a major part of sustainability is community ownership. Understanding the community's reality is therefore an absolute must. This realization has now moved beyond non-government organizations to major development agencies like UNICEF, UNDP, WHO, and universities, as well as to major government agencies. Hence these agencies have started using PLA (Participatory Learning and

Action) on a wide scale. By contrast, Christian agencies have often failed to appreciate the need to understand the spiritual reality of communities *as they see it* before trying to witness to them.

In World Vision India we have started employing wholistic PLA in order to analyze the world view of various communities. This analysis takes the form of recognizing each of the dimensions that influence the survival strategies of communities and the lives of their inhabitants. It is mandatory to understand the specific influence these dimensions bear on their lives. For example, our research has shown that communities in one area see three main controlling influences.




These three influences affect each aspect of the survival strategy. For instance, a particular village community may depend on the following aspects for survival:

- Agriculture
- Animal husbandry
- Herbal medication
- Minor forest produce collection
- Electricity
- Local market
- Communication (Road)
- Etc.

The community sees god(s), outsiders, and themselves influencing each of these aspects to some extent or another. In

some cases, the influence may arise from only one source; in other cases, from two or all three. The extent which each of these influences affects an area of life will vary from community to community. For instance, the various influences on agriculture for three different villages may be as follows:




The areas of greatest uncertainty are those assigned to a god. A visit to these villages will show the centrality each ascribes to the god of rainfall. In Village 3, which depends entirely upon rain, the influence of the god will be perceived to be most important. Both Villages 1 and 2, which enjoy access to a water source more dependable than rain, depend more marginally on the rain deity, but he still can affect the village since rain can fall at the wrong time—say around harvest time—and completely damage the crop.

For each of the other aspects of the survival strategy, the degree of influence by gods, others, and themselves would similarly vary from one village to the other. Ethnographic studies of these villages may indicate the same people group or religious background, but their wholistic world view when analyzed may present a totally different profile. The technique that can be used for carrying out a wholistic world view analysis (WWVA) has been detailed in *Making Wholistic Disciples: World View Analysis: Measuring What Matters*, produced by World Vision India.

The degree of influence of each influencer—namely *god, outsiders* and *themselves*—is discovered using a popular PLA technique called the "10 Seed Technique" developed by the author and expanded to be used here wholistically.

The world view of a community can be more accurately ascertained on the basis of a *capability and vulnerability profile* of the community than by the *stated religious belief* of the group. For instance, in the village Dighori we assumed that the community—since it was predominantly neo-Buddhist—would have a Buddhist world view. On the contrary, we found that the gods and spirits that influenced the villagers' lives were those that controlled the areas of their vulnerability—the gods that controlled rainfall, disease, and the wild animals. Buddha, the god that they profess, only influenced the area of "peace of mind," and this was done by the regular recitation of "shlokas" (poetic praise songs) that they all knew very well. The overriding influences in their lives remain largely determined by the *way they see reality—their world view.* Thus even communities that claim to be Christian but have not had their world views influenced by the scriptures are likely to forge deities in their imaginings. They do this in order to address their vulnerabilities, or try to twist god to become appropriately usable (i.e., fulfill a utilitarian role). The first step in making wholistic disciples therefore is first to understand clearly the world view, and then begin the process of discipling.




Some discipling processes only change *behavior*, others change *behavior and beliefs* but leave the world view unaltered. By default the *world view becomes the overriding, dominating influence.*

In the diagram, which is an adapted modification from one used by Heibert and Dyrness, the outermost area is that of behavior. This is one that is most susceptible to change by external influence. Within behavior lies the deeper realm of belief, which needs stronger penetrative indoctrination before any change is adopted. However the controlling center is that of the world view. If one's world view is not properly *understood, analyzed, and discipled*, it will by default revert realities back to how it has traditionally seen them. Thus when the external influences for change are withdrawn, the undiscipled world view will take over and revert things back to the earlier status.

The survival strategy as a whole consists of various activities that a community undertakes in order to hold its world together. These will consist of the various aspects already mentioned. Those aspects in their direct control are seen as *capabilities* and those that are under indirect control are seen as *vulnerabilities*. Nevertheless, a *seamless continuum* runs between the directly controlled and indirectly controlled—between the *empirical and supernatural.*




Thus, whenever a development agency identifies what it considers an "area of vulnerability," it actually is in the eyes of the concerned community an area *well within their control*, albeit indirect control. Intentions by the development agencies to

intervene are thus seen as being at conflict with the *existing ruling supernatural.*




## Wholistic World View Analysis of a Community

In analyzing a community's survival strategy, one notices the peripheralization of god, wherein he is turned to only for assisting in areas of uncertainty. As the circle of influence of the community to control its environment widens with access to resources and building up of skills (enhanced capabilities), one might actually see god pushed out of that particular aspect. Thus a development agency that doesn't recognize reality as seen by the community may actually cause damage to the world view, making the community more and more godless. Perhaps this gives us greater insight into what has happened to western affluent communities which have developed survival strategies that have brought more of the uncertainties into their control, thus pushing god out of playing an active role in their lives.

Wholistic PLA also enables us to perceive how messages that we attempt to communicate are understood by the community. For example in the village of Gohekhurd we discovered that the community's perception on approaching god was different from that of the World Vision staff working in the project. The more powerful the god, the less frequently was he to be approached; and then never by individuals, but always by a whole village or several

villages together. In the face of this belief system the World Vision staff were talking about a God who interacted with individuals on a personal level and who actually "came to the door and knocked" (Rev 3:20). This obviously didn't make sense to them, for they thought that he was "too small" to be worthy for them to follow.

Another major weakness in our approach is that we do not come across to people as a community. We are more visible as a group of individuals who are vertically aligned (hierarchically). The strong sense of being a community with *its vibrant supportive relational interaction* is not seen in us. Thus community level interaction with World Vision is with different "individuals" with whom they meet, rather than with a Christian community. The profile of the individual they interact with plays a major role. Thus individuals can only play a role with the particular caste group that they are a part of. This is especially very strong in the rural areas of Maharashtra and Karnataka where caste plays a dominant role. Since the names of people bear the caste they are from, there is a strong overriding influence on efficiency in influencing the community. A totally changed name (anglicized or "Christian" name) is assumed to be a cover-up for a lower caste, because the features and the style of speaking betray the origin of a person.

A major barrier for communication is the strong caste system. Except in the tribal areas, major rural portions in Maharashtra, Gujarat, and Karnataka states are strongly influenced by caste. For example in the Vidharba region of Maharashtra, there are villages where some of our staff cannot have any influence at all because of their origin and the family backgrounds from which they come.

It is said that culture is the patent that ensures the continuance of a practice. Caste then is the ground matrix that gives the practice its framework. Having to work within this framework restricts the efficiency of the transformational development process. Yet this is a *reality* that one has to be able to acknowledge that the community is a part of.




At the base of ethnocentricity is attitude, as can be seen in the diagram alongside. The community's attitude to a particular thing results in *prejudice.* A very strong attitude may have a history behind it and thus result in a strong prejudice against or for that particular stand. In due course of time this attitude is manifest in the form of ethnocentricity, and it shapes the cultural practices which lend the community the justifiable reasons for their particular stand.

Change therefore, has to take place at the attitude level before we can overcome prejudice or change ethnocentricity. The background *experiential history* of a community plays a vital role in shaping its attitude. Hence it is important to *listen to and explore their history as perceived by them* if we want to even begin to understand what their attitude is.

Thus to summarize the discussions till now:

1. Understanding the reality of the community "as they see it" is mandatory for effective Christian witness. Stated differently, *Their reality counts.*
2. Our experience using wholistic PLA has shown us that when we start to listen to communities and try to understand their reality, we find their world views to be very different from what we expected. Often those with similar ethnographic profiles had divergent world views, and this was because of their *experiential history.*
3. Communities need to be *empowered to share their world views—to tell their stories.* This involves use of proactive processes like wholistic PLA.
4. Communities have definite perceptions of and effects related to their circumstances and the issues facing them. They must be *facilitated to present their understanding of the cause and effect* of matters that impact their survival strategies.

5. Last, but in no way the least, our effectiveness in understanding the community's reality depends on how well we are able to *make a paradigm shift* in our approach in order to be more open and understanding.

## A Short Note on Wholistic PLA

PLA has been successfully used in development circles for years. It has now started breaking ground even with the larger development agencies and government departments. It has found wide scale application for generating new insights into a wide range of subjects such as demographic profiles, education, health, agriculture, deforestation, rural and urban integrated community development, relief and development, children's programs, marriage counseling, AIDS awareness, BCC (Behavior Change Communication), etc.

More recently, earlier PLA methods have been *modified and expanded* to go beyond the empirical to facilitate a better understanding of the supernatural as well. Though PLA always had the potential to be so used, the method stayed largely confined to use in a secular way to understand only the empirical.

World Vision India has carried out some pioneering work in this regard and expanded its scope so that it could also be used in carrying out a Wholistic World View Analysis and for "measuring what matters in Christian witness." The precondition still remains as with other PLAs, i.e., the mandatory attitude change within the practitioner.

The scope for the use of wholistic PLAs in World Vision is broad and can find widespread use in our Area Development Programs (ADPs). At the end of the final exercise where the world view analysis diagram is completed, there is scope for us to discuss with the community *in interactive dialogue* what their assessment of the "perfect God" is—who would be able to deal with *every aspect* of their lives: (a) help them become *better stewards of their capabilities* and (b) enable them to be *empowered to deal with their vulnerabilities effectively.*

This would essentially work towards bringing god actively into the area of their capabilities—that part of their survival strategy which is within their control and also bring about an integration of several smaller "god needs" to be concentrated in one place (reconciled diversity). This would be the *first step* in discipling their world view. The second step would be to bring about further integration (centripetal infusion) to show that it is the *same God* who deals with their *vulnerabilities and capabilities.*

While all this sounds exciting and promises major breakthroughs, the reality remains that there is a lot of resistance to doing anything differently. Work like this, because it challenges all our earlier presuppositions, can be threatening. It calls on us to be willing for *open-ended interactive dialogue* for which we may not be ready. However, if we are willing to make that change, and follow what Jesus said about resembling a seed that falls and dies before it brings forth shoots, a stem, leaves, and finally fruit, then I believe we are at the *threshold of a new beginning!*

* * * * *

*"Preach the gospel all the time; if necessary use words."*
*–St. Francis of Asissi*

*"Be careful how you live.*
*You may be the only Bible some person ever reads."*
*–Unknown*

---

Adapted from a research article written by Dr. Ravi I. Jayakaran while he was working with World Vision of India.

សំណុំឯកឃ្មុំ ២/១ (មករា ២០០១): ១១-២៥

# បទពិសោធន៍របស់យើងជាមួយ ព័ន្ធកិច្ចគ្រប់ជ្រុងជ្រោយ PLA’s: មើលខាងវិញ្ញាណ និង អ្វីដែល រាប់បញ្ចូលថាជាការពិត

*រ៉ាវី ចាយ៉ាការ៉ាន់*

Arun Shourie បានសរសេរនៅក្នុងសេចក្តីផ្តើមនៃសៀវភៅការថ្វាយបង្គំព្រះខុសឆ្គងរបស់ខ្លួនថា "ប្រជាជាតិមួយ ខិតខំសំអិតសំអាងពួកទេវៈតាមមនោគំនិតរបស់គេ ក្នុងអក្សរសាស្ត្រដ៏ពិសិដ្ឋរបស់គេ អំពីឈើ និង ថ្ម ។ ទំរង់ភាពជាតំណាង និង គុណធម៌ដែលគេបានផ្តល់ឲ្យពួកទេវៈនោះ ឆ្លុះបញ្ចាំងឲ្យឃើញនូវបទពិសោធន៍ ដែលបានមកជាបន្តបន្ទាប់ ជាការយល់ឆ្លុះជ្រៅរបស់អ្នកទាយហេតុការណ៍ទុកជាមុន ដែលឆ្លើយតបចំពោះសេចក្តីត្រូវការរបស់គេ" ។ ព្រះទាំងឡាយ ដែលសហគមន៍មួយថ្វាយបង្គំ និង ជំនឿខាងវិញ្ញាណរបស់សហគមន៍បង្ហាញពីរបៀបដែលសហគមន៍មើលឃើញ ពិភពលោករបស់ខ្លួន ហើយទទួលបាន(យល់ដឹង) ពីការពិតរបស់ខ្លួន ។ អ្វីជាការឆ្លុះបញ្ចាំងដ៏សោកសៅ នោះគឺស្ថិតនៅលើគ្រីស្តបរិស័ទ ដែលបានជ្រើសរើសមិនអើពើនឹងចំណុចទាំងនេះ ក្នុងពេលដែលប្រឹងប្រែង ស្វែងយល់ពីសហគមន៍ ។

ក្នុងឆ្នាំថ្មីៗនេះ ការផ្លាស់ប្តូរគំរូធំជាងគេបានធ្វើឡើង នៅក្នុងការអភិវឌ្ឍន៍សហគមន៍ ។ គេទទួលស្គាល់កាន់តែច្រើនឡើងថា ដំណោះស្រាយពីខាងក្រៅ តាមបែប ថ្នាក់ខ្ពស់មកថ្នាក់ទាប មិនបានដោះស្រាយបញ្ហារបស់សហគមន៍ទេ ។ ហើយក៏មិនបានជួយទ្រទ្រង់ពួកគេ ចាប់តាំងពីផ្នែកដ៏សំខាន់នៃនិរន្តរភាព គឺជាភាពម្ចាស់ការរបស់សហគមន៍ ។ ដូច្នេះការយល់ពីការពិត របស់សហគមន៍ គឺជាសេចក្តីចាំបាច់បំផុត ។ ឥឡូវនេះ

លទ្ធផល នៃការទទួលស្គាល់បានផ្លាស់ប្តូរលើសពីអង្គការក្រៅរដ្ឋាភិបាល ទៅជាទីភ្នាក់ងារអភិវឌ្ឍន៍ចំបងៗ ដូច **UNICEF, UNDP, WHO** និង សកលវិទ្យាល័យនានា ព្រមទាំងភ្នាក់ងាររដ្ឋាភិបាលចំបងៗ ផ្សេងៗ ទៀត ។ ដូច្នោះហើយភ្នាក់ងារទាំងនេះចាប់ផ្តើមអនុវត្ត **PLA** (ការចូលរួម ការហ្វឹកហ្វឺន និង សកម្មភាព **Participatory Learning and Action** ) លើមាត្រដ្ឋានធំទូលាយ ។ ផ្ទុយមកវិញ ភ្នាក់ងារត្រីស្តបរិស័ទទាំងឡាយ ជាញឹកញាប់ មិនអបអរសាទរនឹងសេចក្តីត្រូវការ ដើម្បីយល់ដឹងពីការពិត ខាងវិញ្ញាណរបស់សហគមន៍ទាំងឡាយ ដូចដែលពួកគេមើលឃើញ មុន ការព្យាយាម ដើម្បីធ្វើបន្ទាល់ដល់ពួកគេនោះឡើយ ។

ក្នុងអង្គការទស្សនៈពិភពលោកឥណ្ឌា យើងបានចាប់ផ្តើមប្រើ ព័ន្ធកិច្ចគ្រប់ជ្រុងជ្រោយ **PLA** (ការចូលរួម ការហ្វឹកហ្វឺន និង សកម្មភាព) ដើម្បីនឹងធ្វើវិភាគទស្សនៈលោកិយ នៃសហគមន៍ទាំងឡាយ ផ្សេងៗ ។ ការធ្វើវិភាគនេះមានទំរង់ជាការទទួលស្គាល់ទំហំនីមួយៗ ដែលមានឥទ្ធិពលលើយុទ្ធសាស្ត្រ នៃជីវិតរស់នៅទាំងឡាយនៃសហគមន៍ និង ជីវិតនៃអ្នកស្រុករបស់ពួកគេ ។ វាគឺជាការចាំបាច់ ដើម្បីយល់ពី ឥទ្ធិពលចំៗ ដែលភាពសំខាន់ទាំងនេះ ផ្ទុកលើជីវិតរបស់ពួកគេ ។ ឧទាហរណ៍ ការស្រាវជ្រាវរបស់ពួកយើងបានបង្ហាញថា សហគមន៍ទាំងឡាយនៅក្នុងតំបន់តែមួយ មានឥទ្ធិពលត្រួតត្រាចំបងធំៗ ចំនួន បី ។



ឥទ្ធិពលទាំង ៣ នេះធ្វើឲ្យទិដ្ឋភាពនីមួយៗនៃយុទ្ធសាស្ត្រជីវិតរស់នៅមានការប្រែប្រួល ។ ឧបមាដូចជា សហគមន៍ភូមិណាមួយប្រហែល ជាពឹងលើទិដ្ឋភាពដូចខាងក្រោមនេះ ដើម្បីឲ្យរស់រានមានជីវិតបាននោះគឺ:

- ការធ្វើស្រែចំការ
- ការចិញ្ចឹមសត្វ
- ការផ្សំថ្នាំ
- ការប្រមូលផលិតផលព្រៃឈើតូចតាច
- អគ្គិសនី
- ទីផ្សារក្នុងស្រុក
- គមនាគមន៍ (ផ្លូវ)
- ផ្សេងៗទៀត

សហគមន៍មើលឃើញថា ព្រះ(ទាំងឡាយ) អ្នកខាងក្រៅ ហើយនិងពួកគេផ្ទាល់ កំពុងមានឥទ្ធិពលលើទិដ្ឋភាពទាំងនេះ ក្នុងកំរិតណាមួយ ។ នៅក្នុងករណីខ្លះ ឥទ្ធិពលប្រហែលកើតឡើងពីប្រភពតែមួយ ហើយនៅក្នុងករណីផ្សេងទៀត កើតចេញពីប្រភព ២ ឬ ទាំង ៣ តែម្តង ។ វិសាលភាពដែលឥទ្ធិពលនីមួយៗ មានផលប៉ះពាល់ដល់ចំណុចមួយនៃជីវិត នឹងប្រែប្រួលពីសហគមន៍មួយទៅសហគមន៍មួយទៀត ។ ឧទាហរណ៍: ឥទ្ធិពលផ្សេងៗលើកសិកម្មចំពោះភូមិ ៣ ខុសគ្នាដូចខាងក្រោមនេះ៖

*ទទួលឥទ្ធិពលពីព្រះ*

*ទទួលឥទ្ធិពលពីអ្នកខាងក្រៅ*

*ទទួលឥទ្ធិពលពីខ្លួនពួកគេ*



*ភូមិទី ១ (ក្បែរទន្លេ)* *ភូមិទី២(រដ្ឋាភិបាលអាចបើកឡើងនូវផែនការបញ្ចូលទឹក)* *ភូមិទី ៣ (ភ្លៀងជោក ជាំ)*

ចំណុចដែលមិនប្រាកដប្រជាខ្លាំងនោះ គឺអស់អ្នកដែលត្រូវបានកំណត់ចំពោះព្រះណាមួយ ។ ការចុះសួរសុខទុក្ខភូមិទាំងនេះនឹងបង្ហាញភាពច្បាស់លាស់ ពីសមិទ្ធិផលនីមួយៗ ដែលជាស្នាដៃរបស់ព្រះនៃទឹកភ្លៀង ។ ក្នុងភូមិទី ៣ ដែលពឹងទាំងស្រុងលើទឹកភ្លៀង ហើយឥទ្ធិពលនៃព្រះ នឹងត្រូវបានគេយល់ដឹងគ្រប់គ្នាថាជាសំខាន់បំផុត ។ ទាំងភូមិទី ១ និង ភូមិទី ២ ដែលរីករាយសប្បាយក្នុងការចូលទៅដល់ប្រភពទឹកជាជាងពឹងលើទឹកភ្លៀងនោះ ពឹងជាបន្ទាប់បន្សំលើព្រះបង្អុរភ្លៀង ប៉ុន្តែព្រះនេះនៅតែអាចឥទ្ធិពលលើភូមិ ដោយហេតុថាភ្លៀងអាចធ្លាក់ខុសរដូវ ដូចជានៅអំឡុងរដូវចំរូតជាដើម ហើយបង្ខូចកសិផលទាំងស្រុង ។

សំរាប់ទិដ្ឋភាពនីមួយៗដទៃទៀត ពីយុទ្ធសាស្ត្រនៃការរស់រានមានជីវិត ក៏រីតនៃការទទួលឥទ្ធិពលពីព្រះផ្សេងៗ ពីអ្នកដទៃ និង ខ្លួនពួកគេផ្ទាល់ នឹងអាចផ្លាស់ប្តូរស្រដៀងគ្នាពីភូមិមួយទៅភូមិមួយផ្សេងទៀត ។ ការសិក្សា នៃជាតិពន្ធនិយមនៃភូមិទាំងនេះ អាចនឹងបង្ហាញប្រាប់ក្រុមមនុស្ស ឬ ប្រវត្តិ នៃសាសនា ដូចនេះទស្សនៈលោកិយនៃព័ន្ធកិច្ចគ្រប់ជ្រុងជ្រោយរបស់ពួកគេ ពេលដែលត្រូវបានធ្វើវិភាគ អាចនឹងបង្ហាញទម្រង់ខុសគ្នាទាំងស្រុង ។ វិធីសាស្ត្រ ដែលអាចត្រូវបានប្រើសម្រាប់ការអនុវត្តន៍ ធ្វើវិភាគលើគតិលោកនៃព័ន្ធកិច្ចគ្រប់ជ្រុងជ្រោយ **(WWVA)** ត្រូវបានពិពណ៌នា លំអិតនៅក្នុង *ការបង្កើតសិស្សនៃព័ន្ធកិច្ចគ្រប់ជ្រោយ: ការវិភាគលើគតិលោក: ការថ្លឹងថ្លែងអ្វីក៏ដោយ* ដែលផលិតដោយអង្គការទស្សនៈពិភពលោកឥណ្ឌា ។

កម្រិតនៃឥទ្ធិពលនៃអ្នកមានឥទ្ធិពលម្នាក់ៗពោលគឺព្រះ, អ្នកខាងក្រៅ, ហើយនិង ពួកគេផ្ទាល់ត្រូវបានរកឃើញ ដោយការប្រើវិធីសាស្ត្រ **PLA** ដ៏មានប្រជាប្រិយនេះ ដែលមានឈ្មោះថា "វិធីសាស្ត្រគ្រាប់ ពូជ ១០ យ៉ាង" ដែលត្រូវបានអភិវឌ្ឍន៍ ដោយអ្នកនិពន្ធនឹងត្រូវបានពង្រីកដាក់ឲ្យប្រើនៅទីនេះ ដោយព័ន្ធកិច្ចគ្រប់ជ្រុងជ្រោយ ។

គតិលោកនៃសហគមន៍មួយ អាចត្រូវបានធ្វើការស្រាវជ្រាវឲ្យកាន់តែច្បាស់លាស់ លើមូលដ្ឋាននៃសមត្ថភាព និង ភាពទន់ខ្សោយរបស់សហគមន៍ ជាងសេចក្ដីជំនឿនៃសាសនា ដែលក្រុមបានលើកឡើង ។ ឧបមាថា ក្នុងភូមិ **Dighori** យើងបានសន្មត់ថា ដោយសារសហគមន៍មួយត្រូវបាន គ្របដណ្ដប់ដោយក្រុមអ្នកកាន់ព្រះពុទ្ធសាសនាបែបថ្មីភាគច្រើន សហគមន៍នឹងមានគតិលោកបែបព្រះពុទ្ធសាសនា ។ ផ្ទុយទៅវិញយើងរកឃើញថា ព្រះទាំងឡាយ និង វិញ្ញាណទាំងឡាយ ដែលមានឥទ្ធិពលលើជីវិតរបស់អ្នកស្រុកភូមិ គឺជាអស់អ្នកដែលបានគ្រប់គ្រងលើចំណុចខ្សោយទាំងឡាយរបស់ពួកគេ គឺជាព្រះដែលបានគ្រប់គ្រងទឹកភ្លៀង ជំងឺផ្សេងៗ និង សត្វព្រៃទាំងឡាយ ។ ព្រះពុទ្ធ ដែលពួកគេកាន់តាមនោះ គ្រាន់តែមានឥទ្ធិពលលើចំណុច "សន្តិភាព(សុខ)នៃគំនិត" ប៉ុណ្ណោះ ហើយប្រការនេះគឺបានឡើងដោយការសូត្រដដែលៗ ដោយទៀងទាត់តាម **"Shlokas"** (ចម្រៀងសរសើរបែបកំណាព្យ) ដែលពួកគេបានចេះចាំយ៉ាងល្អ ។ ការមានឥទ្ធិពលដ៏លើសលប់ក្នុងជីវិតរបស់ពួកគេនៅតែបានកំណត់យ៉ាងធំទូលាយ *តាមមធ្យោបាយ ដែលពួកគេមើលឃើញពីការពិត* គឺជាគតិលោករបស់ពួកគេ ។ ដូច្នេះទោះបីសហគមន៍ទាំងឡាយ ដែលប្រកាសថាជាគ្រីស្ទបរិស័ទ ប៉ុន្តែគតិលោករបស់ពួកគេគ្មានឥទ្ធិពលពីបទគម្ពីរទេ នោះគឺទំនងជាពួកគេសំអិតសំអាងពួកទេវៈទៅតាមមនោគតិរបស់ពួកគេ ។ ពួកគេធ្វើដូចនេះ គឺដើម្បីដោះស្រាយភាពទន់ខ្សោយរបស់ពួកគេ ឬ ព្យាយាមដើម្បីបង្វែរព្រះឲ្យត្រឡប់ជាអាចប្រើប្រាស់បានដោយសមរម្យ (ឧទាហរណ៍ បំពេញតួនាទី ដែលគិតពីផលប្រយោជន៍ផ្ទាល់ខ្លួន) ។ ជំហានដំបូង ក្នុងការបង្កើតសិស្សព័ន្ធកិច្ចគ្រប់ជ្រុងជ្រោយគឺ យល់ឲ្យច្បាស់លាស់ជាមុនពីគតិលោក ហើយបន្ទាប់មកចាប់ផ្ដើម ដំណើរនៃការបង្កើតសិស្ស ។

## ដំណើរការនៃការបង្កើតសិស្ស

ដំណើរការបង្កើតសិស្សខ្លះ ផ្លាស់ប្តូរតែ *អាកប្បកិរិយា* ហើយដទៃទៀតផ្លាស់ប្តូរ *អាកប្បកិរិយា* និង *ជំនឿ* ប៉ុន្តែទុកគតិលោកនៅដដែល ។ ហេតុនេះហើយ បានជាគតិលោកក្លាយទៅជាមានឥទ្ធិពលលើសលុប និង គ្របសង្កត់លើយ៉ាងខ្លាំង ។

ក្នុងគំនូសតាង ដែលជាកំណែប្រែយកលំនាំតាមលោក **Heibert** និង **Dyness** នោះចំណុចខាងក្រៅគេបង្អស់ គឺជាអាកប្បកិរិយា ។ នេះគឺជាការមួយ ដែលងាយនឹងផ្លាស់ប្តូរបំផុត ដោយឥទ្ធិពលខាងក្រៅ ។ នៅក្នុងអាកប្បកិរិយាមានផ្នែកដ៏ជ្រៅនៃជំនឿ ដែលត្រូវការបញ្ចុះបញ្ចូលឲ្យយល់ជ្រួតជ្រាបខ្លាំង មុននឹងទទួលយកការផ្លាស់ប្តូរណាមួយ ។ ទោះបីជាយ៉ាងណាក៏ដោយ ចំណុចកណ្តាលនៃការគ្រប់គ្រង គឺជាគតិលោក ។ បើសិនជាគតិលោកមួយមិន *ត្រូវបានយល់* មិន*ត្រូវបានធ្វើការវិភាគ ហើយមិនបានត្រូវបានបង្កើតសិស្ស* ដោយសមរម្យត្រឹមត្រូវទេនោះ គឺតាមរយៈការខកខាននេះ ការពិតទាំងឡាយនឹងបែរត្រឡប់ទៅរកសភាពការណ៍ដើមជាប្រពៃណីវិញ ។ ហេតុដូច្នេះពេលឥទ្ធិពលខាងក្រៅសំរាប់ធ្វើការផ្លាស់ប្តូរ ត្រូវបានដកថយ នោះគតិលោក ដែលមិនបានបង្កើតសិស្ស និងគ្រប់គ្រងបន្ត ហើយធ្វើឲ្យអ្វីៗត្រឡប់ទៅរកសភាពដើមវិញ ។

យុទ្ធសាស្ត្រនៃការរស់រានមានជីវិតទាំងមូល មានសកម្មភាពផ្សេងៗគ្នា ដែលសហគមន៍ទទួលរ៉ាប់រង ដើម្បីនឹងទ្រទ្រង់ពិភពលោករបស់ខ្លួន ។ ទាំងនេះនឹងមានទិដ្ឋភាពផ្សេងៗគ្នា ដូចដែលបាននិយាយរួចមកហើយ ។ អ្វីដែលនៅក្នុងការគ្រប់គ្រង ដោយផ្ទាល់របស់ពួកគេ ត្រូវបានឃើញជាសមត្ថភាព ហើយអស់ទាំងការដែលនៅក្រោមការគ្រប់គ្រង ដោយប្រយោល គឺត្រូវបានឃើញជាភាពទន់ខ្សោយ ទោះបីជាយ៉ាងណាក៏ដោយ ដំណើរការដែលមិនអាចវែកញែកដាច់ពីគ្នាបាន នៅតែមានជានិច្ច រវាងការគ្រប់គ្រងដោយផ្ទាល់ និង ការគ្រប់គ្រងដោយប្រយោល គឺរវាង ការសំអាងលើពិសោធន៍ និង អធិធម្មជាតិ ។




ដូច្នេះពេលណាដែលទីភ្នាក់ងារអភិវឌ្ឍន៍រកឃើញអ្វី ដែលជា "តំបន់នៃភាពទន់ខ្សោយ" នោះពិត គឺវាពិតជាស្ថិតនៅក្នុងប្រស្រីភ្នែករបស់សាមីសហគមន៍ ជាចំណុចមួយក្នុងការគ្រប់គ្រង ដោយប្រយោលរបស់គេ ។ ដូច្នេះគោលបំណងនៃទីភ្នាក់ងារអភិវឌ្ឍន៍ ដើម្បីធ្វើអន្តរាគមន៍ត្រូវបាន មើលឃើញថាជាជម្លោះជាមួយនឹងវត្តមាន នៃការដែលកំពុងគ្រប់គ្រង ដោយអធិធម្មជាតិ ។




**ការធ្វើវិភាគគតិលោកនៃព័ន្ធកិច្ចគ្រប់គ្រងជ្រោយអំពីសហគមន៍មួយ**

នៅក្នុងការវិភាគយុទ្ធសាស្ត្រ នៃការរស់រានមានជីវិតរបស់សហគមន៍ គេធ្វើកំណត់សំគាល់អំពីភាពខាងក្រៅនៃព្រះ ដែលក្នុងនោះទ្រង់បានជួយតែ ក្នុងវិស័យនៃភាពមិនពិតប្រាកដប៉ុណ្ណោះ ។ នៅពេលដែលរង្វង់នៃឥទ្ធិពលរបស់សហគមន៍ គ្រប់គ្រងបរិដ្ឋានរបស់វារីកកាន់តែធំទូលំទូលាយ ចូលទៅក្នុងប្រភពធនធាន និង ការបង្កើតឡើងនូវជំនាញផ្សេងៗ (បង្កើនសមត្ថភាពផ្សេងៗ) គេអាចនឹងមើលឃើញដោយពិតប្រាកដថាព្រះត្រូវ បានផាត់ចេញពីទិដ្ឋភាពពិសេសនេះ ។ ដូច្នេះភ្នាក់ងារអភិវឌ្ឍន៍មួយ ដែលមិនបានទទួលស្គាល់ការពិត ដូចដែលសហគមន៍បានឃើញទេនោះ គឺអាចនឹងបណ្ដាលឲ្យខូចខាតជាពិតប្រាកដចំពោះគតិលោក ដែលជាការធ្វើឲ្យសហគមន៍ កាន់តែមិនទទួលស្គាល់ព្រះជាម្ចាស់ ។ ប្រហែលជាការនេះ ផ្ដល់ឲ្យយើងនូវការយល់ដឹងដ៏ធំធេងទៅក្នុងអ្វី ដែលបានកើតមានឡើង ចំពោះសហគមន៍លោកខាងលិចដែលបានអភិវឌ្ឍយុទ្ធសាស្ត្រ នៃការរស់រានមានជីវិត ហើយបាននាំមកកាន់តែច្រើននូវភាពមិនប្រាកដប្រជា ទៅក្នុងការគ្រប់គ្រង របស់ពួកគេ

ដូច្នោះការនេះបានរុញច្រានព្រះចេញពីតួនាទីយ៉ាងសកម្ម នៅក្នុងជីវិតរបស់ពួកគេ ។

ព័ន្ធកិច្ចគ្រប់ជ្រុងជ្រោយ **PLA** ក៏ជួយយើងឲ្យដឹងផងដែរ ពីរបៀបដែលសហគមន៍យល់ដឹងពីសារដែលយើងប៉ុនប៉ង និង ផ្សព្វផ្សាយនោះ ។ ឧទាហរណ៍នៅក្នុងភូមិ **Gohekurd** យើងបានរកឃើញថាគំនិតយល់ដឹងរបស់សហគមន៍ ក្នុងការឈោងទៅជិតព្រះ គឺខុសប្លែកពីអ្វីដែលបុគ្គលិកអង្គការទស្សនៈពិភពលោកកំពុងធ្វើការងារតាមគំរោង ។

ព្រះមានអំណាចកាន់តែខ្លាំង គឺទ្រង់ត្រូវគេទាក់ទងកាន់តែតិច ។ ហើយពេលនោះមិនអាចទាក់ទងបាន ដោយសារបុគ្គលឡើយ តែដោយសារភូមិមួយទាំងមូល ឬ ភូមិច្រើនរួមគ្នាវិញ ។ តាមរយៈប្រព័ន្ធនៃជំនឿបែបនេះ បុគ្គលិកអង្គការទស្សនៈពិភពលោក កំពុងតែនិយាយអំពីព្រះមួយអង្គ ដែលបានធ្វើអន្តរកម្មជាមួយបុគ្គលម្នាក់ៗ តាមកម្រិតផ្ទាល់ខ្លួនរបស់គេ ហើយដែលទ្រង់ពិតជា "ឈរនៅមាត់ទ្វារហើយគោះ" (វិវរណៈ ៣:២០) ។ ប្រការនេះ គ្មានអត្ថន័យចំពោះពួកគេទេ ដ្បិតពួកគេបានគិតថា ព្រះអង្គ "តូចពេក" មិនសក្តិសមសំរាប់ពួកគេដើរតាមឡើយ ។

ភាពកំសោយដ៏ធំមួយទៀត ក្នុងការដោះស្រាយរបស់យើង គឺថាយើងមិនបានចូលទៅចំពោះមនុស្សដូចជាសហគមន៍ចូលទៅនោះទេ គឺយើងហាក់បីដូចជា ក្រុមមនុស្ស ដែលត្រូវបានតម្រង់ទៅតាមខ្សែបណ្តោយ (តាមឋានានុក្រម) ។ គំនិតដ៏រឹងមាំក្នុងភាពជាសហគមន៍មួយ ដែលមាន *ការទំនុកបំរុងដ៏រស់រវើក ទាក់ទងនឹងអន្តរកម្ម* គឺមិនត្រូវបានឃើញនៅក្នុងយើងទេ ។ ដូច្នេះកម្រិតអន្តរកម្មរបស់សហគមន៍ជាមួយអង្គការទស្សនៈពិភពលោក គឺជាមួយនឹង "បុគ្គលផ្សេងៗ ដែលពួកគេបានជួប" ជាជាងជាមួយសហគមន៍គ្រីស្ទបរិស័ទ ។ ទម្រង់ (ស្ថាន) នៃបុគ្គលម្នាក់ៗ ដែលពួកគេធ្វើអន្តរកម្មជាមួយ មានតួនាទីដ៏ចំបងមួយ ។ ដូច្នេះពួកគេអាចមានតួនាទី តែនៅក្នុងក្រុមពិសេសណាមួយរបស់គេតែ

ប៉ុណ្ណោះ ។ ប្រការនេះគឺ ពិសេសខ្លាំងណាស់នៅក្នុងតំបន់ជនបទនៃ **Maharashtra** និង **Karnataka** ដែលវណ្ណៈដើរតួនាទីគ្របដណ្តប់យ៉ាងខ្លាំង ។ ដោយសារឈ្មោះរបស់មនុស្ស បង្ហាញពីវណ្ណៈរបស់ពួកគេនោះ ទើបមានកម្លាំងមួយដ៏ខ្លាំងលើសលប់ ការជះឥទ្ធិពលលើសហគមន៍ ។ ការផ្លាស់ប្តូរឈ្មោះទាំងស្រុង (ដែលយកលំនាំតាមឈ្មោះ អង់គ្លេស ឬ "គ្រីស្តបរិស័ទ") ត្រូវបានគេសន្និដ្ឋានថា ធ្វើឡើងដើម្បីគ្របដណ្តប់លើវណ្ណៈតូចទាប ពីព្រោះលក្ខណៈ និង របៀបនៃការនិយាយ វាក្យត់នឹងភាពដើមនៃបុគ្គលម្នាក់រួចទៅហើយ ។

ឧបសគ្គចម្បងមួយ សម្រាប់ការប្រាស្រ័យទាក់ទង គឺការប្រកាន់ប្រព័ន្ធវណ្ណៈខ្លាំងក្លាពេក ។ លើកលែងតែនៅក្នុងតំបន់កុលសម្ព័ន្ធ ការប្រកាន់វណ្ណៈ បានជះឥទ្ធិពលយ៉ាងខ្លាំង នៅផ្នែកជនបទដ៏ធំធេងនៃរដ្ឋ **Maharashtra, Gujarat** និង **Karnataka** ។ ឧទាហរណ៍នៅក្នុងតំបន់ **Vidharba** នៃរដ្ឋ **Maharashtra** ដែលនៅទីនោះមានភូមិខ្លះ បុគ្គលិកមួយចំនួនរបស់យើង គ្មានឥទ្ធិពលអ្វីទាល់តែសោះ ពីព្រោះតែភាពដើម និង ប្រវត្តិគ្រួសាររបស់គេ ។

គេនិយាយថា វប្បធម៌ជាការជាក់ស្តែង ដែលធ្វើឲ្យប្រាកដអំពីដំណើរបន្តនៃការអនុវត្តន៍មួយ ។ ពេលនោះវណ្ណៈគឺជាមូលដ្ឋាន ដែលផ្តល់ការអនុវត្តន៍លើក្របខ័ណ្ឌរបស់វា ។ ការបំពេញការងារនៅក្នុងក្របខ័ណ្ឌនេះ កំណត់ប្រសិទ្ធិភាពនៃដំណើរការអភិវឌ្ឍន៍បំផ្លាស់ប្រែ ។ តែនេះជា *ការពិត* ដែលគេត្រូវតែទទួលស្គាល់ថា សហគមន៍ជាបំណែកមួយដែរ ។

ឯមូលដ្ឋាននៃការប្រកាន់ពូជសាសន៍ គឺជាអាកប្បកិរិយាដូចជាការមើលឃើញក្នុងឌីយ៉ាក្រាមភ្ជាប់មកនេះ ។ អាកប្បកិរិយារបស់សហគមន៍ ចំពោះហេតុការណ៍ពិសេសណាមួយ គឺជាលទ្ធផលបុរេនិច្ឆ័យ ។ អាកប្បកិរិយាដ៏ខ្លាំងក្លានេះ អាចមានប្រវត្តិសាស្ត្រមួយនៅពីក្រោយវាហើយ អាចជាលទ្ធផលនៃសេចក្ដីលំអៀង ដែលទាស់ប្រឆាំងយ៉ាងខ្លាំង ឬសំរាប់ជំហរពិសេសនេះ ។ នៅក្នុងថេរៈវេលាដ៏សមគួរ អាកប្បកិរិយានេះ គឺជាការបង្ហាញឲ្យឃើញនៅក្នុងទំរង់នៃកាប្រកាន់ពូជសាសន៍ និង ធ្វើឲ្យការអនុវត្តន៍នៃវប្បធម៌មានរូបរាងឡើង ដែលផ្ដល់ឲ្យសហគមន៍ នូវហេតុផលដ៏ត្រឹមត្រូវល្អ សម្រាប់ជំហរពិសេសរបស់ពួកគេ ។




ដូច្នេះការផ្លាស់ប្ដូរត្រូវកើតឡើងក្នុង កំរិតអាកប្បកិរិយា មុនពេលដែលយើងអាចយកឈ្នះបុរេនិច្ឆ័យ (ការលំអៀង) ឬ ផ្លាស់ប្ដូរការប្រកាន់ពូជសាសន៍ ។ សាវតាប្រវត្តិសាស្ត្រពិសោធន៍នៃសហគមន៍មួយមានតួនាទីយ៉ាងសំខាន់ ក្នុងការរៀបចំអាកប្បកិរិយារបស់ខ្លួន ដូច្នោះ *ការស្ដាប់ និង ការរុករកប្រវត្តិសាស្ត្ររបស់ពួកគេ* គឺជាការសំខាន់ ប្រសិនបើយើងចង់ចាប់ផ្ដើមយល់នូវអ្វី ដែលជាអាកប្បកិរិយារបស់ពួកគេ ។

សង្ខេបនូវការពិភាក្សាទាំងឡាយ ដែលមានរហូតមកដល់ពេលនេះ៖

១. ការយល់ការពិតរបស់សហគមន៍ "ដូចជាពួកគេយល់អំពីវា "នោះគឺជាការចាំបាច់សម្រាប់ការធ្វើបន្ទាល់របស់ គ្រីស្ទបរិស័ទដ៏មានប្រសិទ្ធិភាព ។ ចូរបញ្ជាក់ផ្សេងៗគ្នា ពីអ្វីដែលជាការពិតរបស់ពួកគេ ។

២. បទពិសោធន៍ពីការប្រើព័ន្ធកិច្ចគ្រប់ជ្រុងជ្រោយ PLA របស់យើងបាន បង្ហាញយើងថាពេលយើងចាប់ផ្ដើមស្ដាប់ពីសហគមន៍ និង ព្យាយាម យល់ពីការពិតរបស់ពួកគេ នោះមានន័យថា យើងស្វែងរកមើលពី គតិលោករបស់ពួកគេ ដែលខុសគ្នាយ៉ាងខ្លាំង ពីអ្វីដែលយើងសង្ឃឹម ចង់បាន ។ ជាញឹកញាប់ពួកអ្នក ដែលមានទំរង់ជាតិពន្ធស្រដៀងគ្នា នេះ មានគតិលោកបែកចេញពីគ្នា ហើយការនេះ គឺដោយព្រោះតែបទ ពិសោធន៍ប្រវត្តិសាស្ត្ររបស់ពួកគេ ។

៣. សហគមន៍ទាំងឡាយ ចាំបាច់ត្រូវបានផ្ដល់អំណាចក្នុងការចែកចាយពី គតិលោករបស់ពួកគេ គឺការនិយាយប្រាប់រឿងរ៉ាវរបស់ពួកគេ ។ រឿង នេះមានការពាក់ព័ន្ធនឹងការប្រើដំណើរការសកម្មជាងមុន ដូចជាព័ន្ធ កិច្ចគ្រប់ជ្រុងជ្រោយ PLA ដែរ ។

៤. សហគមន៍ទាំងឡាយមានគំនិតយល់ដឹងច្បាស់លាស់ និង មាន អានុភាព ដែលទាក់ទងទៅនឹងកាលៈទេសៈ ហើយនិងបញ្ហាដែលគេ ប្រឈមមុខ ។ ពួកគេត្រូវតែជួយសម្រួលក្នុង ការបង្ហាញការយល់ដឹង របស់ពួកគេអំពីបុព្វហេតុ និង អានុភាពនៃបញ្ហា ដែលជះឥទ្ធិពលលើ យុទ្ធសាស្ត្រនៃការរស់រានមានជីវិតរបស់ពួកគេ ។

៥. ជាចុងក្រោយ ប្រសិទ្ធិភាពរបស់យើងក្នុងការយល់ដឹងពីការពិតរបស់ សហគមន៍ ត្រូវពឹងផ្អែកលើរបៀប ដែលយើងអាចបង្កើត *ការផ្លាស់ ប្ដូរគំរូ* ក្នុងការឈោងចាប់របស់យើង ឲ្យបានបើកចំហ និង ឲ្យកាន់តែ យល់ដឹងច្រើនថែមទៀត ។

**គំណត់សំគាល់ខ្លីមួយលើព័ន្ធកិច្ចគ្រប់ជ្រុងជ្រោយ PLA**

PLA ត្រូវបានប្រើដោយជោគជ័យក្នុងរង្វង់នៃការអភិវឌ្ឍន៍ជា ច្រើនឆ្នាំ ។ ឥឡូវនេះ PLA បានចាប់ផ្ដើមមានការរីកចំរើននៅតាមទីភ្នាក់ ងារអភិវឌ្ឍន៍ធំៗ និង ស្ថាប័នរដ្ឋាភិបាល ។ វាបានរកឃើញការអនុវត្តន៍ដ៏ ធំទូលាយសម្រាប់បង្កើតឡើងនូវ ការយល់ឆ្លុះថ្មីទៅក្នុងជួរនៃប្រធាន

បទផ្សេងៗដូចជា ប្រជាសាស្ត្រ ការអប់រំសុខភាព កសិកម្ម ការកាប់បំផ្លាញព្រៃឈើ ការអភិវឌ្ឍន៍សហគមន៍ ដោយរួមបញ្ចូលជនបទ និងទីក្រុង ដំណើរការសង្គ្រោះ និង ការអភិវឌ្ឍន៍ កម្មវិធីកុមារ ការជួយគំនិតអាពាហ៍ពិពាហ៍ ការយល់ដឹងអំពីអេដស៍ AIDS, BCC (ការប្រាស្រ័យទាក់ទង ផ្លាស់ប្តូរអាកប្បកិរិយា) ។ល។

ថ្មីៗនេះ វិធីសាស្ត្រដើមដំបូងនៃ PLA ត្រូវបានបញ្ជាក់ និងពង្រីកទៅហួសការដែលសំអាងលើបទពិសោធន៍ ដើម្បីសំរួលដល់ការយល់ដឹងដ៏ប្រសើរពីអធិធម្មជាតិនោះ ។ ទោះបី PLA ជានិច្ចកាលមានសក្តានុពល ដូច្នេះក៏ដោយ ក៏វិធីសាស្ត្របានស្ថិតនៅជាទូលំទូលាយហើយនៅតែមានព្រំដែន ក្នុងការប្រើតាមមធ្យោបាយលោកិយ ដើម្បីស្វែងយល់ពីការសំអាងលើបទពិសោធន៍ប៉ុណ្ណោះ ។

អង្គការទស្សនៈពិភពលោកឥណ្ឌា បានអនុវត្តការងារត្រួសត្រាយផ្លូវខ្លះក្នុងរឿងនេះ និង បានពង្រីកទំហំរបស់ខ្លួន ដើម្បីឲ្យវាអាចត្រូវប្រើផងដែរ នៅក្នុងការអនុវត្តន៍ ការវិភាគគតិលោកនៃព័ន្ធកិច្ចគ្រប់ជ្រុងជ្រោយ និង ដើម្បីប៉ាន់ប្រមាណ អ្វីដែលជាបញ្ហាក្នុងការធ្វើទីបន្ទាល់របស់គ្រីស្តបរិស័ទ ។ បុរេល័ក្ខខ័ណ្ឌនៅតែមានដដែល ជាមួយនឹងគំរោង PLA ដទៃៗទៀត ឧទាហរណ៍ ការផ្លាស់ប្តូរអាកប្បកិរិយា ដែលជាការចាំបាច់នៅក្នុងអ្នកហ្វឹកហាត់ ។

ទំហំសំរាប់ការប្រើព័ន្ធកិច្ចគ្រប់ជ្រុងជ្រោយ PLA នៅក្នុងអង្គការទស្សនៈពិភលោកមានលក្ខណៈទូលំទូលាយ ហើយអាចឃើញការប្រើជាសាកលក្នុងកម្មវិធីអភិវឌ្ឍន៍តំបន់របស់យើង ។ នៅចុងបញ្ចប់នៃលំហាត់ចុងក្រោយ ដែលគំនូសតាងវិភាគលើគតិលោកត្រូវបានបញ្ចប់មានទំហំសំរាប់យើងយកមកពិភាក្សាជាមួយនឹងសហគមន៍ ក្នុងការសន្ទនាជាអន្តរកម្មនូវអ្វីដែលជាការប៉ាន់ស្មានរបស់ពួកគេអំពីព្រះជាម្ចាស់ដ៏គ្រប់ល័ក្ខណ៍ ដែលទ្រង់អាចនឹងមានលទ្ធភាពដោះស្រាយគ្រប់ទាំងទិដ្ឋភាព នៃជីវិត

របស់ពួកគេ: (ក)ជួយពួកគេឲ្យក្លាយជាអ្នកកាន់កាប់សមត្ថភាពរបស់ពួកគេបានល្អប្រសើរនិង (ខ) ជួយពួកគេឲ្យទទួលបានអំណាចដើម្បីដោះស្រាយនូវភាពទន់ខ្សោយ របស់ពួកគេយ៉ាងមានប្រសិទ្ធិភាព ។

ព័ន្ធកិច្ចគ្រប់ជ្រុងជ្រោយនេះ មានដំណើរការយ៉ាងសំខាន់ ក្នុងការនាំព្រះទៅក្នុងវិស័យ នៃសមត្ថភាពរបស់ពួកគេ ផ្នែកនៃវិធីសាស្ត្រនៃការរស់រានមានជីវិត ដែលនៅក្នុងការគ្រប់គ្រងរបស់គេ ហើយនិងរួមបញ្ចូលជាមួយគ្នា គ្រប់ទាំងផ្នែកតូចៗជាច្រើនទៀត នៃតម្រូវការព្រះឲ្យនៅកន្លែងតែមួយ (មានផ្នែកផ្សេងៗត្រូវបានបង្រួបបង្រួម) ។ ការនេះជាជំហានទី ១ ក្នុង ការបង្ហាត់បង្រៀន ពីគតិលោករបស់គេ ។ ជំហានទី ២ គឺជាការរួមបញ្ចូល ថែមទៀត (ការរួមបញ្ចូលឆ្ពោះទៅរកមជ្ឈមណ្ឌល) ដើម្បីបង្ហាញថា គឺព្រះ ជាម្ចាស់តែមួយ ដែលដោះស្រាយភាពទន់ខ្សោយ និង សមត្ថភាពរបស់ពួកគេ ។

ក្នុងខណៈដែលមធ្យោបាយនៃការដោះស្រាយទាំងអស់នេះហាក់បីដូចជាមានភាពរំភើប និងមានការសន្យាពីការរកឃើញដ៏ធំមួយ ក៏ជាការពិតនៅតែដដែលថានឹងមានការប្រឆាំងទាស់ជាច្រើន ចំពោះការធ្វើអ្វីមួយផ្សេងពីនេះ ។ កិច្ចការប្រភេទនេះអាចនាំឲ្យយើងមានការភ័យខ្លាច ព្រោះវាតម្រូវឲ្យយើងមានការប្រុងប្រៀបទុកជាមុន។ វាតម្រូវឲ្យយើងមានសុឆន្ទៈល្អ ក្នុងការឆ្លើយឆ្លងគ្នាដោយចំហ ដែលយើងអាចនឹងមិនបានប្រុងប្រៀបសម្រាប់ការនេះ ។ ទោះជាយ៉ាងណាក៏ដោយប្រសិនបើយើងមានឆន្ទៈធ្វើការផ្លាស់ប្រែហើយយើងធ្វើតាមអ្វីដែលព្រះយេស៊ូទ្រង់មានបន្ទូលអំពីគ្រាប់ពូជមួយ ដែលធ្លាក់ហើយងាប់ មុនពេលវាចេញពន្លក បែកមែកលាស់ស្លឹកហើយទីបំផុតផ្តល់នូវផលផ្លែ នោះខ្ញុំជឿថាយើងកំពុងចាប់ផ្តើមនៃការចាប់ផ្តើមថ្មីមួយនៅក្នុងជីវិតរបស់យើង ! ។

●●● † ●●●

*"ចូរប្រកាសដំណឹងល្អគ្រប់ពេលវេលា បើសិនជាការចាំបាច់ ចូរប្រើព្រះបន្ទូលចុះ"*

**St. Francis of Asisssi .**

*"ចូរប្រយ័ត្នពីរបៀប ដែលអ្នករស់នៅ ។ អ្នកប្រហែលជាព្រះគម្ពីរតែមួយគត់ ដែលអ្នកផងមើលគំរូរបស់អ្នកជានិច្ច"*

អ្នកនិពន្ធអនាមិក

---

យកលំនាំតាមការស្រាវជ្រាវមួយដែលសរសេរដោយ បណ្ឌិត **Ravi I Jayakaran** អំឡុងពេលគាត់ធ្វើការជាមួយអង្គការទស្សនៈពិភពលោក ប្រចាំនៅ ឥណ្ឌា ។

HONEYCOMB 2/1 (January 2001): 26–31

# Intercession

*Ian WEBBER*

**An eyewitness tells Luke what he recalls of the Last Supper**

"It was a night of mixed emotions I have to tell you, Luke—that Passover Meal. First of course there was a note of celebration in this annual reminder of Yahweh's Great Deliverance of us His people.[1] But there was also a sense of unease in that upper room. It flowed back and forth among those who were gathered there, and kept surfacing. I knew Jesus was aware of it, too. Undoubtedly it was brought on to some extent by the tensions that were always simmering just below the surface in Israel. We knew we were slaves again—not in Egypt this time, but here in our own land. Not under Pharaoh, but now under Caesar.

"Our own personal well-being was also threatened. Pressure was building among the Temple leaders to squash the Master's influence. Much had occurred, even in just the last few weeks, that seemed to point to something quite dangerous. I've

[1]Exodus 3:7.

already told you about some of these things, you'll remember, Luke.[2]

"There was something else too—an argumentativeness that was disturbing our time. In the squabbling and boasting in which we were caught up, our fellowship had suddenly become fragile. Jesus quite properly rebuked us, and we were all chastened—but the sour note lingered around the table. It was a somewhat 'uneasy truce' for a few of us who wanted to continue pushing our own claims to be considered 'the greatest.' I have to say that Peter was in this group! But so, I'm ashamed to admit, was I.

"Then we come to what is for me the most disturbing element of the entire meal. Simon was still urging *his* claim to the top spot in the list. He had stopped listening to what Jesus was saying. He was deaf to the Master's words—insensitive to the Lord's exhortation. He was ignoring Him. Then Jesus brings Peter, and the rest of us, up with a jolt. "Simon! Simon!" He doesn't shout, or even raise His voice. But we *all* hear him. The whole room is suddenly very, very still.

"Simon often talks more than he listens, I've noticed. But now, with everyone else around the table, he is most certainly in the 'listening mode.' And the chilling announcement falls from Jesus' lips that we are and will be in great spiritual danger—Satan's testing ('assault' might be a better term) is imminent!

"What is so terribly frightening is that Satan can challenge God, and that it will be up to us to stay faithful. Perhaps even more unnerving is that the main responsibility for holding us faithful will rest on Peter! Peter, for goodness' sake! Well, that certainly sobered him, I remember. The one thing that provided a glimmer of hope (a strong note of hope, actually) was Jesus' assurance that He had already interceded. Every single one of us knew that He would continue to do so.

"My throat was dry. I reached across to take a sip of wine. In my mind's eye I saw the winnower at work—the grain scooped

---

[2]Luke 22:15; 21:12; 20:46a; 19:41; 17:24; 14:24; 13:31, 17; etc.

up and thrown into the air, and a strong wind separating forever the chaff from the grain. . . ."

That is how I told Dr. Luke my version of what that last supper was like, when he was researching for his "orderly account." It is as vivid to me now as it was that night so long ago.

## A great promise

In this article I want to focus on Jesus' words to Peter (after He had gotten Peter's attention) and to the rest of us as well. Peter—who had lapsed into a "Simon" during the meal—is in effect designated the leader for at least the coming crisis. The ugly infighting prior to Jesus' rebuke was both so unnecessary and so demeaning. The Lord assured His disciples that He had interceded for Peter. They surely understood that He would continue to do so, and that by implication they too were included in this. For Peter specifically, His prayer of intercession was for "The Rock."

All this was surely of great encouragement to them (as it is for us) even though they all faltered shortly thereafter (as we often do). And of course the wonderful promise enshrined in Scripture[3] remains certain for us that we might be courageous (given fresh 'heart') in the face of every trial, every temptation, every problem.

## Partnership

ហេតុនេះ តាំងពីដើមដំបូងរៀងមក ក្នុងគម្ពីរកិច្ចការគ្រីស្ដទូតក្ដី យើងអាចសង្កេតឃើញថា គ្រីស្ដបរិស័ទយកចិត្តទុកដាក់ និងបំពេញភារកិច្ចពីរយ៉ាង គឺ គេប្រកាសដំណឹងល្អស្ដីពីការសង្គ្រោះដោយសារព្រះយេស៊ូ ហើយបង្ហាត់បង្រៀនអ្នកជឿឲ្យធ្វើជាសាវ័ក ។ ឧប. ក្រោយពីលោកសីលា ប្រកាសដំណឹងល្អ អំពីព្រះគ្រីស្ដមានព្រះជន្មរស់ឡើងវិញ លោក *"ពន្យល់បញ្ជាក់ និង ដាស់តឿនគេ ដោយពាក្យពេចន៍ជាច្រើន ទៀត"* (កិច្ចការ ២:៤) ។ គ្រីស្ដបរិស័ទដើមដំបូង *"ព្យាយាមស្ដាប់សេចក្ដីបង្រៀនរបស់ក្រុមគ្រីស្ដទូត ព្យាយាមរួមរស់ជាមួយគ្នា . . . និងព្យាយាមអធិដ្ឋាន"* (កិច្ចការ ២:៤២) ។ លោក ប៉ូល ប្រែចិត្តជឿលើព្រះយេស៊ូ ដែលគាត់បៀតបៀនធ្វើបាបនោះ ទទួលការអប់រំពីលោកអណាញ៉ាស រួចទទួលពិធីជ្រមុជទឹក (កិច្ចការ ៩:៥; ១៧-១៩) ។

នៅសតវត្សទី ២ ដល់ទី ៤ នៃគ្រីស្ដសករាជ គ្រីស្ដបរិស័ទមានចំនួនដ៏តិចតួច ហើយត្រូវរដ្ឋអំណាចបៀតបៀនធ្វើបាបទៀតផង ។ ហេតុនេះ ព្រះសហគមន៍របស់ព្រះគ្រីស្ដបរិស័ទ យកចិត្តទុកដាក់ជាខ្លាំង ដើម្បីបង្ហាត់មនុស្សពេញវ័យឲ្យទៅជាគ្រីស្ដបរិស័ទ ។ មានលោក ទែរតូលីយ៉ាំង (គ.ស ១៥០) លោកង៉ូរីសែន (គ.ស ១៨០) លោកស៊ីព្រីយ៉ាំង (គ.ស ២៥០) ជាបុព្វបុរស ដែលមានឈ្មោះល្បី ក្នុងការបង្ហាត់មនុស្សឲ្យទៅជាគ្រីស្ដបរិស័ទ ។ ក្រោយមក ដោយរដ្ឋអំណាចក្លាយទៅជាកាន់គ្រីស្ដសាសនា គ្រីស្ដបរិស័ទមិនសូវយកចិត្តទុកដាក់ប្រកាសដំណឹងល្អ និងបង្ហាត់មនុស្សពេញវ័យទេ ហើយគ្រាន់តែនាំគ្នាធ្វើអគ្គសញ្ញាជ្រមុជទឹកឲ្យកូនក្មេង ដែលទើបនឹងកើតតែប៉ុណ្ណោះ ។ នៅឆ្នាំ ១៩៦៣ អស់លោកអភិ

បាលព្រះសហគមន៍កាតូលិក ជួបជុំគ្នាជាមហាសន្និបាតវ៉ាទីកង់ទី ២ អស់លោកបានសម្រេចនឹងបង្ហាត់មនុស្សពេញវ័យឲ្យទៅជាគ្រីស្តបរិស័ទ តាមរបៀបពីបូរាណមក ។ របៀបនេះ ស្របនឹងកាលៈទេសៈរបស់ប្រទេសកម្ពុជា ដែលមានគ្រីស្តបរិស័ទមួយចំនួនតូច ហើយប្រជាជនភាគច្រើនកាន់ពុទ្ធសាសនា ដែលមានជំនឿប្លែកពីគ្រីស្តសាសនាយ៉ាងខ្លាំង ។

ធម្មតា ព្រះសហគមន៍កាតូលិក គ្មានការប្រញាប់នឹងធ្វើពិធីជ្រមុជទឹកឲ្យអ្នក ដែលសុំស្គាល់ព្រះយេស៊ូ ដែលធ្លាប់អប់រំគេ តាមដំណាក់កាលបួននេះទេ៖

១- *ការប្រកាសដំណឹងល្អដើមដំបូង (first evangelisation)*
២- *ការបង្ហាត់បង្រៀនឲ្យទៅជាសាវ័ក (catechumenate)*
៣- *ការរៀបចំខ្លួន និង ទទួលអគ្គសញ្ញា[២] ជ្រមុជទឹក និង ព្រះកាយ ព្រះគ្រីស្ត*
៤- *ពន្លក (neophyte) ស្វែងយល់អំពីជីវិតថ្មី ដែលខ្លួនបានទទួល (mystagogy)*

## ១- ដំណាក់កាលទី ១ ការប្រកាសដំណឹងល្អ

គ្រីស្តបរិស័ទគ្រប់ៗរូបមានភារកិច្ចដ៏សំខាន់ គឺប្រកាសដំណឹងល្អស្ដីអំពីការសង្គ្រោះ ដោយសារព្រះយេស៊ូ ដូចគ្រីស្តទូត ប៉ូល ថែងថា *"ប្រសិនបើខ្ញុំមិនផ្សាយដំណឹងល្អទេ សូមឲ្យខ្ញុំទៅវេទនាចុះ!"* (១កូរិនថូស ៩:១៦) ។ នេះជាភារកិច្ចមួយ ដែលយើងម្នាក់ៗ *"ត្រូវតែធ្វើ ដោយខានមិនបាន"* ។ ប្រសិនបើយើងបានទទួលស្គាល់ផ្លូវ ដែលផ្តល់សេចក្តីសុខសាន្តដល់ខ្លួន យើងត្រូវតែចែករំលែកដល់អ្នកដទៃ យើងមិនអាចលាក់

---

*[២] អគ្គសញ្ញា គឺសញ្ញាដ៏ប្រសើរ ដូចជាពិធីជ្រមុជទឹកជាដើម ជាពិធីមួយបង្ហាញបញ្ជាក់ជំនឿរបស់អ្នកទទួល និង បញ្ជាក់ថា ព្រះជាម្ចាស់ប្រោសប្រណីដល់មនុស្សមែន ។*

ទុកសម្រាប់តែខ្លួនឯងទេ! ។ យើងប្រកាសដំណឹងល្អតាមរបៀបផ្សេងៗ ដោយទៅសួរសុខទុក្ខគេ ដោយយកចិត្តទុកដាក់នឹងការរស់នៅរបស់គេ ដូចព្រះយេស៊ូ ដែលយកចិត្តទុកដាក់នឹងជីវភាពអ្នកស្រុក ។ យើងនិយាយសន្ទនាជាមួយគេ និង រិះគិតជាមួយគេអំពីសាសនារបស់ខ្លួនថា តើគេចង់បានអ្វី? គេយល់យ៉ាងណាអំពីអត្ថន័យនៃជីវិតរបស់គេ? តើសាសនារបស់គេជួយដោះស្រាយបញ្ហាជីវិតរបស់គេយ៉ាងណា? តើគេមានការពិសោធន៍យ៉ាងណា អំពីជីវិតខាងព្រះវិញ្ញាណ? ។ តាមធម្មតា បងប្អូនកាតូលិកមិនចូលចិត្តឃោសនាអំពីសាសនាទេ ព្រោះជំនឿប្រៀបដូចជារឿងស្នេហាម៉្យាង ជារឿងអាថ៌កំបាំង ដែលយើងមិនអាចប្រាប់ដល់មិត្តសំឡាញ់លើទីសាធារណៈបានទេ ។ ម៉្យាងទៀត យើងជឿជាក់ថា ព្រះវិញ្ញាណដ៏វិសុទ្ធ គឺព្រះវិញ្ញាណរបស់ព្រះយេស៊ូ ដែលមានព្រះជន្មរស់ឡើងវិញ ព្រះអង្គគង់នៅជាមួយអស់អ្នក ដែលកាន់សាសនារបស់ខ្លួនដោយចិត្តស្មោះ ព្រះអង្គត្រាស់ហៅគេ និង ដាស់តឿនគេ តាមរបៀបផ្សេងៗ មានសាសនារបស់ខ្លួនគេជាដើម ។ យើងគ្រាន់តែខិតខំធ្វើជាសាក្សីអំពីមាគ៌ា គឺផ្លូវមួយផ្សេងទៅកាន់ព្រះជាម្ចាស់ ដែលមនុស្សទាំងអស់ស្វែងរកតាមសាសនាផ្សេងៗ ។ យើងខិតខំយល់បំណងដ៏ជ្រៅរបស់គេ ហើយយកចិត្តទុកដាក់តបឆ្លើយនឹងបំណងរបស់គេផងដែរ ។

អ្នកប្រែចិត្តគំនិត ទៅពឹងលើព្រះយេស៊ូ ហាក់ដូចជាអ្នកដូរទិសនៃជីវិតរបស់គេ គេដូរគំនិតមិនមែនមកពីគេរៀនសូត្រទ្រឹស្តី ឬ រៀនគម្ពីរទេ គឺមកពីគេបានជួបព្រះយេស៊ូ ដែលមានព្រះជន្មគង់នៅ ហើយចង់ទទួលយកព្រះអង្គមកធ្វើជាទីពឹង ។ ព្រះអង្គនាំគេឲ្យប្រែរបៀបគិតគូរឲ្យប្រែកិរិយាមារយាទរបស់ខ្លួន ប្រែទំនាក់ទំនងជា មួយអ្នកដទៃក្នុងសង្គម ជាមួយប្រុសជាមួយស្រ្តី របៀបរស់នៅជាគូស្វាមីភរិយា របៀបគេស្រឡាញ់អ្នកដទៃ ។ល។

ជួនកាល អ្នកទទួលដំណឹងល្អនេះ ជឿលើព្រះយេស៊ូជាព្រះសង្គ្រោះភ្លាម តែមិនប្រព្រឹត្តតាមដំណឹងល្អនោះ ដូចមានចែងក្នុងព្រះបន្ទូលប្រស្នាស្តីអំពីគ្រាប់ពូជទេ (ម៉ាកុស ៤:១-៩) ។ ជួនកាល ត្រូវការពីរបីឆ្នាំ ឬ ដប់ម្ភៃឆ្នាំទៀត ទើបគេយកព្រះយេស៊ូជាទីពឹងដ៏ពិតប្រាកដ គឺស្រេចតែព្រះបិតា *"ទាក់ទាញចិត្តគេ"* (យ៉ូហាន ៦:៤៤) និង ស្រេចតែចម្លើយរបស់គេដែរ ។ ក្នុងដំណាក់កាលនេះ បេក្ខជនសំដែងបំណងរបស់ខ្លួន ដែលចង់ទៅជាគ្រីស្តបរិស័ទ គាត់បានជួបគ្រីស្តបរិស័ទ ដែលប្រកាសដំណឹងល្អ តែជួនកាលយល់ច្រឡំ ដោយស្មានថា ព្រះសហគមន៍សង្គ្រោះគេតាមមនុស្សលោក ផ្តល់លុយកាក់ ឬ អង្ករ ។ល។ ព្រះសហគមន៍ក៏ជួយគេឲ្យជម្រះបំណងរបស់គេ ហើយដាស់តឿនគេឲ្យផ្ញើជីវិតលើព្រះគ្រីស្ត ដែលបង្ហាញមាគ៌ាថ្មីទៅកាន់ព្រះបិតាដែរ ។ អ្នកនោះទទួលព្រះយេស៊ូទុក *"ជាផ្លូវ ជាសេចក្តីពិត និងជាជីវិត"* (យ៉ូហាន ១៤:៦) ។ គេសុខចិត្តលះបង់ផ្លូវចាស់ចោល ចង់ស្គាល់ព្រះអង្គ ចង់រួមរស់ជាមួយព្រះអង្គ ។ បើពិតដូច្នេះមែន នៅពេលនោះ ព្រះសហគមន៍ចាត់ចែងពិធីមួយ ហៅថា *"ពិធីចូលព្រះសហគមន៍"* ។

**ព្រះសហគមន៍សម្រេចទទួលគេដោយរិះគិតអំពីលក្ខណៈខ្លះគឺ៖**

- អ្នកដែលសូមចូលព្រះសហគមន៍ ត្រូវចាប់ផ្តើមជឿលើព្រះយេស៊ូជាព្រះគ្រីស្ត និង ជាព្រះសង្គ្រោះរបស់ខ្លួន ។ ត្រូវយល់ថា ព្រះយេស៊ូមិនមែនជាព្រះបិតា ហើយក៏មិនមែនជាព្រះវិញ្ញាណដ៏វិសុទ្ធដែរ ។
- អ្នកនោះត្រូវមានអំណរសប្បាយខ្លះក្នុងចិត្ត ដោយបានជួបព្រះគ្រីស្ត ដែលមានព្រះជន្មគង់នៅ ហើយយកចិត្តទុកដាក់ចែករំលែកដំណឹងល្អនេះឲ្យអ្នកដទៃផង ។
- អ្នកនោះលែងយកព្រះពុទ្ធជាទីពឹង គឺបែរទៅរកព្រះគ្រីស្តជាទីពឹង ។ សេចក្តីនេះមិនសំដៅថា យើងមិនពេញចិត្តនឹងពុទ្ធសាសនា

ទេ តែត្រូវជ្រើសរើសផ្លូវមួយ យើងមិនអាចទៅក្រុងបាត់ដំបងបាន ដោយជិះឡានផង ជិះយន្តហោះផងទេ ។

- អ្នកនោះលែងខ្លាចខ្មោច លែងទៅសួរហោរ លែងទៅបញ្ជាន់អារក្ខ ។
- គេចាប់ផ្តើមយកចិត្តទុកដាក់នឹងអ្នកដទៃ អ្នកក្រជាងខ្លួនរកយុត្តិធម៌ក្នុងសង្គមតាមកម្លាំងរបស់ខ្លួន ។
- គេសប្បាយចិត្ត ដោយចូលរួមជាមួយអ្នក ដែលស្វែងព្រះយេស៊ូដូចគ្នា ។
- មានចិត្តភក្តីនឹងគូរបស់ខ្លួន លែងលេងបៀរ លែងស្រវឹងស្រា លែងរកស៊ីផ្តេសផ្តាស ជាពិសេសដោយជិះជាន់អ្នកដទៃ លែងស៊ីសំណូក ។ល។
- ប្រសិនបើអ្នកនេះនៅក្មេង ឪពុកម្តាយត្រូវពេញចិត្តឲ្យកូនទៅជាគ្រីស្តបរិស័ទ ។

ពេលនោះព្រះសហគមន៍ ទទួលគេទុកជាគ្រីស្តបរិស័ទ ទោះបីគេមិនទាន់ទទួលអគ្គសញ្ញាជ្រមុជទឹកក៏ដោយ ។

## ២- ដំណាក់កាលទី ២ គឺពេលបង្ហាត់ឲ្យទៅជាសាវ័ក

ព្រះយេស៊ូបានផ្តាំក្រុមគ្រីស្តទូតឲ្យ *"នាំមនុស្សគ្រប់ជាតិសាសន៍ ធ្វើជាសាវ័ក"* និង *"បង្រៀនគេឲ្យប្រតិបត្តិតាមសេចក្តីទាំងប៉ុន្មានដែលខ្ញុំបានបង្គាប់"* ឲ្យគេ (ម៉ាថាយ ២៨:១៩) ។ បុព្វបុរសនៃព្រះសហគមន៍គ្រីស្តបរិស័ទបានបង្កើតពាក្យថ្មីសំដៅទៅលើតំណាក់កាលនេះ គឺ *"រយៈពេលបង្ហាត់គេឲ្យទៅជាសាវ័ក"* (Discipulat) ។ ត្រូវចំណាយពេលវេលាយ៉ាងយូរ ដើម្បីឲ្យទៅជាសាវ័ក ទោះបីអ្នកទទួលអគ្គសញ្ញាជ្រមុជទឹកក្តី ក៏មិនទាន់ក្លាយជាសាវ័កពិតប្រាកដដែរ ។

អ្នកដែលចូលព្រះសហគមន៍រួចហើយ ទទួលការអប់រំ ៣ វិស័យដ៏សំខាន់ គឺ៖ ឲ្យគេស្គាល់ព្រះបន្ទូល ឲ្យចេះអធិដ្ឋាន និង ឲ្យរស់នៅតាមគន្លងធម៌របស់ព្រះគ្រីស្ត គឺស្របតាមដំណឹងល្អរបស់ព្រះអង្គ ដូចមានចែងក្នុងគម្ពីរ *"កិច្ចការគ្រីស្តទូត"* អំពីព្រះសហគមន៍គ្រីស្តបរិស័ទដើម គឺពួកគេ *"ព្យាយាមស្តាប់សេចក្តីបង្រៀនរបស់គ្រីស្តទូត ព្យាយាមរួមរស់ជាមួយគ្នា . . . និង ព្យាយាមអធិដ្ឋាន"* (កិច្ចការ ២:៤២) ។

អ្នកទទួលការអប់រំជំនឿ *"ព្យាយាមស្តាប់សេចក្តីបង្រៀនរបស់ក្រុមគ្រីស្តទូត"* ។ អ្នកស្តាប់ព្រះបន្ទូលមិនគ្រាន់តែរៀនគម្ពីរទេ គឺទទួលស្គាល់បន្តិចម្តងៗថា ព្រះជាម្ចាស់ជាព្រះបិតា ដែលស្រឡាញ់គាត់ ហើយត្រាស់ហៅគាត់ឲ្យចងសម្ពន្ធមេត្រីជាមួយព្រះអង្គ ដូចព្រះអង្គសុំរៀបអាពាហ៍ពិពាហ៍ជាមួយ ។ ពេលយើងសិក្សាអំពីគម្ពីរ យើងចូលក្នុងរឿងស្នេហាម៉្យាង ព្រោះប្រវត្តិនៃការសង្គ្រោះ ដែលមានចែងក្នុងព្រះគម្ពីរ ប្រៀបដូចជារឿងស្នេហា និង អំណោយទាននៃជីវិត ។ អ្នកជឿតបឆ្លើយនឹងព្រះជាម្ចាស់ ដែលស្រឡាញ់គេ ។ ធម្មវិន័យក៏ចេញមកពីសេចក្តីស្រឡាញ់ដែរ ហេតុនេះហើយ អ្នកស្វែងរកព្រះយេស៊ូ ត្រូវរិះគិតអំពីការរស់នៅរបស់ខ្លួន ដើម្បីឲ្យគេប្រែរបៀបរស់នៅ ឲ្យបានស្របនឹងព្រះជាម្ចាស់ ដែលស្រឡាញ់គាត់ ។ អ្នក *"បង្រៀនព្រះគម្ពីរ"* ជាសាក្សី ដែលចែករំលែកការពិសោធន៍របស់ខ្លួន ដោយយោងពីការរស់នៅរបស់ខ្លួនផ្ទាល់ មិនមែនជាគ្រូ ដែលបង្រៀនសេចក្តីក្នុងគម្ពីរទេ ។

គេ *"ព្យាយាមអធិដ្ឋាន"* គឺ អ្នកស្វែងរក ទទួលការអប់រំឲ្យចេះអធិដ្ឋានដោយខ្លួនឯង តាមបែបជាគ្រីស្តបរិស័ទ ។ គ្រប់សាសនា អប់រំមនុស្សឲ្យចេះ ពាក្យអធិដ្ឋាន ឬ ឲ្យចេះសូត្រធម៌ ប៉ុន្តែមានតែព្រះយេស៊ូមួយព្រះអង្គទេ ដែលបង្ហាត់ឲ្យមានទំនាក់ទំនងពិសេសជាមួយព្រះបិតា ដោយព្រះវិញ្ញាណបំភ្លឺ ។ ហេតុនេះ ត្រូវបង្ហាត់គេឲ្យអធិដ្ឋានតាមរបៀបព្រះយេស៊ូបង្ហាត់ក្នុង ម៉ាថាយ ៦:៥-១៣ ជាពិសេស ។ ពាក្យអធិដ្ឋាន *"ឱ!*

*ព្រះបិតាយើងខ្ញុំ"* ជាពាក្យអធិដ្ឋានគំរូរបស់គ្រីស្ទបរិស័ទ ។ អ្នកទទួលការអប់រំឲ្យចេះអធិដ្ឋាន ទូលព្រះបិតាដោយផ្ទាល់ ដោយចិត្តស្រឡាញ់ ដោយយកព្រះបន្ទូលរបស់ព្រះយេស៊ូផ្ទាល់មកទូល ដោយមានចិត្តគំនិតដូចព្រះយេស៊ូ ។

គេ *"ព្យាយាមរួមរស់ជាមួយគ្នា . . ."* គឺ គ្រីស្ទបរិស័ទដើមដំបូងយកទ្រព្យសម្បត្តិរបស់ខ្លួនមកចែកគ្នា ។ បានសេចក្ដីថាគ្រីស្ទបរិស័ទរស់នៅតាមរបៀបផ្សេងពីអ្នកដទៃ ហើយមិនរកប្រយោជន៍ផ្ទាល់ខ្លួន ដោយគិតគូរដល់អ្នកក្រជាងខ្លួន ។ នេះជាចំណុចដ៏សំខាន់ បញ្ជាក់អំពីការប្រែចិត្តគំនិត មិនគ្រាន់តែដោយបបូរមាត់ប៉ុណ្ណោះទេ ។ អ្នកស្វែងរកព្រះយេស៊ូទទួលការអប់រំឲ្យរស់នៅតាមរបៀបព្រះយេស៊ូបានបង្ហាត់បង្រៀន គឺឲ្យស្រឡាញ់អ្នកដទៃ ឲ្យអត់ទោសឲ្យគេ ដែលសុទ្ធតែជាការប្លែកពីការមនុស្សលោកធ្លាប់ធ្វើជាធម្មតា ។ ពេលនោះ ត្រូវនឹកសញ្ជឹងអំពីសេចក្ដីដែលព្រះយេស៊ូបង្រៀននៅលើភ្នំ (ម៉ាថាយ ៥-៧) គឺព្រះអង្គបង្ហាញផ្លូវទៅកាន់សុភមង្គល ដ៏ពិតប្រាកដ ប្លែកពីសុភមង្គល របស់មនុស្សលោកិយ ។ អ្នកណាក៏ត្រូវអនុវត្តតាមវិន័យរបស់លោកម៉ូសេដែរ មានតែគ្រីស្ទបរិស័ទទេ ដែលអនុវត្តតាមធម្មវិន័យថ្មីរបស់ព្រះយេស៊ូ ។

ដំណាក់កាលនេះយូរក្រៃលដែរ ប្រហែលមួយ ឬ ពីរឆ្នាំ ។ ក្នុងតំណាក់កាលនេះ មានចាត់ចែងពិធីផ្សេងៗ ដូចជាពិធីបញ្ចូលពាក្យអធិដ្ឋានរបស់ព្រះយេស៊ូ (ម៉ាថាយ ៦:៩-១៣) គឺគ្រីស្ទបរិស័ទផ្ដល់សក្ខីភាពអំពីរបៀប ដែលខ្លួនរស់នៅតាមពាក្យអធិដ្ឋាននេះ ឲ្យអ្នកស្វែងរកស្ដាប់ ។ ជួនកាលមានចែងពិធីបញ្ជូនព្រះបន្ទូលរបស់ព្រះយេស៊ូ ស្ដីអំពីសុភមង្គលដ៏ពិតប្រាកដ (ម៉ាថាយ ៥:១-១២) ។ ជួនកាលមានបញ្ជូន *"ធម៌ប្រកាសជំនឿ"* ជាសេចក្ដីសង្ខេបនៃជំនឿរបស់គ្រីស្ទបរិស័ទ ដូចអភិបាលព្រះសហគមន៍បានចែងនៅក្រុងនីសេ (គ.ស ៣២៥) ។ ដូច្នេះ អ្នក

ចំណោលថ្មីអាចយល់ឃើញថា ខ្លួនទទួលជំនឿ ដែលក្រុមគ្រីស្តទូតបាន ប្រកាសមក តៗរហូតដល់សព្វថ្ងៃ ។

## ៣- ដំណាក់កាលរៀបចំខ្លួនឲ្យអគ្គសញ្ញាជ្រមុជទឹក និង ព្រះកាយព្រះគ្រីស្ត

តាំងពីជំនាន់មានចំនួនគ្រីស្តបរិស័ទជាច្រើន ព្រះសហគមន៍ចាត់ចែងរយៈពេលមួយ មុនបុណ្យចម្លង សម្រាប់ឲ្យគ្រីស្តបរិស័ទទាំងអស់រៀបចំខ្លួននឹងធ្វើពិធីលើកតំកើងព្រះយេស៊ូសោយទិវង្គត និង មានព្រះជន្មរស់ឡើងវិញ គឺអស់រយៈពេលជាសែសិបថ្ងៃ (lent) ។ ពេលនោះ ព្រះសហគមន៍ចាត់ចែងការអប់រំពិសេសសម្រាប់អ្នកស្វែងរកព្រះយេស៊ូ គឺឲ្យអានអត្ថបទគម្ពីរ ដែលរំឭកគ្រីស្តបរិស័ទអំពីអគ្គសញ្ញាជ្រមុជទឹក គឺអត្ថបទស្តីអំពីមារល្បួងព្រះយេស៊ូ (ម៉ាថាយ ៤:១-១១) ព្រះយេស៊ូសំដែងសិរីរុងរឿង (ម៉ាថាយ ១៧:១៩) ព្រះយេស៊ូមានព្រះបន្ទូលសន្ទនាជាមួយស្ត្រីស្រុកសាម៉ារី (យ៉ូហាន ៤:៥-៤២) ព្រះយេស៊ូប្រោសមនុស្សខ្វាក់តាំងពីកំណើតមកឲ្យភ្លឺ (យ៉ូហាន ៩:៤១) ព្រះយេស៊ូប្រោសលោកឡាសារឲ្យរស់ឡើងវិញ (យ៉ូហាន ១១-៤៤) ។ ព្រះសហគមន៍ទាំងមូលអប់រំអ្នកដែលចង់ទទួលអគ្គសញ្ញាជ្រមុជទឹក ក្នុងឱកាសបុណ្យចម្លង ឲ្យទទួលស្គាល់ផ្លូវរបស់ព្រះយេស៊ូ ដែលជាការតយុទ្ធប្រឆាំងនឹងមារ តែជាផ្លូវដែលនាំគេឆ្ពោះទៅកាន់សិរីរុងរឿង ។ ពេលគេទទួលអគ្គសញ្ញាជ្រមុជទឹក ព្រះយេស៊ូប្រោសប្រទានទឹកដែលផុសឡើង ផ្តល់ជីវិតអស់កល្បជានិច្ច ព្រះអង្គបំភ្លឺចិត្តគំនិតរបស់គេ ព្រះអង្គក៏ប្រោសគេឲ្យរស់ឡើងវិញដែរ ។

ធម្មតា លោកអភិបាលព្រះសហគមន៍ ធ្វើអគ្គសញ្ញាជ្រមុជទឹកជូនគេ នៅរាត្រីបុណ្យចម្លង ដើម្បីបញ្ជាក់យ៉ាងច្បាស់ថា អ្នកដែលទទួលអគ្គសញ្ញាជ្រមុជទឹក គឺរួមស្លាប់រួមរស់ជាមួយព្រះគ្រីស្ត ដែលសោយទិវង្គត

និង មានព្រះជន្មរស់ឡើងវិញ ដូចគ្រីស្តទូតប៉ូល ថែងថា៖ *"យើងទាំងអស់គ្នា ដែលបានទទួលពិធីជ្រមុជទឹក ដើម្បីរួមជាមួយព្រះ គ្រីស្តយេស៊ូ គឺយើងបានជ្រមុជរួមជាមួយព្រះអង្គ ដែលសោយទិវង្គត . . . រួមស្លាប់ជាមួយព្រះអង្គ យើងដូចជាបានចូលក្នុងផ្នូរជាមួយព្រះអង្គដែរ ។ . . . យើងក៏នឹងបានរួមជាមួយព្រះអង្គ ដែលមានព្រះជន្មរស់ឡើងវិញដែរ"* ។ (រ៉ូម ៦:៣ . . . ៥) ។

## ៤- ដំណាក់កាលទី ៤ ការរិះគិតអំពីជីវិតថ្មីដ៏អស្ចារ្យ ដែលគ្រីស្តបរិស័ទបានទទួលដោយសារព្រះគ្រីស្ត

ក្រោយបុណ្យចម្លង ហើយអស់រយៈពេលយ៉ាងហោចណាស់ ៥០ ថ្ងៃ ពន្លកថ្មី (neophyte) រិះគិតជាមួយគ្នាអំពីតម្លៃដ៏ថ្លៃថ្នូរនៃជីវិតរបស់ខ្លួន ។

★ ★ ★

បុព្វបុរសនៃព្រះសហគមន៍ពីដើម តែងប្រៀបធៀបមនុស្សពេញវ័យ ដែលសុំទៅជាគ្រីស្តបរិស័ទ ទៅនឹងការករកំណើតក្នុងផ្ទៃម្តាយ ឬទៅនឹងជនជាតិអ៊ីស្រាអែល ដែលធ្វើដំណើរចេញពីស្រុកអេស៊ីប ហើយចូលទៅទឹកដីកាណាន ។

ព្រះយេស៊ូ តែងប្រៀបធៀបអគ្គសញ្ញាជ្រមុជទឹកទៅនឹងកំណើតថ្មី (យ៉ូហាន ៣:៣-៨៖ *"ប្រសិនបើមនុស្សមិនកើតជាថ្មីទេ . . . ប្រសិនបើមនុស្សមិនកើតពីទឹក និង ពីព្រះវិញ្ញាណទេ គេពុំអាចចូលក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់បានឡើយ"* ) ។ ប៉ុន្តែមនុស្សធ្លាប់មានជីវិតក្នុងផ្ទៃម្តាយ ៩ ខែ មុននឹងកើតជាទារក ។ ម្តាយទទួលមេជីវិតពីស្វាមីយ៉ាងណា អ្នកជឿក៏ទទួលព្រះបន្ទូលរបស់ព្រះជាម្ចាស់យ៉ាងនោះដែរ ។ ពេលគេទទួល

ដំណើងល្អដើមដំបូង ជំនឿរបស់គេ ហាក់ដូចជា *"ចាប់ផ្ទៃ"* តែជំនឿនេះនៅតូចនៅឡើយ ដូចទារកក្នុងផ្ទៃម្តាយ ។ ពេលនោះ អ្នកស្វែងរកព្រះយេស៊ូ ធ្វើកាយវិការផ្សេងៗបញ្ជាក់ថា ខ្លួនសុខចិត្តដើរតាមព្រះអង្គ ដែលត្រាស់ហៅគេ គេចង់ស្គាល់ព្រះអង្គទុកជាព្រះបរមគ្រូរបស់ខ្លួនឲ្យកាន់តែច្បាស់ឡើងៗ ហើយគេសម្រេចចិត្តផ្ញើជីវិតទាំងស្រុងលើព្រះអង្គ ដែលជាប្រភពនៃជីវិតដ៏ពិតប្រាកដ ។ អ្នកនោះចាប់ផ្តើមជឿ ហើយនៅពេលនោះគាត់ *"ចូលក្នុងព្រះសហគមន៍"* ដោយមានពិធីដ៏ឱឡារិកមួយ ។ ពេលគេចូលព្រះសហគមន៍ហើយនោះគេទៅជា *"គ្រីស្តបរិស័ទ"* ហើយ ។

ក្នុងផ្ទៃម្តាយ កូនត្រូវការពេលវេលាយ៉ាងយូរ ដើម្បីចំរើនឡើងយ៉ាងណា អ្នកដែលប្រែចិត្តគំនិតទទួលព្រះយេស៊ូទុកជាព្រះសង្គ្រោះ ក៏ត្រូវការពេលវេលាយ៉ាងយូរដែរ ដើម្បីហាត់ខ្លួនឲ្យរស់នៅតាមព្រះឱវាទរបស់ព្រះអង្គ ។ គេមិនត្រូវ *"រៀន"* ទេ គឺគេត្រូវហាត់ខ្លួនឲ្យរស់នៅតាមព្រះគ្រីស្ត គឺគេដើរតាមព្រះអង្គ ដែលគេបានជួប គឺព្រះដែលមានព្រះជន្មគង់នៅ ។

ការប្រៀបធៀបបែបនេះ ជួយបំភ្លឺឲ្យយើងយល់ថា ត្រូវទុកពេលវេលាយ៉ាងយូរ ដើម្បីឲ្យជំនឿនេះចំរើនឡើង ដូចកូនក្នុងផ្ទៃត្រូវការពេលវេលាយ៉ាងយូរ ដើម្បីទៅជាទារកដ៏ពិតប្រាកដ ។ បើកូនកើតត្រូវតាមពេលកំណត់ វារស់បាន ប្រសិនបើវាកើតមុនពេលកំណត់ វារលូត មិនអាចរស់បានទេ ប្រសិនបើវាកើតយឺតពេលពេក វាក៏ត្រូវស្លាប់ក្នុងផ្ទៃម្តាយដែរ ។ ហេតុនេះ កុំធ្វើអគ្គសញ្ញាជ្រមុជទឹកមុនពេលកំណត់ គឺនៅពេលគេមិនទាន់មានជំនឿគ្រប់គ្រាន់ ក្រែងជំនឿរបស់គេសាបសូន្យ ។ កុំពន្យារពេលយូរពេក ក្រែងគេណាយចិត្ត ហើយជំនឿនេះក៏ស្លាប់ដែរ ។

ម្យ៉ាងទៀត ការប្រៀបធៀបនេះជួយបំភ្លឺ ឲ្យយើងដឹងថា ការអប់រំអ្នកស្វែងរកព្រះយេស៊ូពុំមែនជា *"ការបង្រៀន"* ទេ គឺជាការបង្ហាត់ឲ្យគេរស់នៅតាមរបៀបព្រះគ្រីស្តវិញ ។ ព្រះសហគមន៍ទាំងមូលប្រៀបដូចជា

ម្ដាយ ដែលចិញ្ចឹមកូនក្នុងផ្ទៃ គឺមិនគ្រាន់តែមានពីរ ឬ បីនាក់ទទួលភារកិច្ចនេះទេ ។ ក្រុមគ្រីស្ទបរិស័ទទាំងអស់អប់រំគេ ដោយធ្វើជាគំរូឲ្យគេ ដោយស្រឡាញ់គ្នាយ៉ាងពិតប្រាកដ ដោយចាត់ចែងពិធីបុណ្យផ្សេងៗ ។ អ្នកស្វែងរកព្រះយេស៊ូ ក៏ជួយឲ្យព្រះសហគមន៍បំពេញមុខនាទីរបស់ខ្លួនជាម្ដាយដែរ គឺឲ្យមានចិត្តល្អ ចេះអប់រំ យកចិត្តទុកដាក់នឹងចិញ្ចឹមគេ ។

បុព្វបុរសនៃព្រះសហគមន៍ ក៏តែងតែប្រៀបធៀបការបង្ហាត់អ្នកស្វែងរកព្រះយេស៊ូ ទៅនឹងដំណើរចេញពីស្រុកអេស៊ីបទៅកាន់ទឹកដីកាណានដែរ ។ ព្រឹត្តិការណ៍នេះមានសារៈសំខាន់យ៉ាងខ្លាំងក្នុងប្រវត្តិនៃប្រជារាស្ត្ររបស់ព្រះជាម្ចាស់។ ព្រះជាម្ចាស់ត្រាស់ហៅប្រជារាស្ត្រព្រះអង្គឲ្យរួចផុតពីទាសករនៅស្រុកអេស៊ីប ព្រះអង្គប្រោសគេឲ្យឆ្លងកាត់សមុទ្រក្រហម និង ប្រទានធម្មវិន័យនៅលើភ្នំស៊ីណៃ ។ ព្រះអង្គហាក់ដូចជាមានព្រះបន្ទូលថា *"យើងស្រឡាញ់អ្នករាល់គ្នាហើយ តើអ្នករាល់គ្នាសុខចិត្តស្រឡាញ់យើងឬទេ? យើងមានព្រះបន្ទូល តើអ្នករាល់គ្នាសុខចិត្តប្រព្រឹត្តតាមឬទេ?"* ។ ជនជាតិអ៊ីស្រាអែលបានប្រព្រឹត្តអំពើបាបដោយថ្វាយបង្គំរូបគោ ហេតុនេះ ព្រះជាម្ចាស់ល្បងលមើលចិត្តគេអស់រយៈពេលសែសិបឆ្នាំ ។

លោក អូរីសែន ជាជនជាតិអេស៊ីបម្នាក់ រស់នៅសតវត្សទី ២ នៃ គ.ស ។ លោកជាគ្រូអប់រំជំនឿដ៏ចំណានម្នាក់ លោកធ្លាប់លើកឧទាហរណ៍នេះ ដើម្បីអប់រំអ្នកស្វែងរកព្រះយេស៊ូថា *"បងប្អូនបានឃ្លាតចាកពីពិភពលោកនៃសាសន៍ដទៃ បានលះបង់ចោលការគោរពព្រះដទៃនៅស្រុកអេស៊ីបហើយ! បងប្អូនបានចូលក្នុងប្រជារាស្ត្ររបស់ព្រះជាម្ចាស់ហើយ ។ បងប្អូនចាប់ផ្ដើមដើរ ។ ពេលបងប្អូនទទួលការអប់រំខាងជំនឿ ប្រៀបដូចជាទៅនឹងពេលដែលប្រជាជនអ៊ីស្រាអែលដើរក្នុងវាលរហោស្ថាន ។ បងប្អូនបានទទួលធម្មវិន័យរបស់លោកម៉ូសេ និង ធម្មវិន័យរបស់ព្រះយេស៊ូ ហើយហាត់ខ្លួនឲ្យរស់នៅតាមរបៀបព្រះអង្គប្រៀន*

*ប្រដៅនោះ ។ ពេលបងប្អូនបានហាត់ខ្លួនឲ្យរស់នៅតាមរបៀបថ្មីនោះរួច អស់លោកបូជាចារ្យនឹងជូនដំណើរបងប្អូន ឲ្យឆ្លងទន្លេយ័រដាន់ ហើយបងប្អូនបានទទួលពិធីជ្រមុជទឹកក្នុងទន្លេយ័រដាន់ដូចព្រះគ្រីស្តដែរ ។ បន្ទាប់មកបងប្អូននឹងចូលក្នុងទឹកដីសន្យា ទៅសម្រាប់រួមជាមួយព្រះគ្រីស្ត*" ។

ការប្រៀបធៀប ក៏ជួយបំភ្លឺឲ្យយល់ថា ជំនឿប្រៀបដូចជាការធ្វើដំណើររួមជាមួយព្រះយេស៊ូ គឺមានដំណាក់កាលផ្សេងៗ ។ អ្នកស្វែងរកព្រះយេស៊ូ ធ្វើដំណើរជាមួយព្រះសហគមន៍ទាំងមូល ពួកគេស្តាប់ព្រះបន្ទូលរួមជាមួយគ្រីស្តបរិស័ទឯទៀតៗ ។ ដំណើរនេះ ជាការពិបាកបន្តិច ប៉ុន្តែ ត្រូវខិតខំរស់នៅឲ្យបានកាន់តែប្រសើរឡើងៗ តាមដំណឹងល្អរបស់ព្រះយេស៊ូ ។

អស់លោកក៏ធ្លាប់ប្រៀបធៀបអត្តសញ្ញាជ្រមុជទឹក ទៅនឹងអាពាហ៍ពិពាហ៍ គឺមានដំណាក់កាលផ្សេងៗដែរ មានចូលដណ្តឹង ភ្ជាប់ពាក្យ លើកជំនួន រៀបការ រស់នៅជាមួយគ្នា ។

★ ★ ★

របៀបព្រះសហគមន៍កាតូលិក អប់រំអ្នកស្វែងរកព្រះយេស៊ូ ជារបៀបគ្រីស្តបរិស័ទធ្លាប់ធ្វើតាំងពីដើមរៀងមក ។ ព្រះជាម្ចាស់ទាក់ទាញចិត្តមនុស្សឲ្យជឿ តែយើងជាគ្រីស្តបរិស័ទក៏មានភារកិច្ចអប់រំជំនឿដែរ ។ លោក អូរីសែន បញ្ជាក់ថា "*គេមកជិតជំនឿ គេចូលក្នុងជំនឿ គេបញ្ជាក់ជំនឿ និង រស់នៅតាមជំនឿ*" ។ ព្រះយេស៊ូក៏សព្វព្រះហឫទ័យឲ្យអ្នកជឿរួមគ្នាជាមហាគ្រួសារ ដែលយកចិត្តទុកដាក់នឹងរស់នៅតាមរបៀបថ្មី និងកែប្រែទ្រង់ទ្រាយពិភពលោកនេះ ឲ្យបានសមនឹងព្រះហឫទ័យព្រះអង្គ ។ ជំនឿមានឥទ្ធិពលក្នុងដំណើរនៃពិភពលោក ។

HONEYCOMB 2/1 (January 2001): 99–110

# Indigenization of a National Church

## A Reflection on Cambodian Church Structure

*Arun SOK NHEP*

### Introduction

The concept of indigenization is not new to Christianity. We read about it as early as Paul's ministry in the book of Acts. Gentile churches, while keeping a close relationship with the mother church in Judea, had difficulty adopting Jewish practices such as circumcision. Paul, as a missionary to the Gentiles, understood the need of the Gentiles to be themselves. He defended their cause and convinced the Jewish Christians not to impose their own customs and lifestyle on the Gentiles (Acts 15).

Everywhere the gospel is proclaimed Christianity has to work toward making the Church indigenous. Presently, church culture seems to be moving towards Western—and especially American—paradigms in music, worship, structure, strategy, evangelism methods, etc. This trend also occurs here in Cambodia.

Unfortunately, in process of church planting, not only were the gospel and a Christian worldview transmitted, but western church culture as well. As a result, the Cambodian church as a whole seems disconnected from its own socio-cultural environment. This puts believers under pressure, as they are torn between the cultural system transmitted by missionaries and their own cultural system. Christians are perceived by their compatriots as traitors, and become strangers within their own culture. Some missionaries and national leaders are aware of the problem of

western acculturation but do not know how to make the appropriate changes.

The purpose of this article is to learn from what has been written about contextualization with its benefits and dangers, and to provide a reflection (but not a model) on how a contextualized Cambodian Church may be conceived.

## Indigenization

Nowadays missionaries are evaluated not only by their accomplishments in evangelizing a nation, but also by their ability to indigenize the churches they establish. Consequently, most mission societies orient their objectives toward the training of national leaders so that, in turn, the nationals can take over the leadership of their own churches.

According to Soltau, a church is indigenous when "it becomes native to the country and grows there naturally, as part and parcel of the people among whom it has been planted."[1]

Smalley defines an indigenous church as "a group of believers who live out their life, including their socialized Christian activity, in the patterns of the local society, and for whom any transformation of that society comes out of their felt needs under the guidance of the Holy Spirit and the Scriptures."[2]

In practice, however, a local church is judged to be indigenized or not based on its autonomy in leadership, finance, and propagation strategy. This autonomy is often labeled as *the three-self formula:* "self-governing, self-supporting, and self propagating."

Self-governing churches are not necessarily indigenous, because national leaders are often trained in western patterns of church government. They are not really oriented to organizing the

---

[1]T. S. Soltau, *Missions at the Crossroads* (Grand Rapids: Baker, 1994), 20.

[2]Article in *Perspectives on the World Christian Movement*, ed. R. D. Winter and S. C. Hawthorne (Pasadena: William Carey Library, 1981), 497.

church from their own socio-cultural perspective, but rather blindly imitate the western church culture. In fact, nationals often serve as figureheads in the leadership while missionaries exercise the real power over the local churches because of the financial support they provide. "Self-supporting" is also often considered a barometer of success in indigenization. National churches are encouraged to meet their needs financially and support their leaders. They are also encouraged to establish local strategies to share the gospel with their own people. But the methods used, whether in financial matters or in evangelism strategies (crusades, campaigns, etc.), are often not different from those of the west.

But indigenization entails more than this three-self formula; it requires deep reflection on and evaluation of the cultural identity of a national church. This leads to the next and probably most important step in the process of indigenization—contextualization.

## Contextualization

According to Lingenfelter, contextualizing means "to frame the gospel message in language and communication forms appropriate and meaningful to the culture and to focus the message upon crucial issues in the lives of the people."[3]

**Contextualization: reaction to colonialism.** Unfortunately, in the past the history of mission has been closely linked to colonialism. Mission opened a door for western colonization, and colonization allowed missionaries to establish the church in remote areas of the world.

During the colonial era, encounters between western and other nations resulted in a feeling of superiority on the part of white people because of their advanced science and technology. Consequently, western culture was considered superior to other

---

[3]Sherwood G. Lingenfelter, *Transforming Culture—A Challenge for Christian Mission*, 2nd ed. (Grand Rapids: Baker, 1998), 1.

cultures, and often it was labeled simply as "the culture" in contrast to others termed "primitive".

Missionaries during that period were affected by the spirit of their times. They organized the church molded on western culture. In their reasoning, "the West's obvious superiority over other cultures proved the superiority of Christian over pagan religions."[4] And these "primitive" nations did need not only salvation, but also civilization! For instance, "in 1890, T. W. Pearce pointed out that merely introducing Christianity to China was not enough, Western civilization, in its entirely, had to overcome Chinese civilization."[5] For this reason, even today one can notice a strongly western culture within Chinese churches.

In the same spirit, they translated the Bible using the literal translation principle (often from the King James Version) and did not care about the linguistic or cultural sensibilities of the receptive languages. Often witnessing to the gospel was combined with English teaching so that new believers could find better jobs and attain higher economic status. Thus, Anglo-culturization was sometimes perceived by missionaries and national as superior to local culture.

Although the colonial era thus entailed such negative aspects as arrogance and segregation, we have to admit the positive side of that period: the gospel was proclaimed, regardless of how it was transmitted;[6] the Bible was translated into many languages; churches, hospitals, and educational systems were established.

But the anti-colonial movement brought to an end racial segregation within the church, at least on the ethic level. The superiority of western culture was questioned; western Christians started to discern between the gospel and their own culture. They also began taking other cultures seriously and sought to understand them. Consequently, more and more missionaries encouraged

---

[4]Paul G. Hiebert, *Anthropological Reflections on Missiological Issues* (Grand Rapids: Baker, 1994), 55.

[5]Ibid.

[6]Phil 1:18.

indigenous leaders to present the gospel with a local context and theology. The local church must seek to "integrate the Gospel message (*the text*) with its local culture (*the context*). The text and context must be blended into that one, God-intended reality called *Christian living.*"[7]

**The dangers of contextualization.** However, contextualization also has its drawbacks, especially when there is a tendency to perceive all cultures as good. Other religions may also be considered as a revelation of God, and therefore may open a door to syncretism. As a result the uniqueness of Christ and his salvation are questioned. Christ may be presented as only *one* way to the Father, and not *the* way.

This could also lead to the other extreme—rejecting everything from the West, even its good principles.

**Critical contextualization.** In order to benefit from contextualization and avoid dangers of dragging, the process must be undertaken with care. I think the task of contextualization should undertaken by local leaders and missionaries (preferably from different nationalities) together. A local leader has ability to discern and feel what is good or bad in his culture. But the role of the missionary is also important in providing a framework. Before making any exegesis of a culture, one should seek first to understand that culture.

Kwast[8] believes that understanding a culture is like peeling different layers. The first layer is to study the *behavior* of the people. Second, understand their *values*. Third, probe the deeper level of *beliefs*: what they hold to be true. Finally, at the very heart of any culture lies its *worldview*: what is real to people. This last has to be taken into account when sharing the gospel.

---

[7]L. J. Luzbetak, *The Church and Cultures*, (Maryknoll, New York: Orbis, 1988), 72.

[8]In an article published in C. H. Kraft and T. N. Wisley, eds., *Readings in Dynamic Indigeneity* (Pasadena: William Carey Library, 1979).

Hesselgrave[9] argues that the missionary has his own cultural background, which embodies his own worldview and standard of values. He himself received the message of the Bible within his own specific cultural context. This is the "missionary's culture." He has to transmit the message to another culture with its distinct worldview and value system. This is the "target culture." The temptation is ever present to project the cultural background of the missionary into the process and therefore blur the original meaning of the Bible's message. The missionary must take into account the target culture with its value system. He must remember that the ideas of this culture are as strong as those from his own. His audience will project their own understanding into the message of the Bible. The missionary must strive to communicate in a way that is relevant to the target culture while still remaining faithful to the original message. This is a most difficult task.

Therefore the responsibility of the missionary is heavy, as he has to lead and train leaders in the respondent culture. National pastors have often proved even worse in spreading a western message with little relevance to their own culture. The consequences are both disastrous and lasting. What is done is difficult to undo.

Hesselgrave believes that communication between the missionary and the target culture is often a monologue—from missionary to respondent. The missionary only relates the message without trying to understand the respondent culture and worldview. Nothing will be gained by ridiculing or pointing to inconsistencies in the beliefs. The message of the gospel is universal. The Christian message remains the same for all times and all cultures. Contextualization is essential for the message to be understood and accepted.

In the case study of the Cambodian church, I would like to leave aside the theological aspects of contextualization, and emphasize the institutional structure of the indigenized church.

---

[9]In an article published in Kraft and Wisley, *Readings*.

## The Cambodian Church

Every society is a system. In order to function efficiently, any system needs to be balanced and harmonious. According to Mayers, "all the parts of the systems relate to the whole and give it meaning. The whole, in turn, gives meaning to the parts. Without the whole, the parts would have no reason for existing; and without any one of the parts, there would be no whole."[10]

A local church, although spiritual part of the Kingdom of God, also remains part of a definite socio-cultural group. The church is called to transform its environment with the gospel without becoming unnecessarily foreign to the socio-cultural system.

The church of Cambodia has manifested a desire to indigenize, and missionaries are working to relinquish the leadership to national Christians. Nevertheless, non-Christian Cambodians still consider the church to be foreign, since the church culture and institutional structure are unfamiliar to most people. For a Cambodian, to become a Christian is not an easy thing—he experiences not only a spiritual transformation, but has to adapt to western church culture. For this reason, most of the churches have a difficult time in discipling new believers, as they tend to return to Buddhism after a brief sojourn in Christianity. I think this phenomenon is due to cultural nostalgia, because the church has neglected the importance of contextualization. I believe that indigenization without contextualization is ineffective.

**Learning from history.** Portuguese Dominican missionaries arrived in Cambodia in the mid-sixteenth century. Buddhism had entered a few centuries previously, and experienced such expansion that it superseded Hinduism as the national religion. Christianity never enjoyed such success. Buddhism succeeded in its indigenization.

---

[10]M. Myers, *Christianity Confronts Culture* (Grand Rapids: Zondervan, 1987), 95.

In 1975 the Roman Catholic Church counted only a few hundred members in its fold.[11] Leadership was exercised by French bishops and priests. Although the Catholics took great pains to inculturate, the French missionaries did not seem ready to relinquish leadership to nationals. Only two or three Khmer priests were ordained, and the first Khmer bishop was ordained at the last minute because foreigners had to leave the country before the Khmer Rouge took over the country in 1975. Therefore the Catholic Church is perceived by the population as a French religion.

Protestant missionaries from Christian and Missionary Alliance arrived in Cambodia in 1923. This mission focused on indigenization. The three-self formula was (and is) widely implemented in this denomination. But the church was then supervised by missionaries, and church structure is often based on American models. Because of this, the church was perceived as an American religion.

Unfortunately during the Khmer-Rouge period (1975–79), as the whole country was plunged into genocide, Catholic and Protestant churches shared the same fate: the Khmer bishop and priests were executed, and out of forty pastors only four survived. Churches were destroyed, Christians dispersed, and the majority perished.

**The contemporary Cambodian church.** When the post-communist regime was proclaimed in Cambodia in 1991, the surviving Christians rebuilt the church. As the church grows, and as more national Christians assume leadership, it is time to think about how to contextualize church structure so that it fits local culture. Most missionaries and Cambodian leaders have noticed that evangelizing the Khmer people is easy, but keeping them

---

[11]In 1955 the Cambodian Roman Catholic Church had 120,000 members. But during the Indochinese independence process, France gave to Vietnam the Cochin China, which used to be Khmer provinces and where the majority of Cambodian Catholics live. This explains one of the reasons why modern Cambodia counts only a few hundred Catholics.

faithful to Christian living is hard. This is due to the fact that the believers do not know how to live as Christians in Khmer society, since the whole church structure is alien to Cambodians. For this reason it is important to reconsider the form of Christianity, so that the church of Christ may have a local look, rather than a French or American face.

## Understanding Khmer socio-cultural structure

The first step in the process is seeking to understand the Cambodian social structure. Cambodian society is organized according to a corporate social environment. Hierarchy is very important to Cambodians. For instance, when missionaries start to learn the Khmer language they will realize very soon that one of the main characteristics is that it is built upon a hierarchical system. Thus there are at least four levels of vocabulary. One cannot talk to God, to the king, to monks, teachers, parents, or friends, using the same vocabulary. Each set of vocabulary is used for each specific level of society.

In the traditional structure, hierarchy is based not only on the role that one may play in society but also on seniority. Wisdom is often associated with age. Normally a young man is not in a good position to teach elderly people. Missions have a tendency to focus their effort on training young people, because of their ability to learn the western way. The elderly people are neglected; as a result they think that evangelism or other tasks for God are a young person's job. Consequently, the church has lost a natural way to impact its community. In a society like Cambodia's, we should not neglect and underestimate the importance of the elderly.

Another important aspect that one should not overlook is that religious life in Cambodia is organized around monasticism. The concept of the church with a salaried priest or pastor working in an office is not familiar to Cambodians. For this reason, pastors are often considered more as mission employees or civil servants than religious or spiritual leaders.

## Two possible patterns

Establishing the Kingdom of God entails not only proclaiming the gospel but building a community of believers in a specific socio-cultural context. The church as a religious institution ought to be structured in a form that is culturally natural. In a hierarchical society "the cooperate interests of the group place significant constrains upon leaders."[12] The Cambodian church leadership could be structured on the two following models:

1. *Presbyterian* form: In the Khmer tradition, a position of authority and seniority often tend to be synonymous. For the instance, the king is respected not simply because he is king, but also because of his seniority. The social and religious activities are usually organized by a group of elderly lay men, the *Achars*, who lead the Buddhist community in worship and ceremonies. In the temple, they fulfill the role of mediator between the Buddhist monks and the believers. (Since a Christian pastor looks like a layman, in contrast to a Buddhist monk, he is often named the *Achar* by non-Christians. He is thus perceived as less important than a monk.) .The *Achars* normally have a secular job; their involvement in religious life is merely voluntary.

A church organized with a "Council of Elders" may have more impact on the community than a church led by a sole pastor. Such a structure would not only be familiar to the Khmer people, but its foundation closely reflects the New Testament pattern. Furthermore, the requirements of the elders can also be found in the Scripture.[13]

2. *Monastic* form: Traditionally, the Cambodian pagoda is central not only for religious life, but also for social and educational life, where a group of people live together as a learning, praying, and meditating community. Young monks gather around elder priests and commit themselves to live in poverty and chastity (at least in theory). They spend their time in meditating and learning the Buddhist scriptures. But unlike

---

[12]Lingenfelter, *Transforming Culture*, 134.

[13]1Tim 3:1–7; Tit 1:5–9.

monastic life in Europe, these monks interact every day with secular society through ceremonies and teachings. They also receive their food and gifts from the population. This could be serve as a model for Cambodian Christians who want to commit themselves entirely to God without being entirely disconnected from the world. One may see connection between this lifestyle and the experience of Jesus and his disciples. The disciples gathered around the Master while learning and interacting with the population.

In the past, Benedictine monks organized monastic life Cambodian style, but they failed to flourish. I think this is due to the uncritical concept of contextualization. For instance, they practiced flagellation, which is not familiar to the Khmer people.

In the process of contextualization, only the external form should be structured with a local paradigm (perhaps also evangelism and theologizing methods), but the core of the gospel, that is salvation in Jesus Christ, must remain intact. What the people need is not a local or imported religion, but to be transformed by the gospel.

## Conclusion

An indigenized church is not simply one led by national leaders imitating western church culture. Indigenizing a church should not mean that we have to reject the principles and values of other churches. As part of the universal church we ought to live and share together our discovery in our pilgrim life with the Lord.

We must be aware that church cannot be completely integrated into its cultural setting. We cannot conform ourselves entirely to our society, lest we may go astray from the One who called us. In the process of indigenizing the church we ought to think about transforming our culture by bringing the spirit of the gospel into it, instead of bringing its spirit to the gospel. "Transformation is neither bridging form one system to another or transferring a Christian system to another place and people. Rather, transformation means a new hermeneutic—a redefinition, a

reintegration of the lives of God's people (the Church) within the system in which they find themselves living and working."[14]

[14]Lingenfelter, *Transforming Culture*, 18.

សំណុំឱកឃ្មុំ ២/១ (មករា ២០០១)៖ ១១១-១២៨

# ការធ្វើឲ្យពួកជំនុំក្នុងស្រុកមានលក្ខណៈម្ចាស់ការ

## ការឆ្លុះបញ្ចាំងមួយទៅលើរចនាសម្ព័ន្ធពួកជំនុំកម្ពុជា

សុខ ញិម *អារុណា*

### សេចក្តីផ្តើម

គោលគំនិតស្តីពីការបង្កើតពួកជំនុំឲ្យមានលក្ខណៈម្ចាស់ការ គឺមិនមែនជារឿងថ្មីចំពោះគ្រីស្ទបរិស័ទទេ ។ យើងបានអានពីរឿងនេះ តាំងតែពីព័ន្ធកិច្ចដើមដំបូង របស់លោកសាវ័ក ប៉ូល នៅក្នុងកណ្ឌគម្ពីរកិច្ចការ ។ កាលកំពុងបន្តទំនាក់ទំនងយ៉ាងជិតស្និទ្ធ ជាមួយពួកជំនុំមេនៅស្រុកយូដា ពួកជំនុំសាសន៍ដទៃទាំងឡាយបានជួបការលំបាក ក្នុងការទទួលយកការអនុវត្តន៍នានារបស់ជនជាតិជ្វីហ្វ (យូដា) ដូចជា ការកាត់ស្បែកជាដើម ។ លោក ប៉ូល ដែលជាសាសនទូតម្នាក់សំរាប់សាសន៍ដទៃ បានយល់ពីសេចក្តីត្រូវការរបស់សាសាន៍ដទៃ ក្នុងការធ្វើជាម្ចាស់ការរបស់ពួកគេ ។ លោកបានការពារផលប្រយោជន៍របស់ពួកគេ និងបានធ្វើឲ្យពួកគ្រីស្ទបរិស័ទយូដាជឿយ៉ាងស៊ុប ដោយមិនរំលោភលើទំនៀមទំលាប់ និង ជីវភាពផ្ទាល់ខ្លួនរបស់ពួកគេទៅលើពួកសាសន៍ដទៃឡើយ (កិច្ចការ ១៥) ។

នៅគ្រប់ទីកន្លែង ដែលដំណឹងល្អត្រូវបានប្រកាសផ្សាយ នោះជំនឿគ្រីស្ទបរិស័ទត្រូវតែធ្វើការឆ្ពោះទៅរកការបង្កើតពួកជំនុំដើមមួយ ។ បច្ចុប្បន្ននេះ វប្បធម៌ពួកជំនុំហាក់ដូចជា កំពុងរំកិលទៅរកពួកលោកខាងលិច ជាពិសេសអាម៉េរិកាំង គឺថាចម្លងតាមតន្ត្រី ការថ្វាយបង្គំ រចនា

សម្ព័ន្ធ យុទ្ធសាស្ត្រ វិធីសាស្ត្រផ្សាយដំណឹងល្អ ។ល។ និន្នាការទាំងនេះ ក៏កើតមានឡើងផងដែរនៅក្នុងប្រទេសកម្ពុជា ។

គួរឲ្យស្ដាយក្នុងដំណើរការនៃការបង្កើតពួកជំនុំ មិនមែនគ្រាន់តែជាដំណឹងល្អ និង ជាគតិលោករបស់គ្រីស្ទបរិស័ទមួយ ដែលបានបញ្ជូន ឬជះឥទ្ធិពលប៉ុណ្ណោះទេ តែថែមទាំងវប្បធម៌ពួកជំនុំលោកខាងលិចផងដែរ ។ ជាលទ្ធផល និង ជារូបភាពធំ ពួកជំនុំកម្ពុជាហាក់បីដូចកាត់ផ្ដាច់ចេញពីវប្បធម៌ និង សង្គមរបស់ខ្លួន ដែលប្រការនេះធ្វើឲ្យពួកអ្នកជឿស្ថិតនៅក្រោមសម្ពាធ គឺថាពួកគេត្រូវបានរហែកជាពីរ ដោយសារប្រព័ន្ធវប្បធម៌ដែលបានបញ្ជូនមកដោយសារពួកសាសនទូត និងប្រព័ន្ធវប្បធម៌ផ្ទាល់របស់ពួកគេ ។ គ្រីស្ទបរិស័ទត្រូវបានជនរួមជាតិរបស់ខ្លួន ចាត់ទុកថាជាជនក្បត់ ហើយក្លាយជាជនចម្លែក នៅក្នុងវប្បធម៌របស់ខ្លួនឯងទៀតផង ។ បេសកជនខ្លះនិងអ្នកដឹកនាំជាតិមួយចំនួន យល់ដឹងអំពីបញ្ហានៃការយកលំនាំតាមលោកខាងលិចនេះយ៉ាងច្បាស់ ប៉ុន្តែមិនដឹងពីរបៀបដែលត្រូវធ្វើការ ផ្លាស់ប្ដូរឲ្យសមរម្យទាល់តែសោះ ។

គោលបំណងនៃប្រធានបទនេះ គឺដើម្បីរៀនពីអ្វី ដែលបានចារទុកមកអំពីបរិបទូបនីយកម្ម ( ធ្វើឲ្យស៊ីនឹងស្ថានការណ៍ ) ជាមួយនឹងផលប្រយោជន៍ និង គ្រោះថ្នាក់ទាំងឡាយរបស់វា និង ដើម្បីផ្ដល់នូវការឆ្លុះបញ្ចាំងមួយ ( ប៉ុន្តែមិនមែនជាគំរូទេ ) ទៅលើរបៀបដែលពួកជំនុំកម្ពុជាអាចចាប់យកបាននូវបរិបទូបនីយកម្មត្រឹមត្រូវនេះ ។

## ការធ្វើឲ្យមានភាពម្ចាស់ការ

សព្វថ្ងៃនេះ បេសកជនទាំងឡាយត្រូវបានគេវាយតម្លៃមិនគ្រាន់តែដោយស្នាដៃរបស់ពួកគេ ក្នុងការផ្សាយដំណឹងល្អ ដល់ប្រជាជាតិមួយប៉ុណ្ណោះទេ តែក៏ដោយសារលទ្ធភាពរបស់ពួកគេក្នុងការផ្ដល់កំណើតពួកជំនុំ ដែលពួកគេបង្កើតឡើង ។ ជាលទ្ធផល សមាគមបេសកកម្មទាំងឡាយតំរង់គោលដៅរបស់ពួកគេ ឆ្ពោះទៅកាន់ការហ្វឹកហ្វឺនអ្នកដឹកនាំក្នុង

ស្រុក ដើម្បីឲ្យជនជាតិទាំងនោះអាចបន្តវេណាស្នងភាពជាអ្នកដឹកនាំនៃពួកជំនុំរបស់ពួកគេដោយខ្លួនគេបាន ។

យោងតាមលោក សូលតូ ថ្លែងថាពួកជំនុំមួយដែលមានលក្ខណៈម្ចាស់ការកាលណា "ពួកជំនុំនោះក្លាយជាម្ចាស់ស្រុក ចំពោះប្រទេសនោះ ហើយរីកលូតលាស់ជាធម្មតាជាផ្នែក និងជាភាគតូចៗនៃមនុស្ស នៅក្នុងចំណោមដែលពួកជំនុំត្រូវបានបង្កើតឡើង[១]"

លោក ស្មាលី ឲ្យអត្ថន័យថា ពួកជំនុំមួយដែលមានលក្ខណៈម្ចាស់ការគឺជា "អ្នកជឿមួយក្រុម ដែលមានជីវិតរស់នៅ ដោយរាប់បញ្ចូលទាំងសកម្មភាពសង្គមរបស់គ្រីស្ទបរិស័ទ នៅក្នុងគំរូនៃសង្គមមូលដ្ឋាន និងទាំងសំរាប់អស់អ្នកណា ដែលការផ្លាស់ប្តូរណាមួយរបស់សង្គមនោះកើតចេញពីសេចក្តីត្រូវការ ដែលស្ថិតនៅក្រោមការដឹកនាំរបស់ព្រះវិញ្ញាណ និង បទគម្ពីរ[២]" ។

ទោះជាយ៉ាងណាក៏ដោយ នៅក្នុងការអនុវត្តន៍ជាក់ស្តែង ពួកជំនុំមូលដ្ឋានមួយត្រូវបានគេវិនិច្ឆ័យថាជា ពួកជំនុំម្ចាស់ការ ឬ មិនមែនដោយអាស្រ័យលើស្វ័យភាពរបស់ពួកជំនុំ ក្នុងភាពជាអ្នកដឹកនាំ ហិរញ្ញវត្ថុ និងការផ្សព្វផ្សាយដំណឹងល្អ ដែលជាញឹកញាប់ត្រូវបានគេឲ្យឈ្មោះថា *រូបមន្តត្រីស្វ័យភាព*: "ស្វ័យាភិបាល ស្វ័យូបត្ថម្ភ និង ស្វ័យបេសកកម្ម" ។

ពួកជំនុំស្វ័យាភិបាល មិនមែនសុទ្ធតែជាពួកជំនុំដែលមានលក្ខណៈម្ចាស់ការទេ ពីព្រោះអ្នកដឹកនាំជាតិនោះជាញឹកញាប់ត្រូវបានហ្វឹកហ្វឺន នៅក្នុងគំរូនៃការគ្រប់គ្រងរបស់ពួកជំនុំបែបលោកខាងលិច ។ ពួកគេមិនត្រូវបានណែនាំយ៉ាងពិតប្រាកដ ក្នុងការរៀបចំពួកជំនុំចេញពីទស្សនៈវប្បធម៌

---

[1] T. S. Soltau, *Missions at the crossraods* (Grand Rapids: Baker, 1994), 20.

[2] Article in *Perspectives on the World Christian Movement,*ed. R.D. Winter and S. C. Hawthrone (Pasadena: William Carey Library, 1981), 497

និង សង្គមផ្ទាល់របស់ពួកគេទេ តែបែរជាត្រាប់តាមទាំងងងឹតងងុលនូវវប្បធម៌ពួកជំនុំលោកខាងលិច ។ តាមការពិត ម្ចាស់ស្រុកជាញឹកញាប់បំរើក្នុងនាមជាអ្នកដឹកនាំមានតែឈ្មោះ ក្នុងខណៈដែលពួកបេសកជនប្រតិបត្តិនូវអំណាចពិតប្រាកដទៅលើពួកជំនុំមូលដ្ឋាន ដោយសារតែការផ្គត់ផ្គង់ខាងហិរញ្ញវត្ថុ ដែលពួកគេផ្តល់ឲ្យ ។ ជារឿយៗ "ស្វ័យបត្ថម្ភ" ត្រូវបានគេចាត់ទុកថាជា បារ៉ូម៉ែត្រនៃជោគជ័យ (ជោគជ័យមានតែក្នុងគំនិត) ក្នុងការធ្វើឲ្យមានលក្ខណៈម្ចាស់ការ ។ ពួកជំនុំជាតិត្រូវបានលើកទឹកចិត្តឲ្យបំពេញសេចក្តីត្រូវការរបស់ពួកគេខាងផ្នែកហិរញ្ញវត្ថុ និងផ្គត់ផ្គង់អ្នកដឹកនាំរបស់ពួកគេ ។ ពួកគេក៏ត្រូវបានលើកទឹកចិត្តផងដែរ ក្នុងការស្ថាបនាយុទ្ធសាស្ត្រមូលដ្ឋានទាំងឡាយ ដើម្បីប្រកាសដំណឹងល្អ ជាមួយប្រជារាស្ត្ររបស់ពួកគេផ្ទាល់ ។ ប៉ុន្តែវិធីសាស្ត្រទាំងឡាយ ដែលបានប្រើទោះជាបញ្ហាខាងហិរញ្ញវត្ថុ ឬនៅក្នុងយុទ្ធសាស្ត្រនៃការផ្សាយដំណឹងល្អក្តី (ការប្រកាសដំណឹងល្អជាទ្រង់ទ្រាយធំ ការធ្វើយុទ្ធនាការ ។ល។ ) គឺជាញឹកញាប់មិនខុសពីពួកលោកខាងលិចឡើយ ។

ប៉ុន្តែការធ្វើឲ្យមានលក្ខណៈម្ចាស់ការ តម្រូវឲ្យមានច្រើនលើសជាងរូបមន្តត្រីស្វ័យភាពនេះទៅទៀត គឺថាវាតម្រូវឲ្យមានការឆ្លុះបញ្ចាំងដ៏ស៊ីជំរៅទៅលើពួកជំនុំជាតិមួយ ហើយនិង ការវាយតម្លៃអំពីអត្តសញ្ញាណវប្បធម៌របស់ពួកជំនុំជាតិមួយនោះដែរ ។ ប្រការនេះហើយ ដែលនាំទៅរកជំហានបន្ទាប់ ហើយប្រហែលជាជំហានមានលក្ខណៈដ៏មានសារៈសំខាន់ក្នុងដំណើរការ នៃការធ្វើឲ្យមានលក្ខណៈម្ចាស់ការ មានន័យថា ការធ្វើឲ្យស៊ីនឹងស្ថានការណ៍ដ៏ត្រឹមត្រូវ ។

## បរិបទូបនិយកម្ម

យោងតាមលោក លីងហ្សង់ហ្វីលទ័រ ឲ្យអត្ថន័យថា បរិបទូបនីយកម្មត្រឹមត្រូវគឺការដាក់ក្របខ័ណ្ឌដល់រាជសារនៃដំណឹងល្អជាភាសាហើយការប្រាស្រ័យទាក់ទងបង្កើតឡើងយ៉ាងសមរម្យ និង មានអត្ថន័យចំពោះ

វប្បធម៌ និង ដើម្បីផ្តោតទៅលើសារនៃព្រះបន្ទូល ដែលជាបញ្ហាសំខាន់នៅក្នុងជីវិតរបស់បណ្តាជន[៣]" ។

បរិបទូបនីយកម្មៈ ប្រតិកម្មចំពោះអាណានិគមនិយម គួរឲ្យស្តាយកាលពីអតីតនៅក្នុងប្រវត្តិសាស្ត្រនៃបេសកកម្មកន្លងទៅ ត្រូវបានផ្សារភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងអាណានិគមនិយម ។ បេសកកម្មបានបើកទ្វារសំរាប់ការធ្វើអាណានិគមរបស់លោកខាងលិច ហើយការធ្វើអាណានិគមទៀតសោតអនុញ្ញាតឲ្យសាសនទូត បង្កើតពួកជំនុំនៅតាមតំបន់ដែលដាច់ស្រយាលនៃផែនដី ។

នៅក្នុងសករាជនៃអាណានិគម ការពើបប្រទះរវាងលោកខាងលិច និង ប្រជាជាតិដទៃទៀត បានហុចលទ្ធផលឧត្តមភាពពួកស្បែកស ប្រើអំណាចគ្របដណ្តប់លើម្ចាស់ស្រុក ដោយសារតែភាពជឿនលឿនផ្នែកបច្ចេកវិជ្ជា និង វិទ្យាសាស្ត្ររបស់ពួកគេ ។ ផលវិបាកដែលកើតឡើងវប្បធម៌លោកខាងលិច ត្រូវបានចាត់ទុកថា ខ្ពស់ជាងវប្បធម៌របស់ម្ចាស់ស្រុក ហើយជាញឹកញាប់វាត្រូវបានគេឲ្យឈ្មោះយ៉ាងសាមញ្ញថា "វប្បធម៌ឧត្តម" ផ្ទុយទៅនឹងវប្បធម៌ម្ចាស់ស្រុក ដែលត្រូវគេឲ្យឈ្មោះថា "វប្បធម៌ចាស់គំរិល" ។

នៅក្នុងអំឡុងពេលនោះ ពួកសាសនទូតបានទទួលឥទ្ធិពល ដោយសារស្មារតីនៃសម័យកាលរបស់ពួកគេ។ ពួកគេបានរៀបចំគំរូពួកជំនុំតាមវប្បធម៌លោកខាងលិច ។ នៅក្នុងហេតុផលរបស់ពួកគេគឺថា "ឧត្តមភាពរបស់ពួកលោកខាងលិចខ្ពស់ជាងវប្បធម៌ដទៃ បានសឲ្យឃើញពី ឧត្តមភាព នៃគ្រីស្តបរិស័ទទៅលើពាហិរសាសនានៃពួកអ្នកមិនជឿព្រះគ្រីស្ត[៤]" ហើយប្រជាជាតិ "អន់ថយ" ទាំងនេះ ពិតជាមិនគ្រាន់តែត្រូវការសេចក្តី

---

[3] Sherwood G. Lingenfelter, *Transforming Culture—A challenge for Christian Mission* (Grand Rapids: Baker, 1998), 1

[4] P. G. Hiebert, *Anthropological Reflections on Missiological Issues* (Grand Rapids: Baker, 1994), 55.

សង្គ្រោះប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវការអារ្យធម៌ផងដែរ! ជាតួយ៉ាង "នៅក្នុងឆ្នាំ ១៨៩០ លោក ធ. វ. ភាស (T. W. Pearce) បានបង្ហាញថា គ្រាន់តែណែនាំជំនឿគ្រីស្ទបរិស័ទដល់សាធារណរដ្ឋប្រជាមានិតចិន គឺវាមិនគ្រប់គ្រាន់ទេ គឺអារ្យធម៌លោកខាងលិចទាំងមូល បានគ្របដណ្តប់អារ្យធម៌ចិន[5]" ព្រោះហេតុផលនេះ សូម្បីតែសព្វថ្ងៃនេះនរណាម្នាក់ក៏អាចសំគាល់ថា វប្បធម៌លោកខាងលិចបានជ្រាបចូលយ៉ាងធ្ងន់ធ្ងរទៅក្នុងពួកជំនុំចិន ។

នៅក្នុងស្មារតីដូចគ្នានេះ ពួកគេបានបកប្រែព្រះគម្ពីរប៊ីប ដោយប្រើគោលការណ៍បកប្រែតាមពាក្យត្រង់ៗ (ជារឿយៗតាមព្រះគម្ពីរ ឃីង ជែម វឺរស្សិន "King James Version" ) ហើយមិនខ្វាយខ្វល់អំពីភាពផ្ទុយគ្នា ឬភាពសមហេតុផលនៃវប្បធម៌របស់ភាសា ដែលត្រូវទទួលយក ។ ជាញឹកញាប់ការធ្វើបន្ទាល់ដំណឹងល្អ ត្រូវបានភ្ជាប់ការបង្រៀនភាសាអង់គ្លេសប្រយោជន៍ឲ្យអ្នកជឿថ្មីអាចរកការងារបានល្អ ហើយទទួលបានជីវភាពរស់នៅខ្ពស់ជាងមុន ។ ដូច្នោះ ការសាបព្រោះវប្បធម៌អង់គ្លេសូបនីយកម្ម ជួនកាលត្រូវបានទទួលដោយពួកសាសនទូត និង ពួកម្ចាស់ស្រុកនោះថា មានឧត្តមភាពជាងវប្បធម៌ក្នុងស្រុក ។

ដូច្នេះ ថ្វីដ្បិតតែសម័យអាណានិគម បន្សល់ទុកនូវទិដ្ឋភាពអវិជ្ជមាន (ចំណុចអាក្រក់) ដូចជាភាពក្រអឺតក្រទម និង ការបែងចែកក្រុមបក្ខក៏ដោយ ក៏យើងត្រូវតែទទួលស្គាល់ផងដែរ នូវទិដ្ឋភាពវិជ្ជមាន (ចំណុចល្អ) នៃសម័យកាលនោះដូចជាការប្រកាសដំណឹងល្អ បានធ្វើឲ្យគេពុស្មុះសាយ ទោះប្រកាសផ្សព្វផ្សាយដោយរបៀបណាក៏ដោយ[6] ការសាបព្រោះវប្បធម៌អង់គ្លេសូបនីយកម្ម គេបានបកប្រែព្រះគម្ពីរប៊ីប ជាច្រើនភាសា គេបានស្ថាបនាពួកជំនុំ មន្ទីរពេទ្យ និង ប្រព័ន្ធសិក្សាអប់រំជាច្រើន ។

---

[5] Ibid.

[6] *ភីលីព ១:១៨*

ប៉ុន្តែចលនាប្រឆាំងនឹងអាណានិគម បានបញ្ចប់នូវការបែងចែកពូជសាសន៍នៅក្នុងពួកជំនុំ ដែលយ៉ាងហោចណាស់ក៏បានបញ្ចប់ក្នុងការបែងចែកសីលធម៌ផងដែរ ។ ឧត្តមភាពនៃវប្បធម៌របស់លោកខាងលិច ត្រូវបានគេចោទសួរគ្រីស្ទបរិស័ទ លោកខាងលិចក៏ចាប់ផ្តើមយល់ដឹងរវាងដំណឹងល្អ និង វប្បធម៌របស់ខ្លួន ។ ពួកគេក៏ចាប់ផ្តើមទទួលយកវប្បធម៌របស់ម្ចាស់ស្រុកយ៉ាងហ្មត់ចត់ ហើយបានស្វែងយល់អំពីវប្បធម៌នោះ ។ បន្ទាប់មកពួកបេសកជន បានលើកទឹកចិត្តអ្នកដឹកនាំក្នុងស្រុកឲ្យប្រកាសដំណឹងល្អឲ្យស៊ីនឹងស្ថានការណ៍ និង ស្របតាមទេវសាស្ត្រក្នុងស្រុក ។ ពួកជំនុំមូលដ្ឋានត្រូវតែស្វែងរកនូវ "ការផ្សារភ្ជាប់ព្រះរាជសារនៃ (អត្ថបទ) ដំណឹងល្អឲ្យស៊ីនឹងវប្បធម៌ក្នុងតំបន់របស់ខ្លួន *(បរិបទ)* ។ អត្ថបទ និង បរិបទ ត្រូវតែលាយបញ្ចូលគ្នា ឲ្យក្លាយទៅជាតែមួយ ដែលជាសេចក្តីពិតដែលព្រះទ្រង់ប្រាថ្នា គឺបានហៅថា ការរស់នៅរបស់គ្រីស្ទបរិស័ទ[7]" ។

**គ្រោះថ្នាក់នៃបរិបទូបនិយកម្ម:** ទោះជាយ៉ាងណាក៏ដោយ ក៏បរិបទូបនីយកម្មត្រឹមត្រូវ មានចំណុចខ្សោយរបស់វាដែរ ជាពិសេសនៅពេលមានទំនោរមួយទៅរកការទទួលយកនូវវប្បធម៌ទាំងអស់ថាល្អ ។ គេក៏ទទួលស្គាល់ថាសាសនាដទៃទៀត ក៏ជាការបើកសម្តែងមកពីព្រះជាម្ចាស់ដែរ ដូច្នេះការនេះក៏បើកទ្វារ ឲ្យមានការរិះគន់យ៉ាងចម្រូងចម្រាសចូលមក ។ ហេតុដូច្នេះបានជាឯកលក្ខណៈភាព (លក្ខណៈពិសេស) របស់ព្រះគ្រីស្ទ និង សេចក្តីសង្គ្រោះរបស់ព្រះអង្គត្រូវបានចោទសួរយ៉ាងខ្លាំងៗ ។ គេបានបង្ហាញឲ្យឃើញថា ព្រះគ្រីស្ទអាចជាផ្លូវមួយទៅកាន់ព្រះបិតាតែមិនមែន ជាផ្លូវតែមួយគត់នោះឡើយ ។ ការនេះអាចនាំទៅកាន់ភាពជ្រុល

---

[7] L. Luzbetak, *the Church and Cultures,* (Maryknoll, New York: Orbis, 1988),72

និយម ដទៃទៀតផងដែរ គឺការបដិសេធចោលអ្វីៗទាំងអស់ពីលោកខាងលិច ស្វមរ្បីតែគោលការណ៍ល្អៗ នៃវប្បធម៌លោកខាងលិចក៏ដោយ ។

**បរិបទូបនីយកម្មដ៏សំខាន់:** ដើម្បីឲ្យទទួលផលប្រយោជន៍ពីបរិបទូបនីយ-កម្ម និង ដើម្បីចៀសវាងនូវគ្រោះថ្នាក់ ដែលកើតពីការអូសទាញ ដំណើរការបរិបទូបនីយកម្មត្រូវតែធ្វើឡើងដោយប្រុងប្រយ័ត្ន ។ ខ្ញុំគិតថាភារកិច្ចនៃបរិបទូបនីយកម្ម គួរតែទទួលយកដោយអ្នកដឹកនាំក្នុងស្រុក និង សាសនទូត (យកល្អគឺចេញពីជនជាតិផ្សេងៗ) ជាមួយគ្នាទើបបាន ។ អ្នកដឹកនាំក្នុងស្រុកម្នាក់មានលទ្ធភាពក្នុងការស្វែងយល់ និង មានអារម្មណ៍ដឹងថាអ្វីល្អ ឬ អាក្រក់នៅក្នុងវប្បធម៌របស់ខ្លួន ។ ប៉ុន្តែតួនាទីនៃសាសន-ទូតក៏មានសារៈសំខាន់ណាស់ដែរ ក្នុងការផ្តល់ក្របខ័ណ្ឌអ្វីមួយ ។ មុនពេលធ្វើការដឹកបំផុសវប្បធម៌មួយ គេគួរតែស្វែងរកឲ្យយល់ជាមុននូវវប្បធម៌នោះ ។

លោក ខ្វាស្ត[8] ជឿថា ការយល់ដឹងពីវប្បធម៌មួយគឺដូចជាបកសំបកមួយស្រទាប់ម្តង ។ សំបកទី១ គឺការសិក្សាអំពីអាកប្បកិរិយារបស់មនុស្ស សំបកទី២ គឺការយល់ដឹងអំពីតម្លៃរបស់ពួកគេ ។ បន្ទាប់មក អ្នកឈានទៅរកកម្រិតដ៏ជ្រៅមួយ នៃជំនឿដែលពួកគេប្រកាន់យកថា ជាសេចក្តីពិត ។ ទីបំផុត អ្វីដែលជាជម្រៅនៃបេះដូងរបស់វប្បធម៌ណាមួយគឺជា *គតិលោក* របស់ពួកគេនោះឯងគឺអ្វីដែលជាការពិតចំពោះពួកគេ ។ ចំណុចចុងក្រោយនេះ យើងត្រូវតែលើកយកមកពិចារណា នៅពេលប្រកាសដំណឹងល្អ ។

លោក ហេសិលគ្រេវ[9] វែកញែកថា សាសនទូតមានប្រវត្តិវប្បធម៌ផ្ទាល់ខ្លួនគាត់ ដែលតំណាងគតិលោក និង មាត្រដ្ឋាននៃការឲ្យតម្លៃ របស់

---

[8] In an article published in C. H. Kraft and T. N. Wisley. eds., Readings in Dynamic Indigeneity (Pasadena: William Carey Library, 1979).
[9] In an article published in Kraft and Wisley, *Readings*.

គាត់ផ្ទាល់ ។ គាត់ខ្លួនឯងបានទទួលសារពីព្រះគម្ពីរប៊ីប ឋិតក្នុងបរិបទនៃវប្បធម៌ជាក់លាក់របស់គាត់ ។ នេះជា "វប្បធម៌របស់សាសនទូត" ។ គាត់ត្រូវតែបញ្ជូនសារនេះទៅកាន់វប្បធម៌មួយផ្សេងទៀត ជាមួយនឹង គតិលោក និង ប្រព័ន្ធតម្លៃដាច់ដោយឡែករបស់វប្បធម៌នោះ ។ នេះជា "ចំណុចដៅវប្បធម៌គោលដៅ" ។ សេចក្ដីល្បួង ដែលកើតមានឡើងក្នុងការបញ្ជាំងប្រវត្តិវប្បធម៌របស់សាសនទូតទៅលើដំណើរការ ហើយធ្វើឲ្យស្រពិចស្រពិលដល់អត្ថន័យដើម នៃសាររបស់ព្រះគម្ពីរប៊ីប ។ សាសនទូត ត្រូវតែលើកយកមកពិចារណានូវចំណុចស្នូល នៃវប្បធម៌ជាមួយនឹងប្រព័ន្ធនៃតម្លៃរបស់វា ។ គាត់ត្រូវតែចងចាំថាគំនិតទាំងឡាយនៃវប្បធម៌នេះមានកម្រិតខ្លាំងក្លាដូចគ្នានឹងវប្បធម៌ផ្ទាល់ខ្លួនរបស់គាត់ដែរ ។ អ្នកស្ដាប់គាត់ នឹងផ្ដោតការយល់ដឹងផ្ទាល់ខ្លួនរបស់គេ ទៅក្នុងសារនៃព្រះគម្ពីរប៊ីប ។ សាសនទូតត្រូវតែស្ទិតស្ទាញក្នុងការប្រាស្រ័យទាក់ទងតាមមធ្យោបាយមួយ ដែលទាក់ទងយ៉ាងស៊ីជម្រៅដល់វប្បធម៌គោលដៅ នៅពេលដែលគាត់នៅតែរក្សា ដោយស្មោះត្រង់ចំពោះសារដើមដំបូង ។ ភារកិច្ចនេះគឺជា ការងារចំពោះមុខមួយដ៏លំបាកបំផុត ។

ដូច្នេះសាសនទូតមានការទទួលខុសត្រូវធ្ងន់ធ្ងរណាស់ នៅពេលដែលគាត់ដឹកនាំនិងហ្វឹកហ្វឺនអ្នកដឹកនាំក្នុងវប្បធម៌ ដែលគេអើពើទទួលយក ។ គ្រូគង្វាលក្នុងស្រុកជារឿយៗបានបង្ហាញឲ្យឃើញកាន់តែអាក្រក់ឡើងក្នុងការផ្សាយសារនៃដំណឹងល្អបែបលោកខាងលិច ដោយមានការស៊ីចង្វាក់បន្តិចបន្តួចជាមួយវប្បធម៌របស់ពួកគេផ្ទាល់ ។ ផលវិបាកដែលកើតឡើង គឺគ្រោះថ្នាក់ផង និង ស្និតស្នេរផង ។ អ្វីដែលបានចងហើយពិបាកនឹងស្រាយវិញខ្លាំងណាស់ ។

លោក ហេសិលគ្រេវ ជឿថាការប្រាស្រ័យទាក់ទងរវាងសាសនទូតនឹងវប្បធម៌ដែលគេដៅទុក ជាញឹកញយជាល្ខោន ដែលតួសំដែងនិយាយតែម្នាក់ឯង-គឺមានន័យថា សាសនទូតនិយាយតែងគ្មានអ្នកឆ្លើយ

តប ។ សាសនទូត មានទំនាក់ទំនងទៅនឹងសារដោយគ្មានការព្យាយាមយល់ពីវប្បធម៌ និង គតិលោក របស់អ្នកឆ្លើយតបសោះ ។

គ្មានផលចំណេញអ្វីកើតឡើងពីការចំអក ឬ ចង្អុលទៅកាន់ភាពមិននឹងនក្នុងជំនឿផ្សេងៗនោះឡើយ ។ សារនៃដំណឹងល្អ ជាសារដែលមានលក្ខណៈសកល ។ សាររបស់គ្រីស្ទបរិស័ទនៅតែដូចគ្នា គ្រប់ពេលទាំងអស់ និង គ្រប់វប្បធម៌ទាំងអស់ ។ បរិបទូបនីយកម្មមានសារៈសំខាន់ចំពោះសារដែលគេអាចយល់បាន និង ទទួលយកបាន ។

នៅក្នុងការសិក្សាអំពីករណីពួកជំនុំកម្ពុជា ខ្ញុំចង់ផាត់ចេញទៅម្ខាងនូវទិដ្ឋភាពខាងទេវសាស្ត្រនៃបរិបទូបនីយកម្ម ហើយខ្ញុំចង់សង្កត់ន័យឲ្យខ្លាំងទៅលើរចនាសម្ពន្ធបែបស្ថាប័ននៃពួកជំនុំ ដែលមានលក្ខណៈម្ចាស់ការ ។

## ពួកជំនុំកម្ពុជា

សង្គមនីមួយៗ គឺជាប្រព័ន្ធមួយ ។ ដើម្បីនឹងដំណើរការដោយមានប្រសិទ្ធិភាព ប្រព័ន្ធណាមួយក៏ដោយត្រូវតែមានតុល្យភាព និង ស៊ីចង្វាក់គ្នា ។ បើនិយាយតាមលោក ម៉េយឺរ ( Mayers) "ផ្នែកទាំងអស់នៃប្រព័ន្ធរមែងទាក់ទិនទៅនឹងប្រព័ន្ធទាំងមូល ហើយផ្តល់អត្ថន័យទៅដល់ប្រព័ន្ធនោះ ។ បើនិយាយបញ្ច្រាសមកវិញ ប្រព័ន្ធទាំងមូលផ្តល់អត្ថន័យដល់ផ្នែកនីមួយៗរបស់ប្រព័ន្ធ ។ បើគ្មានប្រព័ន្ធទាំងមូល នោះផ្នែកនីមួយៗគ្មានហេតុផលអ្វីនឹងនៅស្ថិតស្ថេរបានទេ ហើយបើគ្មានផ្នែកណាមួយរបស់ប្រព័ន្ធទេ នោះក៏គ្មានប្រព័ន្ធទាំងមូលដែរ"[១០] ។

ពួកជំនុំមូលដ្ឋានមួយ ជាផ្នែកខាងវិញ្ញាណនៃអាណាចក្រព្រះផង និង ជាផ្នែកនៃក្រុមសង្គមវប្បធម៌ជាក់លាក់មួយផងដែរ ។ ព្រះជាម្ចាស់

---

[10] M. Mayers, Christianity Confronts Culture (Grand Rapids: Zondervan, 1987), 95.

គ្រាស់ហៅពួកជំនុំគឺ បំផ្លាស់បំប្រែសង្គមបរិយាកាស ដោយសារជំណើងល្អ ដោយមិនចាំបាច់ចម្លងតាមប្រព័ន្ធសង្គមវប្បធម៌បរទេសនោះឡើយ ។

ពួកជំនុំកម្ពុជាអាចបង្ហាញអំពីសុឆន្ទៈ ក្នុងការធ្វើឲ្យពួកជំនុំមានភាពម្ចាស់ការ ចំណែកឯសាសនទូតវិញ កំពុងព្រលែងតួនាទីដឹកនាំដល់គ្រីស្ទបរិស័ទខ្មែរ ។ តែខ្មែរ ដែលមិនមែនជាគ្រីស្ទបរិស័ទវិញ គេនៅតែចាត់ទុកពួកជំនុំខ្មែរថា គ្មានលក្ខណៈជាតិត្រង់ណាសោះ ដោយហេតុថាវប្បធម៌ និង រចនាសម្ព័ន្ធ ដូចជាស្ថាប័នរបស់ពួកជំនុំខ្មែរ មានលក្ខណៈចម្លែកចំពោះមហាជនជាទូទៅពេក ។ កាលដែលជនជាតិខ្មែរម្នាក់ក្លាយខ្លួនមកជាគ្រីស្ទបរិស័ទនោះ មិនមែនជាការងាយស្រួលប៉ុន្មានទេ គឺគាត់មិនគ្រាន់តែពិសោធនូវការផ្លាស់ប្រែខាងវិញ្ញាណប៉ុណ្ណោះទេ គាត់ថែមទាំងត្រូវសម្របខ្លួនតាមវប្បធម៌របស់ពួកជំនុំលោកខាងលិច ។ ដោយហេតុដូច្នេះឯងទើបពួកជំនុំភាគច្រើនមានការពិបាកក្នុងការបង្កើតសិស្ស ចេញពីចំណោមអ្នកជឿថ្មី ។ អ្នកជឿថ្មីអាចមានទំនោរចង់ត្រឡប់ទៅពុទ្ធសាសនាវិញ បន្ទាប់ពីដាក់ខ្លួនមួយរយៈខ្លីក្នុងជំនឿគ្រីស្ទបរិស័ទនោះមក ។ ខ្ញុំគិតថា បាតុភូតនេះកើតឡើងដោយសារយកការអាឡោះអាល័យចំពោះវប្បធម៌ចាស់ ពីព្រោះពួកជំនុំមិនអើពើចំពោះសារៈសំខាន់បរិបទវប្បធម៌របស់ពួកជំនុំ ។ ខ្ញុំជឿថា ដោយគ្មានការបញ្ចូលបរិបទដ៏ត្រឹមត្រូវទេ គឺគ្មានប្រសិទ្ធិភាពឡើយ ។

**ការរៀនពីប្រវត្តិសាស្ត្រ** សាសនទូតព័រទុយហ្គោ ដូមីនីកាំង បានមកដល់ក្នុងប្រទេសកម្ពុជាក្នុងពាក់កណ្ដាលសតវត្សទី ១៦ ។ ពុទ្ធសាសនាបានចូលមកដល់ស្រុកខ្មែរបីបួនសតវត្សមុន ហើយរីកលូតលាស់រហូតទាល់តែស៊ីជាច់សាសនាហិណ្ឌូ ហើយត្រូវបានគេទទួលស្គាល់ថា ជាសាសនាជាតិថែមទៀត ។ ជំនឿគ្រីស្ទបរិស័ទ មិនដែលបានសម្រេចជោគជ័យរបៀបនេះឡើយ ។ ពុទ្ធសាសនាបានទទួលជោគជ័យ ដោយសារការធ្វើឲ្យមានលក្ខណៈម្ចាស់ការនៅក្នុងស្រុក ។

នៅក្នុងឆ្នាំ ១៩៧៥ ព្រះសហគមន៍កាតូលិករ៉ូម៉ាំងមានសមាជិកត្រឹមតែចំនួន ពីរបីរយនាក់ប៉ុណ្ណោះ ក្នុងក្រុមរបស់ខ្លួន ។[១១] ការដឹកនាំស្ថិតនៅលើដៃរបស់លោកអភិបាល និង បូជាចារ្យបារាំង ។ គ្រីស្តបរិស័ទកាតូលិក បានទទួលរងការឈឺចាប់យ៉ាងច្រើនក្នុងការបង្កើតវប្បធម៌ព្រះសហគមន៍ក៏ដោយ ក៏សាសនទូតបារាំងហាក់បីដូចជា មិនបានត្រៀមខ្លួននឹងព្រលែងតួនាទីដឹកនាំទៅឲ្យខ្មែរក្នុងស្រុកទេ ។ មានបូជាចារ្យខ្មែរតែពីរ ឬបីនាក់ប៉ុណ្ណោះ ដែលទទួលអគ្គសញ្ញាលាបប្រេងតែងតាំង ហើយមានតែខ្មែរម្នាក់ប៉ុណ្ណោះ ដែលបានទទួលអគ្គសញ្ញាលាបប្រេងតែងតាំងឲ្យធ្វើជាអភិបាលព្រះសហគមន៍ នៅនាទីចុងក្រោយបំផុត ដោយសារតែជនបរទេសត្រូវតែចាកចេញពីប្រទេស មុនពេលខ្មែរក្រហមវាយដណ្តើមយកប្រទេស ក្នុងឆ្នាំ១៩៧៥ ។ ហេតុដូច្នេះ ប្រជាជនខ្មែរមើលឃើញថា ព្រះសហគមន៍កាតូលិកជាសាសនារបស់បារាំង ។

សាសនទូតប្រូតេស្តង់មកពីគ្រីស្តបរិស័ទ និងសម្ព័ន្ធសាសនទូត (CMA ) បានមកដល់ប្រទេសកម្ពុជា ក្នុងឆ្នាំ ១៩២៣ ។ បេសកកម្មនេះបានផ្តោតយកចិត្តទុកដាក់ លើការធ្វើឲ្យពួកជំនុំមានលក្ខណៈម្ចាស់ការក្នុងស្រុក ។ ពួកជំនុំក្នុងនិកាយនេះមានលក្ខណៈម្ចាស់ការក្នុងស្រុក ។ និកាយនេះបានហើយ និង កំពុងតែអនុវត្តនូវរូបមន្តត្រីស្វយភាពយ៉ាងទូលំទូលាយ ។ ប៉ុន្តែការគ្រប់គ្រងពួកជំនុំនៅតែស្ថិតនៅក្នុងកណ្តាប់ដៃសាសនទូត ហើយរចនាសម្ព័ន្ធរបស់ពួកជំនុំនៅតែផ្តេកផ្តួលទៅតាមគំរូពួកជំនុំ អា

---

[១១] *ក្នុងឆ្នាំ ១៩៥៥ ពួកជំនុំកាតូលិករ៉ូម៉ាំង-កម្ពុជាបានមានចំនួនសមាជិក ១២០.០០០ នាក់ ។ ប៉ុន្តែកំឡុងពេលដំណើរការឯករាជ្យឥណ្ឌូចិន បារាំងបានអោយទៅវៀតណាមនូវកូសាំងស៊ីន* (Cochin China) *ដែលធ្លាប់ជាអាណាខេត្តរបស់ខ្មែរ និង ដែលភាគច្រើនពួកកាតូលិកកម្ពុជារស់នៅទីនោះ ។ ការពន្យល់ នេះជាហេតុផលមួយ ដែលកម្ពុជាសម័យមានចំនួនពួកកាតូលិកត្រឹមតែពីរបីរយនាក់ប៉ុណ្ណោះ ។*

មេរិកាំងដដែល ។ ហេតុដូច្នេះ ប្រជាជនខ្មែរមើលឃើញថាពួកជំនុំ ប្រូតេស្តង់ ជាសាសនារបស់អាមេរិកាំង ។

គួរឲ្យស្តាយណាស់ ក្នុងអំឡុងពេលដែល ខ្មែរក្រហមត្រួតត្រាប្រទេសកម្ពុជា (១៩៧៥-១៩៧៩) ប្រទេសទាំងមូលត្រូវធ្លាក់ទៅក្នុងរបបប្រល័យពូជសាសន៍ ព្រះសហគមន៍កាតូលិក និង ប្រូតេស្តង់ទទួលរងវាសនាដូចគ្នា គឺថា លោកអភិបាលព្រះសហគមន៍បូជាចារ្យខ្មែរ និង គ្រូគង្វាលខ្មែរត្រូវខ្មែរក្រហមប្រហារជីវិតចោល ។ ក្នុងចំណោមគ្រូគង្វាលសែសិបនាក់ មានតែបួននាក់តែប៉ុណ្ណោះ ដែលនៅរស់រានមានជីវិត ។ ខ្មែរក្រហមបំផ្លាញពួកជំនុំខ្មែរខ្ទេចខ្ទី ហើយគ្រីស្តបរិស័ទខ្មែរក៏បែកខ្ញែកគ្នាអស់ហើយភាគច្រើនក៏វិនាសបាត់បង់ជីវិតអស់ ។

**ពួកជំនុំកម្ពុជាសម័យបច្ចុប្បន្ន:** ក្រោយពីរបបកុម្មុយនីស្ត បានប្រកាសទទួលស្គាល់ពួកជំនុំនៅកម្ពុជាក្នុងឆ្នាំ ១៩៩១ ពួកគ្រីស្តបរិស័ទដែលនៅរស់ បាននាំគ្នាស្ថាបនាពួកជំនុំឡើងវិញ ។ នៅពេលដែលពួកជំនុំរីកចំរើន និង នៅពេលដែលគ្រីស្តបរិស័ទជាតិឡើងកាន់កាប់ តួនាទីដឹកនាំឡើងវិញ គឺជាពេលដែលត្រូវគិត អំពីបរិបទូបនីយកម្ម នៃរចនាសម្ព័ន្ធរបស់ពួកជំនុំប្រយោជន៍ឲ្យវាស៊ីចង្វាក់គ្នានឹងវប្បធម៌ក្នុងស្រុក ។ សាសនទូតភាគច្រើន និង អ្នកដឹកនាំខ្មែរបានកត់សំគាល់ថា ការផ្សាយដំណឹងល្អទៅកាន់ប្រជាជនខ្មែរមិនពិបាកដូចមុនទៀតទេ តែគឺការថែរក្សាអ្នកជឿ ឲ្យនៅស្មោះត្រង់ក្នុងជីវភាពជាគ្រីស្តបរិស័ទឯនោះទេ ទើបជាការពិបាក ។ នេះគឺជាការពិតដែលពួកអ្នកជឿ មិនដឹងពីរបៀបរស់នៅជាគ្រីស្តបរិស័ទ ក្នុងសង្គមខ្មែរដោយហេតុថារចនាសម្ព័ន្ធរបស់ពួកជំនុំទាំងមូល មានលក្ខណៈបរទេសចំពោះប្រជាជនកម្ពុជា ។ ដូច្នេះ ការពិចារណាពីទ្រង់ទ្រាយ និង លក្ខណៈរបស់ពួកជំនុំខ្មែរ ដើម្បីធ្វើឲ្យប្រជាជនខ្មែរមើលទៅឃើញថាជាពួកជំនុំរបស់ជាតិខ្លួនមិនមែនជាពួកជំនុំបារាំង ឬ អាមេរិកាំងមានសារៈសំខាន់ខ្លាំងណាស់ ។

## ការយល់ដឹងពីរចនាសម្ព័ន្ធសង្គមវប្បធម៌ខ្មែរ

ជំហានដំបូងនៅក្នុងដំណើរការនេះ គឺការស្វែងយល់ពីរចនាសម្ព័ន្ធរបស់សង្គមខ្មែរ ។ សង្គមខ្មែរត្រូវបានរៀបចំឡើង ស្របទៅតាមបរិយាកាសសង្គមប្រមូលផ្តុំ ។ ឋានានុក្រមមានសារៈសំខាន់ណាស់ ចំពោះប្រជាជនកម្ពុជា ។ ឧទាហរណ៍នៅពេលសាសនទូតចាប់ផ្តើមរៀនភាសាខ្មែរ ពួកគេនឹងទទួលស្គាល់មួយរំពេចថា លក្ខណៈសំគាល់មួយក្នុងចំណោមលក្ខណៈ សំគាល់ចំបងទាំងឡាយរបស់ខ្មែរ គឺចាក់គ្រឹះលើប្រព័ន្ធឋានានុក្រមនេះឯង ដូច្នេះយ៉ាងតិចក៏មានបួនលំដាប់ថ្នាក់នៃវាក្យស័ព្ទខ្មែរដែរ ។ គេមិនអាចនិយាយទៅកាន់ព្រះជាម្ចាស់ ទៅកាន់ស្តេច ទៅកាន់សង្ឃ គ្រូបង្រៀន ឪពុកម្តាយ ឬ មិត្តភក្តិ ដោយប្រើវាក្យស័ព្ទដូចគ្នាបានទេ ។ វាក្យស័ព្ទនីមួយៗ ដែលគេកំណត់រួចមកហើយ ត្រូវបានគេយកមកប្រើសំរាប់លំដាប់ថ្នាក់ជាក់លាក់នីមួយៗនៅក្នុងសង្គម ។

ក្នុងរចនាសម្ព័ន្ធប្រពៃណី ឋានានុក្រមមិនគ្រាន់តែមានមូលដ្ឋានលើតួនាទី ដែលម្នាក់ៗដើរតួនៅក្នុងសង្គមប៉ុណ្ណោះទេ គឺវាផ្អែកលើភាពចាស់ទុំផងដែរ ។ ប្រាជ្ញាច្រើនតែទាក់ទងទៅនឹងអាយុរបស់មនុស្ស ។ តាមធម្មតាមនុស្សវ័យក្មេងមិនសូវមានតួនាទីល្អក្នុងការបង្រៀនមនុស្សចាស់ទេ ។ បេសកកម្មមាននិន្នាការផ្តោតទៅលើការខិតខំប្រឹងប្រែងហ្វឹកហ្វឺនមនុស្សវ័យក្មេង ដោយសារពួកគេមានសមត្ថភាពរៀនតាមរបៀបលោកខាងលិចបានយ៉ាងឆាប់រហ័ស ។ គេមិនសូវអើពើចំពោះមនុស្សវ័យចាស់ប៉ុន្មានទេ ព្រោះគេយល់ឃើញថាការផ្សាយដំណឹងល្អ ឬភារកិច្ចដទៃទៀតក្នុងការបំរើព្រះជាម្ចាស់ គឺជាការងាររបស់មនុស្សវ័យក្មេង ។ អីចឹងហើយបានជា ពួកជំនុំបាត់បង់នូវមធ្យោបាយធម្មតាមួយក្នុងការជះឥទ្ធិពលទៅលើសហគមន៍របស់ខ្លួន ។ នៅក្នុងសង្គមមួយដូចជាប្រទេសកម្ពុជា យើងមិនគួរធ្វេសប្រហែស និង មិនគួរមើលស្រាលចំពោះសារៈសំខាន់របស់មនុស្សវ័យចាស់ឡើយ ។

ចំណុចសំខាន់មួយផ្សេងទៀត ដែលមិនគួរបំភ្លេចចោលនោះ គឺថា ជីវិតខាងឯសាសនា នៅក្នុងប្រទេសកម្ពុជាត្រូវបានរៀបចំឡើងជុំវិញបុព្ជិតនិយម ។ គំនិតស្តីអំពីពួកជំនុំ ដែលជាសង្ឃ ឬ គ្រូគង្វាលមានប្រាក់បៀវត្សរ៍ដោយធ្វើការនៅក្នុងការិយាល័យ មិនធ្លាប់កើតមានឡើងចំពោះប្រជាជនកម្ពុជាទេ ។ ជារឿយៗគ្រូគង្វាលត្រូវបានគេចាត់ទុកថាជានិយោជិតរបស់ក្រុមបេសកកម្ម ឬ អ្នកបំរើការស៊ីវិលច្រើនជាង ជាអ្នកដឹកនាំខាងវិញ្ញាណ ឬ ជាអ្នកដឹកនាំសាសនា ។

### គំរូពីរដែលអាចធ្វើទៅបាន

ការកសាងអាណាចក្រព្រះ មិនគ្រាន់តែតម្រូវឲ្យប្រកាសដំណឹងល្អប៉ុណ្ណោះទេ គឺថែមទាំងការកសាងសហគមន៍នៃអ្នកជឿមួយ ក្នុងស្ថានភាពវប្បធម៌ជាក់លាក់មួយ ។ ពួកជំនុំដែលជាស្ថាប័នសាសនាមួយគួរតែរៀបចំរចនាសម្ព័ន្ធមួយ ដែលមានលក្ខណៈធម្មតាស្របតាមវប្បធម៌ ។ នៅក្នុងសង្គមបែបឋានានុក្រមមួយ "ការចាប់អារម្មណ៍រួមរបស់ក្រុម តែងតែផ្តល់សារៈសំខាន់ ទៅលើថ្នាក់ដឹកនាំ "[១២] ។ ការដឹកនាំពួកជំនុំកម្ពុជាអាចរៀបចំឡើងតាមគំរូពីរ ដូចខាងក្រោមនេះ ៖

១.*ទម្រង់ព្រឹទ្ធាចារ្យនិយម ឬ ទម្រង់ប្រេសប៊ីធីរាន:* នៅក្នុងទំនៀមទម្លាប់ខ្មែរ តួនាទីនៃសិទ្ធិអំណាច និង តួនាទីរបស់ចាស់ទុំ ច្រើនតែជារឿងតែមួយ ។ ជាតួយ៉ាង ស្តេចគឺត្រូវបានគេគោរពមិនគ្រាន់តែ ដោយសារទ្រង់ជាស្តេចប៉ុណ្ណោះទេ ប៉ុន្តែក៏ដោយសារភាពវ័យចាស់ទុំរបស់ទ្រង់ផងដែរ ។ សកម្មភាពខាងសាសនា និង សង្គម ជាធម្មតាត្រូវបានរៀបចំឡើងដោយក្រុម *ឧបាសក ចាស់ទុំ លោកអាចារ្យ* ដែលជាអ្នកដឹកនាំសហគមន៍ពុទ្ធសាសនា ក្នុងការថ្វាយបង្គំ និង ពិធីបុណ្យផ្សេងៗ ។ នៅក្នុងព្រះវិហារ លោកអាចារ្យបំពេញតួនាទីជាអ្នកកណ្តាលរវាងលោកសង្ឃខាងពុទ្ធសាសនា និង ពុទ្ធបរិស័ទចំណុះជើងវត្ត ។

---

[12] Lingenfelter, *Transforming Culture. 134*

ដោយហេតុថា គ្រូគង្វាលគ្រីស្ទបរិស័ទម្នាក់ មើលទៅដូចជាឧបាសកម្នាក់ផ្ទុយពីលោកសង្ឃពុទ្ធសាសនាមួយអង្គ អ្នកមិនជឿហៅគ្រូគង្វាលនោះថា ជាលោកអាចារ្យទៅវិញ ។ ដូច្នេះគេទទួលស្គាល់គ្រូគង្វាលមានសារៈសំខាន់តិចជាងលោកសង្ឃ ។ តាមធម្មតា លោកអាចារ្យមានការងារមនុស្សលោក ។ ប៉ុន្តែការចូលរួមរបស់ពួកគេបិតក្នុងកិច្ចការសាសនា គ្រាន់តែជាការស្ម័គ្រចិត្តប៉ុណ្ណោះ ។

ពួកជំនុំមួយ ដែលរៀបចំដោយមាន "ក្រុមប្រឹក្សាចាស់ទុំ" អាចមានឥទ្ធិពលក្នុងសង្គមច្រើនជាងពួកជំនុំ ដែលមានតែគ្រូគង្វាលម្នាក់ដឹកនាំ ។ រចនាសម្ព័ន្ធបែបនេះ មិនគ្រាន់តែប្រជាជនខ្មែរទទួលស្គាល់ទេ ប៉ុន្តែមូលដ្ឋានរបស់វាឆ្លុះបញ្ចាំងយ៉ាងជិតស្និតទៅនឹងគំរូនៃពួកជំនុំសម័យព្រះគម្ពីរសញ្ញាថ្មី ។ លើសពីនោះទៅទៀត តម្រូវការនៃអ្នកចាស់ទុំក៏យើងបានរកឃើញនៅក្នុងបទគម្ពីរផងដែរ ។[១៣]

២.*ទម្រង់នៃបុព្វជិតនិយមៈ* តាមទំនៀមទម្លាប់ពីដូនតាមក វត្តអារាមរបស់ប្រជាជនកម្ពុជា មិនគ្រាន់តែជាមជ្ឈមណ្ឌលសាសនាប៉ុណ្ណោះទេ គឺថែមទាំងជាមជ្ឈមណ្ឌលអប់រំ និង ជាខឿននៃសង្គម ដែលក្រុមមនុស្សរស់នៅជាមួយគ្នាជាសហគមន៍ ដើម្បីរៀនសូត្របន់ស្រន់ និង តាំងសមាធិរួមគ្នាជាសហគមន៍ ។ លោកសង្ឃក្មេងៗ ប្រមូលគ្នាជុំវិញលោកសង្ឃចាស់ៗ ហើយប្ដេជ្ញារស់នៅក្នុងភាពក្រខ្សត់ និង ការវៀរចាកកាមកិលេស (យ៉ាងហោចណាស់ ក៏វាមាននៅក្នុងទ្រឹស្ដីមែន) ។ ពួកគេបានចំណាយពេលរបស់ខ្លួន ក្នុងការធ្វើសមាធិ និង សិក្សាគម្ពីរព្រះពុទ្ធសាសនា ។ ប៉ុន្តែមិនដូចជាជីវិត បុព្វជិតនៅក្នុងប៉ែកអឺរ៉ុបទេ សង្ឃយើងទាំងនេះឯណោះវិញធ្វើការប្រាស្រ័យទាក់ទងរាល់ថ្ងៃជាមួយសង្គមមនុស្សក្រៅព្រះវិហារតាមរយៈពិធីផ្សេងៗ និង ការបង្រៀន ។ ពួកសង្ឃក៏ទទួល

---

[១៣] *១ធីម៉ូថេ ៣:១-៧. ទីតុស ១:៥-៩*

អាហារ និង អំណោយពីសំណាក់បណ្ដាជន ។ គំរូនេះអាចឲ្យគ្រីស្ទបរិស័ទខ្មែរ ដែលចង់ប្ដេជ្ញាចិត្ត ចំពោះព្រះជាម្ចាស់ទាំងស្រុង យកមកអនុវត្តតាម ដោយមិនចាំបាច់ផ្ដាច់ខ្លួនចេញពីសង្គមខាងក្រៅឡើយ ។ គេអាចមើលឃើញចំណងទាក់ទងរវាងជីវភាពនេះ និង បទពិសោធន៍របស់ព្រះយេស៊ូ និង ពួកសិស្សរបស់ព្រះអង្គ ។ ពួកសិស្ស បានប្រមូលផ្ដុំគ្នាជុំវិញលោកគ្រូ ដើម្បីរៀនពីគ្រូ និង រក្សាការទាក់ ទងជាមួយសង្គមខាងក្រៅផង ។

នៅក្នុងអតីតកាល ក្រុមបូជាចារ្យ បេណេឌិកទីន បានរៀបចំរបៀបរស់នៅតាមគំរូលោកសង្ឃខ្មែរ ប៉ុន្តែការនេះមិនបានជួយ ឲ្យពួកលោកចំរើនលូតលាស់ឡើយ ។ ខ្ញុំគិតថា នេះជាគំនិតបរិបទូបនីយកម្ម ដែលគ្មានសារៈសំខាន់ ដែលពួកលោកអនុវត្តនូវការធ្វើទុក្ខកិរិយា ដោយចម្លែកចំពោះប្រជាពលរដ្ឋខ្មែរ ។

នៅក្នុងដំណើរការ នៃបរិបទូបនីយកម្ម មានតែទំរង់ខាងក្រៅប៉ុណ្ណោះទេ ដែលត្រូវរៀបចំឡើង តាមរបៀបក្នុងស្រុក ដែលខុសពីនោះប្រហែលជាការផ្សាយដំណឹងល្អ និង វិធីសាស្ត្រនៃការបញ្ចូលទេវសាស្ត្រ ប៉ុន្តែស្នូលនៃដំណឹងល្អ គឺសេចក្ដីសង្គ្រោះ នៅក្នុងព្រះយេស៊ូគ្រីស្ទ ត្រូវតែរក្សាឲ្យនៅដដែល ។ អ្វីដែលពលរដ្ឋខ្មែរ ត្រូវការគឺមិនមែនសាសនាដែលនាំចូលមកពីស្រុកក្រៅ ឬ សាសនានៅក្នុងស្រុកនោះទេ ប៉ុន្តែពួកគេត្រូវការ ការបំផ្លាស់បំប្រែជីវិត ដោយសារដំណឹងល្អវិញ ។

## សរុបសេចក្ដី

ពួកជំនុំក្នុងស្រុកមួយដែលមានលក្ខណៈម្ចាស់ការ មិនមែនគ្រាន់តែជាពួកជំនុំ ដែលដឹកនាំខ្មែរគ្នាឯង ដែលចម្លងយកតាមវប្បធម៌ពួកជំនុំលោកខាងលិច តែប៉ុណ្ណោះទេ ។ ការធ្វើឲ្យពួកជំនុំមានលក្ខណៈម្ចាស់ការក្នុងស្រុក មិនមែនមានន័យថាត្រូវតែបដិសេធចោលនូវគោលការណ៍ និងតម្លៃផ្សេងៗរបស់ពួកជំនុំផ្សេងទៀតនោះទេ ក្នុងនាមយើងជាផ្នែកមួយនៃ

ពួកជំនុំសកលលោក យើងត្រូវតែរស់នៅជាមួយគ្នា ចែករំលែកគ្នានូវការរកឃើញផ្សេងៗ ក្នុងដំណើរជីវិតរបស់យើង ជាមួយព្រះអម្ចាស់ ។ យើងត្រូវតែយល់ជ្រួតជ្រាបផងថា ពួកជំនុំមិនអាចផ្សារភ្ជាប់ទាំងស្រុងជាមួយវប្បធម៌របស់ជាតិខ្លួននោះទេ ។ យើងមិនសម្របខ្លួនទាំងស្រុងទៅតាមសង្គមជាតិរបស់ខ្លួន ក្រែងលោវាបែរជានាំយើងឲ្យវង្វេងចេញពីព្រះ ដែលត្រាស់ហៅយើង ។ ក្នុងដំណើរការនៃការធ្វើឲ្យពួកជំនុំក្នុងស្រុកមានលក្ខណៈម្ចាស់ការ យើងត្រូវតែគិតគូរដល់ ការបំផ្លាស់បំប្រែសង្គមរបស់យើង ដោយនាំយកជីវិតនៃដំណឹងល្អ ទៅក្នុងសង្គមជាជាងនាំយកជីវិតរបស់សង្គមបញ្ចូលក្នុងដំណឹងល្អ "ការបំផ្លាស់បំប្រែមិនមែនជាការធ្វើស្ពាន ដើម្បីចម្លងប្រព័ន្ធមួយទៅ ប្រព័ន្ធមួយទៀតនោះទេ ហើយវាក៏មិនមែនជាការផ្ទេរប្រព័ន្ធគ្រីស្តបរិស័ទ បញ្ចូលទៅកន្លែងណាមួយ ឬប្រជាជនណាមួយនោះដែរ ។ តាមពិតទៅ ការបំផ្លាស់បំប្រែមានន័យថាការកំណត់អត្តន័យជាថ្មី ការផ្សារភ្ជាប់ជាថ្មីនៃជីវិតរបស់ពួកជំនុំ ដែលជាប្រជារាស្ត្ររបស់ព្រះជាម្ចាស់ ជាមួយនឹងប្រព័ន្ធ ដែលពួកគេឃើញខ្លួនឯងរស់នៅ និងធ្វើការនៅក្នុងនោះ ។"

HONEYCOMB 2/1 (January 2001): 129–132

# Meet Yos Em Sithan

*Debbi MAHER*

*YOS Em Sithan*

Yos Em Sithan became a Christian in 1975, one week before the Khmer Rouge invaded Phnom Penh. Her brother Yos Ann Tipo led her to the Lord; her sister Yos Kam Molly was already a strong believer.

Having so little time to understand her new faith, she cried almost daily to God, "Why was this all happening? Please help me." Such was the extent of her new faith. God answered her prayers in a variety of ways. Although she had previously been a student and her father a government official, she was able to convince the Khmer Rouge soldiers otherwise and thereby avoid almost certain elimination. She was often asked what she used to do. "Are you a student? What was your job before?" She replied that she had been a vegetable seller in the market.

She was fortunate that her entire family was able to remain together when they were relocated to Prey Veng to work as rice farmers. Suspicious that she and her family were from the educated class, the soldiers would often ask questions regarding their skill in farming or hard labor. God intervened by giving her rice-planting skills, which as a city girl she had never had. Another means by which God provided for their family was Em Sitan's father's background with the Ministry of Agriculture. This gave him some understanding of farming, and allowed them to secretly grow extra food for their family. In 1978 her family was eventually separated, and the Khmer Rouge arranged for her subsequent marriage.

After the fall of the Pol Pot regime, her family did not immediately declare their faith openly. Her father, knowing the then-current system of government, felt strongly that they should be cautious. He had witnessed the deportation of a World Council of Churches representative known for his evangelistic activity.

1989 was a year of new life, and the realization of eternal life, in Em Sithan's family. Her husband, Malk Wathna, become a Christian following study in Cuba, and her father, Yos Ann, went home to be with the Lord. He had been respected in both Christian and Buddhist circles. The arrangements for his funeral created a major dilemma. How would they perform the ceremony in a manner that reflected their Christian faith? They sought permission from the local authorities, only to be turned down. They did have a ceremony with many in attendance. Seang Ang performed the ceremony, and leaders such as Oung Rien and Sar Paulerk were present. After this Em Sithan began to wonder just how we as Christians should practice our faith? She was encouraged by a leader in the Catholic community to write the government for permission to actively express their faith.

She knew of a prominent official—related to her father by marriage—who had close ties with high-ranking government members. Because she and her family were not associated with any certain group, and because of the tremendous respect her father had in government circles, he agreed to help her submit a letter to the proper authorities. She then began to feel that "God had a plan for us." She met regularly with an official responsible for religious matters to discuss Christianity. He wanted to know what Christians

were and who was behind them (meaning outside foreign support). When he realized that she had no outside support and that she was a teacher in the Ministry of Education, he saw that it was possible to be a Christian and simultaneously maintain love for Cambodian people and culture. Permission was granted for Cambodian Christians to openly express their faith.

In 1990 the Olympic Church opened its doors. In the beginning, Em Sithan's family would simply read the Bible, sing songs, and listen to FEBC (Far East Broadcasting Cambodia). They started without any denominational or outside support in order to avoid being perceived as having been deceptive in their initial discussions with the government. Today the church has between forty and fifty members. It has no pastor. She calls herself a church leader. There are four elders who share the speaking duties each week. Bible study is taken seriously in this church. Em Sithan has a TEE degree, and the church has an active outreach program. The Olympic Church has sister churches in Kampong Cham, Kang Meas, Batheay, and Rokakong (Kandal Province).

From 1993–97 Em Sithan served on the translation committee with Arun Sok Nep for the new translation of the Cambodian Bible. Until March 2000 she had maintained a part-time position within the Ministry of Education. She now works full time for the Bible Society as their Executive Secretary. The mission of the Bible Society is the translation, printing, and distribution of the Word of God for everyone, everywhere in Cambodia—especially the non-Christian.

Em Sithan remains optimistic regarding the growth of Christianity here. She sees the church and growing both spiritually and materially. She would caution fellow believers to always remain faithful to Jesus, as He is their only Savior. Following Christianity for power and gain is wrong. She is saddened to see poor Cambodians giving offerings to build lavish pagodas, which seldom address their personal or spiritual needs. She feels strongly that tithes, which go into churches, should be used outside the church for God's work. The Olympic Church uses their offerings for outreach and missions in the provinces. She would also enjoy having more fellowship with other local Christians, but finds that

her days are full with the demands of her church and the Bible Society.

When discussing the evangelization of Cambodia, Em Sithan has an open mind, and welcomes foreign missionaries. She believes strategies should fit the situation as well as the country. Evangelism must be lived as well as spoken. It is important to share the need to love God and each other. What should not be done is to spend too much time arguing over denominations and translations. What is important is to obey God, fear and respect Him. He, alone is the judge; we should not judge each other.

In 1994, American evangelist Mike Evans brought a disastrous "crusade" to Cambodia. He made promises of healing to all who came, and eventually narrowly avoided having the stage overturned by the riotous stadium crowd. When Em Sithan saw the promotion of this event, she found it disconcerting that the evangelist's name was given more prominence than name of Jesus Christ. She made the decision that Olympic Church would not take part in this event. When co-workers at the Ministry of Education taunted her regarding the failed spectacle, she simply replied, "If you have questions regarding my Christianity, I would be happy to share with you. If, on the other hand, you wish to argue and criticize the events of the crusade, then I really have nothing to say." She believes as Christians study the word of God they will gain discernment regarding the various messages and messengers who come to Cambodia.

Em Sithan admits that there are many misconceptions regarding Cambodian Christians. A former co-worker at the Ministry of Education was surprised that she was a Christian; after all, she was an educated woman. She continued with the equally popular question, "So how much money do you receive for having a church in your home?" She replied, "If you really believe my faith is just about the money, why don't you open up your house and make some money as I do?"

Em Sithan was right to believe that God has a plan for her and Cambodia. He has shown her His faithfulness, protection, perfect timing, and provision. She has responded with a sincere desire to serve Him with humility, integrity, and a love for her country and its people.

សំណុំធិកឃ្មុំ ២/១ (មករា ២០០១)៖ ១៣៣-១៤០

# ការជួបជាមួយអ្នកស្រី យស់ ឯមស៊ីថាន

លោកស្រី ដេប៊ី ម៉ាហ៊ើ

លោកស្រី យស់ ឯមស៊ីថាន

លោកស្រី យស់ ឯមស៊ីថាន ថ្វាយជីវិតដល់ព្រះគ្រីស្ទ នៅក្នុងឆ្នាំ ១៩៧៥ គឺនៅពេលមួយអាទិត្យមុនពួកខ្មែរក្រហមចូលលុកលុយ ក្នុងទីក្រុងភ្នំពេញ ។ ប្អូនប្រុសរបស់គាត់ឈ្មោះ យស់ អានទីប៉ូ បាននាំគាត់ និង ប្អូនស្រីរបស់គាត់ឈ្មោះ យស់ កាំម៉ូលី ឲ្យថ្វាយជីវិតទទួលជឿព្រះអម្ចាស់ ហើយប្អូនស្រីគាត់ក៏ជាអ្នកជឿរឹងមាំ កាលពីពេលនោះដែរ ។

ដោយសារតែមានពេលតិចតួច ដើម្បីឲ្យបានយល់ច្បាស់ចំពោះជំនឿថ្មីរបស់គាត់នោះ គាត់បានយំស្ទើររាល់ថ្ងៃ ហើយបានទូលសួរព្រះជាម្ចាស់ថា៖ "ហេតុអ្វីបានជារឿងរ៉ាវទាំងនេះកើតឡើងដូច្នេះ?" គាត់ក៏បានទូលដល់ព្រះជាម្ចាស់ផងដែរថា "ព្រះអម្ចាស់អើយ សូមជួយកូនផង" ។ ការបែបនោះបានធ្វើឲ្យជំនឿថ្មីរបស់គាត់រីកចំរើនឡើង ។ ព្រះជាម្ចាស់បានឆ្លើយតបចំពោះការអធិស្ឋានទាំងនោះតាមបែបផ្សេងៗ ។ ទោះបីមុនពេលខ្មែរក្រហមចូលមកគាត់ជានិស្សិត និងឪពុករបស់គាត់ជាមន្ត្រីធ្វើការនៅក្នុងរដ្ឋាភិបាលក៏ដោយ គាត់អាចបង្ហាញឲ្យពួកទាហានខ្មែរក្រហម ទុកចិត្តបើពុំនោះទេខ្មែរក្រហមមិនទុកឲ្យរស់ឡើយ ។ ខ្មែរក្រហមតែងតែសួរគាត់ពីមុខរបរពីមុនរបស់គាត់ ។"តើអ្នកឯងជានិស្សិតឬ?" "ធ្វើការអីពីមុន?" ចម្លើយរបស់គាត់នោះគឺថា គាត់ជាអ្នកលក់បន្លែនៅឯផ្សារ ។

គាត់មានសំណាង ដោយបានខ្មែរក្រហមជំលៀសទៅធ្វើស្រែនៅខេត្តព្រៃវែង ទៅទាំងគ្រួសារតែម្តង ។ ដោយមានការសង្ស័យថា គាត់និង គ្រួសាររបស់គាត់ជាត្រកូល ដែលបានទទួលការអប់រំចេះដឹងនៅក្នុងសង្គម ពួកទាហានខ្មែរក្រហមតែងតែព្យាយាមសួរនូវសំណួរជាច្រើនដើម្បីល្បងល មើលការប៉ិនប្រសប់ផ្នែករបរធ្វើស្រែចំការ ឬ ក៏ដាក់ការងារលំបាកៗឲ្យធ្វើ ។ ព្រះជាម្ចាស់ជួយក្នុងការនោះ ដោយផ្តល់ឲ្យគាត់នូវភាពស្ទាត់ជំនាញផ្នែកស្ទូងស្រូវ ដែលអ្នកទីក្រុងមិនដែលធ្លាប់ចេះពីមុនមក ។ មធ្យោបាយមួយទៀត ដែលព្រះជាម្ចាស់ការពារនោះ គឺដោយផ្តល់ឲ្យឪពុករបស់លោកស្រី ឯម ស៊ីថាន ធ្លាប់ជាមន្ត្រីរដ្ឋការធ្វើការនៅក្រសួងកសិកម្ម ។ ការនេះឯង ដែលអាចឲ្យគាត់អាចយល់ដឹងពីរបៀបធ្វើស្រែចំការខ្លះៗ និង អាចលបដាំដំណាំខ្លះ ដើម្បីជួយផ្តល់អាហារដល់គ្រួសាររបស់គាត់បន្ថែមទៀត ។ នៅក្នុងឆ្នាំ ១៩៧៨ គ្រួសាររបស់គាត់ត្រូវបានបែកខ្ញែកគ្នា ហើយនិងពេលនោះខ្មែរក្រហមបានរៀបចំឲ្យគាត់រៀបការ ។

បន្ទាប់ពីរបប ប៉ុល ពត ត្រូវរលំដួលទៅ គ្រួសាររបស់គាត់មិនទាន់ហ៊ានប្រកាសពីជំនឿរបស់ខ្លួនដោយបើកចំហឡើយ ។ ឪពុករបស់គាត់ស្គាល់ពីប្រព័ន្ធដឹកនាំរបស់រដ្ឋាភិបាលសម័យនោះ ដោយដឹងយ៉ាងច្បាស់ថា គួរតែប្រុងប្រយ័ត្ន ។ ឪពុករបស់គាត់បានឃើញដោយផ្ទាល់ភ្នែក នូវការដែលរដ្ឋាភិបាលបញ្ជូនតំណាង WCC ដែលគេស្គាល់ថាជាសកម្មជនផ្សាយដំណឹងល្អឲ្យចេញក្រៅប្រទេស ។

នៅក្នុងឆ្នាំ ១៩៨៩ គឺជាឆ្នាំនៃជីវិតថ្មី និង គឺជាឆ្នាំនៃការបានដឹងពីជីវិតអស់កល្បជានិច្ចរបស់គ្រួសារលោកស្រី ឯម ស៊ីថាន ។ ប្ដីរបស់គាត់ឈ្មោះលោក ម៉ាក់ វឌ្ឍនា បានទទួលជឿព្រះយេស៊ូ បន្ទាប់ពីបានទៅសិក្សានៅប្រទេសគុយបា ។ ឪពុករបស់លោកស្រី ឯម ស៊ីថាន ឈ្មោះលោក យស់ អាន បានទៅនៅជាមួយនឹងព្រះអម្ចាស់នៅក្នុងឆ្នាំនោះដែរ ។ ឪពុក របស់គាត់ជាមនុស្ស ដែលគេគោរពរាប់អាន ទាំងនៅក្នុងរង្វង់គ្រីស្ទបរិស័ទ ក៏ដូចគ្នានិងក្នុងរង្វង់ពុទ្ធបរិស័ទ ។ នៅក្នុងការរៀបចំធ្វើបុណ្យសពរបស់គាត់មានការពិបាកក្នុងការសម្រេចចិត្តយ៉ាងខ្លាំង ។ តើពួកគេត្រូវធ្វើពិធីតាមរបៀបណា ដើម្បីបញ្ជាក់ឲ្យគេដឹងពីជំនឿគ្រីស្ទបរិស័ទរបស់ខ្លួននោះ? ពួកគេបានសុំច្បាប់ដល់អាជ្ញាធរ តែមិនបានសម្រេចសោះ ។ ពួកគេក៏បានធ្វើពិធីមួយ ដែលមានមនុស្សចូលរួមយ៉ាងច្រើនកុះករ ។ លោកគ្រូអាចារ្យ សៀង អង បានធ្វើពិធីនោះ ហើយនិង អ្នកដឹកនាំជាច្រើនរូបទៀត ក៏បានចូលរួមដែរ ដូចជាលោក អ៊ួង រៀន និង លោកសរ ពល: ។ បន្ទាប់ពីពេលនោះ លោកស្រី ឯម ស៊ីថាន ចាប់ផ្ដើមឆ្ងល់ក្នុងចិត្ត ចុះថាតើយើងជាគ្រីស្ទានត្រូវធ្វើយ៉ាងម៉េចចំពោះសិទ្ធិជំនឿរបស់ខ្លួន នៅពេលនោះមានគ្រីស្ទបរិស័ទម្នាក់នៅក្នុងព្រះសហគមន៍កាតូលិកបានលើកទឹកចិត្តឲ្យគាត់សរសេរសំបុត្រសុំច្បាប់អនុញ្ញាត ពីរដ្ឋាភិបាលដោយបញ្ជាក់ពីជំនឿរបស់ខ្លួនដោយបើកចំហ ។

គាត់បានស្គាល់មន្ត្រីសំខាន់ម្នាក់ ដែលមានទំនាក់ទំនងយ៉ាងជិតស្និទនឹងសមាជិកជាន់ខ្ពស់នៅក្នុងជួររដ្ឋាភិបាល ។ មន្ត្រីម្នាក់នេះត្រូវជាប់ជាសាច់ញាតិជាមួយនឹងសពឪពុករបស់គាត់ ។ ដោយសារតែគាត់ និង គ្រួសាររបស់គាត់ មិនមានជាប់ជំពាក់ជាមួយនឹងក្រុមជំនុំណាមួយច្បាស់លាស់ និង ដោយសារតែឪពុកគាត់មានការគោរពរាប់អានយ៉ាងជ្រាលជ្រៅនៅក្នុងរង្វង់ជួររដ្ឋាភិបាល មន្ត្រីម្នាក់នោះឯងក៏ព្រមជួយដាក់សំបុត្រសុំច្បាប់អនុញ្ញាតនោះទៅដល់កន្លែងអាជ្ញាធរជំនាញត្រឹមត្រូវ ។ នៅត្រង់ចំណុចនោះឯង គាត់ចាប់ផ្តើមមានអារម្មណ៍ថា "ព្រះជាម្ចាស់មានផែនការសំរាប់យើង" គាត់បានទៅជួបជាមួយនឹងមន្ត្រីម្នាក់ ដែលទទួលបន្ទុកកិច្ចការសាសនាជាញឹកញាប់ ដើម្បីសុំពិភាក្សាពីជំនឿគ្រីស្ទបរិស័ទ ។ មន្ត្រីនោះចង់ដឹងថាតើអ្វីទៅជាគ្រីស្ទបរិស័ទ ហើយតើនរណាជាអ្នកនៅពីក្រោយ (គឺមានន័យថាការគាំទ្រពីបរទេស) ។ នៅពេលដែលមន្ត្រីនោះបានដឹងថា គាត់គ្មានបានទទួលការគាំទ្រអ្វីពីខាងក្រៅនោះឡើយ ហើយបានដឹងថា គាត់ជាគ្រូបង្រៀននៅក្នុងក្រសួងអប់រំ មន្ត្រីនោះបានឃើញថាគាត់ជាគ្រីស្ទបរិស័ទ ប៉ុន្តែនៅស្រឡាញ់ជនជាតិខ្មែរ និងទំនៀមទម្លាប់ខ្មែរ ទើបព្រមអនុញ្ញាតច្បាប់ឲ្យគ្រីស្ទបរិស័ទខ្មែរជឿដោយស្របច្បាប់ ។

នៅក្នុងឆ្នាំ ១៩៩០ ពួកជំនុំនៅអូឡាំពីកបានបើកទ្វារប្រជុំជាផ្លូវការ ។ ពេលចាប់ផ្តើមដំបូង គ្រួសាររបស់លោកស្រី ឯម ស៊ីថាន គ្រាន់តែអានព្រះគម្ពីរ ច្រៀងសរសើរដំកើងព្រះ និងស្តាប់វិទ្យុសម្លេងនៃសេចក្តីស្រឡាញ់ (FEBC) ។ ពួកជំនុំនេះចាប់ផ្តើមឡើង ដោយគ្មាននិកាយ ឬការឧបត្ថម្ភគាំទ្រណាពីខាងក្រៅឡើយ ដើម្បីជៀសវាងការ ដែលគេមើលឃើញថា មានការឆបោក ឬ មិនស្មោះត្រង់ ផ្ទុយពីការដែលបានពិភាក្សាដំបូងជាមួយរដ្ឋាភិបាលនោះ ។ សព្វថ្ងៃនេះពួកជំនុំកើនឡើងរហូតដល់ ៤០-៥០ នាក់ហើយ គ្មានគ្រូគង្វាលឡើយ នៅក្នុងក្រុមជំនុំរបស់គាត់ ។ គាត់បានហៅខ្លួនឯងថា ជាអ្នកដឹកនាំក្រុមជំនុំ ។ មានចាស់ទុំ ៤ នាក់

ដែលចែករំលែកកិច្ចការគ្នា ក្នុងការអធិប្បាយប្រចាំអាទិត្យ ។ ការសិក្សាព្រះគម្ពីរ គឺគេយកចិត្តទុកដាក់យ៉ាងខ្លាំងនៅក្នុងក្រុមជំនុំ ។ លោកស្រី ឯម ស៊ីថាន មានសញ្ញាប័ត្រTEE ហើយក្រុមជំនុំក៏មានកម្មសិក្សានៅខាងក្រៅនិងបានបង្រៀនយ៉ាងសកម្មផងដែរ ។ ក្រុមជំនុំ អូឡាំពិក មានសាខានៅ ខេត្តកំពង់ចាម ស្រុកកងមាស បាធាយ និង ស្រុករកាកោង (ខេត្ត កណ្ដាល) ។

ចាប់ពីឆ្នាំ ១៩៩៣ រហូតដល់ ១៩៩៧ លោកស្រី ឯម ស៊ីថាន ជាសមាជិកគណៈកម្មាធិការក្រុមបកប្រែគម្ពីរខ្មែរសម្រាយ ជាមួយលោក សុខញឹប អារុណ ។ រហូតមកដល់ខែ មិនា ឆ្នាំ ២០០០ គាត់នៅតែមានតួនាទីពាក់កណ្ដាលពេលជាមួយក្រសួងអប់រំ ។ ឥឡូវនេះ គាត់ធ្វើការពេញពេលក្នុងសមាគមព្រះគម្ពីរក្នុងឋានៈជាអគ្គលេខាធិការ។ បេសកកម្មរបស់សមាគមព្រះគម្ពីរ គឺបកប្រែ បោះពុម្ព និង បែងចែកព្រះបន្ទូលរបស់ព្រះទៅមនុស្សគ្រប់រូប នៅគ្រប់ទីកន្លែងទាំងអស់ទូទាំងប្រទេសកម្ពុជា ជាពិសេសសំរាប់ពួកអ្នកមិនជឿ ។

ឯម ស៊ីថាន នៅតែមានសុទិដ្ឋិនិយមចំពោះការរីកដុលផុសនៃជំនឿគ្រីស្ទបរិស័ទនៅក្នុងប្រទេសកម្ពុជា ។ គាត់ឃើញថាក្រុមជំនុំនិងសមាជិកក្រុមជំនុំម្នាក់ៗមានការលូតលាស់ ទាំងផ្នែកវិញ្ញាណ និងទាំងខាងផ្នែកសម្ភារៈ ។ គាត់សូមឲ្យបងប្អូនអ្នកជឿនៅមានជំនឿស្មោះស្ម័គ្រ ចំពោះតែព្រះយេស៊ូ ដែលជាព្រះអង្គសង្គ្រោះតែមួយគត់របស់ពួកគេ ។ គឺមិនត្រូវមានបំណងចង់បានអំណាច ឬចង់បានលាភសក្ការៈ ដោយសារតែជំនឿជាគ្រីស្ទបរិស័ទនោះឡើយ ។ គាត់មានសេចក្ដីទុក្ខព្រួយ ដោយឃើញជនជាតិខ្មែរក្រីក្រខំដាក់ទាន និង ចូលលុយកាក់ ដើម្បី កសាងវត្តអារាមដែលកម្រនឹងបានជួយអ្វីដល់សេចក្ដីត្រូវការផ្ទាល់ខ្លួន ឬ សេចក្ដីត្រូវការផ្នែកវិញ្ញាណរបស់គេនោះឡើយ ។ គាត់មានជំនឿមុតមាំ ចំពោះការដាក់ដង្វាយនៅក្នុងពួកជំនុំ ដង្វាយនោះឯងគេយកទៅប្រើនៅខាង

ក្រៅសំរាប់សេចក្តីត្រូវការនៃការងាររបស់ព្រះជាម្ចាស់ ។ ក្រុមជំនុំ អូឡាំពិក ប្រើប្រាស់ដង្វាយរបស់ខ្លួនសំរាប់ការងារបេសកកម្ម នៅតាម ខេត្តនានា ។ គាត់រីករាយនឹងចូលរួមប្រកបជាមួយ នឹងគ្រីស្ទបរិស័ទដទៃទៀត ប៉ុន្តែដោយការងារពួកជំនុំ និងការងារសមាគមព្រះគម្ពីរទាមទារ ខ្លាំងពេក ទើបគាត់ខកខានក្នុងការប្រកបខ្លះៗនោះ ។

នៅពេលនិយាយពីការផ្សាយដំណឹងល្អក្នុងប្រទេសកម្ពុជា លោកស្រី ឯម ស៊ីថាន មានគំនិតទូលាយក្នុងការស្វាគមន៍ចំពោះបេសកជនបរទេស ។ គាត់ជឿថាយុទ្ធសាស្រ្តទាំងឡាយ ត្រូវតែស៊ីជាមួយនឹងស្ថានការណ៍នៅក្នុងប្រទេសដែរ ។ ការផ្សាយដំណឹងល្អ គឺត្រូវទៅព្រមជាមួយគ្នាទាំងការផ្សាយជាពាក្យសំដី និង ការផ្សាយតាមបន្ទាល់នៃជីវិតរស់នៅពិត ។ គឺជាការចាំបាច់ណាស់ ដែលយើងត្រូវផ្សាយពីសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ និងការដែលយើងត្រូវចេះស្រឡាញ់គ្នាទៅវិញទៅមកដែរ ។ អ្វីដែលគួរធ្វើនោះ គឺមិនត្រូវចំណាយពេលច្រើនជ្រុលហួសដល់ទៅឈ្លោះប្រកែកពីគណៈនិកាយ និង ពីគម្ពីរសម្រាយ និង គម្ពីរបកប្រែចាស់នោះឡើយ ។ អ្វីដែលសំខាន់គឺស្តាប់បង្គាប់ព្រះជាម្ចាស់ ដោយកោតខ្លាច និង គោរពដល់ព្រះអង្គ ព្រោះមានតែព្រះអង្គប៉ុណ្ណោះ ដែលជាចៅក្រម ។ យើងមិនត្រូវថ្កោលទោសគ្នាឡើយ ។

នៅក្នុងឆ្នាំ ១៩៩៤ មានអ្នកផ្សាយដំណឹងល្អជនជាតិអាមេរិកម្នាក់ឈ្មោះ **ម៉ៃ អេមិនស៍** បាននាំយកនូវភាពចលាចលនៃ "ការធ្វើការផ្សាយដំណឹងល្អដ៏មានទ្រង់ទ្រាយធំ" មួយមកកាន់កម្ពុជា ។ គាត់បានសន្យាប្រោសជម្ងឺដល់មនុស្សទាំងអស់ ដែលបានមកចូលរួម ហើយក្រោយមកក៏មានការរីករាវ ពីសំណាក់ពួកហ្វូងមនុស្សធ្វើឲ្យឆាកឈរប្រកាសដំណឹងនោះត្រូវរលំរលាយ ។ លោកស្រី ឯម ស៊ីថាន បានឃើញនៅពេល ដែលគេរៀបចំព្រឹត្តិការណ៍នេះឡើង គាត់យល់ឃើញថា គឺគួរឲ្យឆ្ងល់ណាស់ដែលឈ្មោះអ្នកផ្សាយដំណឹងល្អនោះត្រូវបាន គេលើកឲ្យលេចធ្លោខ្ពស់

ជាងព្រះនាមព្រះយេស៊ូគ្រីស្ទទៅទៀត ។ គាត់បានសម្រេចចិត្តថា ក្រុមជំនុំអូឡាំពិកមិនគួរចូលរួមនៅក្នុងព្រឹត្តិការណ៍នេះទេ ។ នៅពេលដែលបុគ្គលិករួមការងារនៅឯក្រសួងអប់រំបាននិយាយចំអកឲ្យគាត់ ចំពោះព្រឹត្តិការណ៍ដែលទទួលបរាជ័យនេះ គាត់គ្រាន់តែឆ្លើយថា "បើអ្នកមានសំណួរអ្វីដែលទាក់ទងនឹងជំនឿគ្រីស្ទបរិស័ទរបស់ខ្ញុំ នោះខ្ញុំរីករាយនឹងនិយាយប្រាប់អ្នកបាន តែផ្ទុយទៅវិញបើអ្នកចង់ឈ្លោះ និងរិះគន់ដល់ព្រឹត្តិការណ៍នោះ ខ្ញុំពិតជាគ្មានអ្វីដែលត្រូវនិយាយទេ" ។ គាត់ជឿថា ក្នុងនាមជាគ្រីស្ទបរិស័ទ នៅពេលដែលបានសិក្សាព្រះបន្ទូលនោះ គេនឹងអាចសំគាល់ព្រមទាំងយល់ដឹងពីព្រះរាជសារ និងអ្នកនាំសារផ្សេងៗដែលបានចូលមកក្នុងប្រទេសកម្ពុជា ។

លោកស្រី ឯម សីថាន ទទួលស្គាល់ថា នៅតែមានផ្តត់គំនិតយល់ខុសជាច្រើន ដែលទាក់ទងទៅនឹងគ្រីស្ទបរិស័ទកម្ពុជា ។ អតីតបុគ្គលិកធ្វើការជាមួយគ្នា នៅក្នុងក្រសួងអប់រំ មានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ដោយបានដឹងថា គាត់ជាគ្រីស្ទបរិស័ទ ជាពិសេសគាត់ជាស្ត្រី ដែលមានការអប់រំជ្រៅជ្រះម្នាក់នោះ ។

គាត់បានទទួលនូវការចោទជាសំណួរជាបន្តទៀតថា "តើអ្នកបានទទួលលុយប៉ុន្មាន សំរាប់ការទទួលបើកផ្ទះរបស់អ្នកឯង ធ្វើជាព្រះវិហារនេះ?" គាត់ក៏ឆ្លើយឡើងថា "បើសិនជាអ្នកពិតជាជឿថា ជំនឿរបស់ខ្ញុំ គឺព្រោះតែរឿងលុយ ចុះម៉េចក៏អ្នកមិនបើកផ្ទះរបស់អ្នក ហើយរកលុយឲ្យដូចខ្ញុំទៅ!" ។

លោកស្រី ឯម ស៊ីថាន ជឿជាក់យ៉ាងពិតប្រាកដថា ព្រះជាម្ចាស់មានផែនការសំរាប់គាត់ និង ប្រទេសកម្ពុជា ។ ព្រះអង្គបានបង្ហាញឲ្យគាត់ឃើញនូវសេចក្តីស្មោះស្ម័គ្រ ការគាំពារពេលវេលាដ៏ត្រឹមត្រូវ និងការផ្គត់ផ្គង់របស់ព្រះអង្គ ។ គាត់បានឆ្លើយតបទៅ ព្រះជាម្ចាស់ ដោយមាន

បំណងស្មោះត្រង់បំរើព្រះអង្គ ដោយបន្ទាបខ្លួន ដោយភាពស្មោះត្រង់ និង ដោយក្តីស្រឡាញ់ដល់ប្រទេសជាតិ និង ប្រជាជាតិរបស់ខ្លួន ។